ក្រសួងអប់រំ យុវជន និងកីឡា

ហាមលក់

ក្នុងកម្មវិធីបង់ថ្លៃ

# វិទ្យាសាស្ត្រ

# គីមីវិទ្យា

## ១០



For MEYC-Ebooks Only

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# គីមីវិទ្យា

## ថ្នាក់ទី ១០

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

For MPTC-Ebooks Only

**គណៈកម្មការនិពន្ធ** លោក សួន សុជាតិ លោក ចាន់ ខេង
លោក ម៉ី សុវណ្ណី អ្នកស្រី អន កិត្យាស៊ី
លោក ប៉ែន សំភា

**អ្នកវាយអត្ថបទ** អ្នកស្រី ហាក់ ផាន្នី

**វិចិត្រករ** លោក សិដ្ឋ ចាន់រដ្ឋា

**អ្នករៀបរៀង** លោក ស៊ុន ប៊ុណ្ណា

**អ្នករចនាទំព័រ** លោក ហាក់ វណ្ណថា

សូមថ្លែងអំណរគុណចំពោះ
ការជួយឧបត្ថម្ភរបស់អង្គការ JICA

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៧៥៩ អយក.ប្រក. ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©
**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី១២ ឆ្នាំ២០២០ ចំនួន ៣៤ ០០០ ច្បាប់

ISBN 9-789-995-000-738

For MPTC-Ebooks Only

# អារម្ភកថា

សៀវភៅគីមីវិទ្យាសម្រាប់សិស្សថ្នាក់ទី10 គណៈកម្មការយើងបានរៀបចំឡើងស្របតាមគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩ គឺឱ្យសិស្សស្គាល់ច្បាស់អំពីបាតុភូតដែលកើតឡើងនៅជុំវិញខ្លួនយើងតាមរយៈវិធីវិទ្យាសាស្ត្រ ។

សៀវភៅគីមីវិទ្យាថ្នាក់ទី10 មានទម្រង់ដូចខាងក្រោម :

- មេរៀននីមួយៗមានខ្លឹមសារនិងវត្ថុបំណងច្បាស់លាស់
- ខ្លឹមសារមេរៀនផ្ដើមចេញពីឧទាហរណ៍នៃបាតុភូតដែលមាននៅក្នុងជីវភាពរស់នៅ
- មេរៀនខ្លះមានសកម្មភាពពិសោធន៍ដើម្បីឱ្យសិស្សយកទៅអនុវត្តន៍ផ្ទាល់
- នៅចុងមេរៀននីមួយៗមានសង្ខេបមេរៀនដើម្បីឱ្យសិស្សចងចាំអ្វីដែលសិស្សបានរៀន
- មេរៀននីមួយៗមានសំណួរនិងលំហាត់ហើយសៀវភៅនេះក៏មានសំណួរនិងលំហាត់សម្រាប់ជំពូកនីមួយៗផងដែរ ។

ជាទីបញ្ចប់គណៈកម្មការនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ JICA ជាពិសេសអ្នកឯកទេសជប៉ុន ដែលបានជួយផ្ដល់យោបល់សម្រាប់អ្នកនិពន្ធ ព្រមទាំងលោកគ្រូ អ្នកគ្រូដែលបានសម្រួលនិងផ្ដល់យោបល់ក្នុងការសាកល្បង រួមទាំងគណៈកម្មការវាយតម្លៃដែលបានជួយត្រួតពិនិត្យនិងផ្ដល់យោបល់លើសៀវភៅនេះ ។

ដើម្បីឱ្យសៀវភៅសិស្សនេះកាន់តែល្អប្រសើរ គណៈកម្មការយើងខ្ញុំនឹងទទួលរាល់ការរិះគន់ និងកែលម្អបន្ថែមពីសំណាក់លោកគ្រូ អ្នកគ្រូដោយក្ដីរីករាយ ។

គណៈកម្មការនិពន្ធ

For MPTC Ebooks Only

# បញ្ជីអត្ថបទ

**ទំព័រ**


សេចក្តីផ្តើម ............ 1

**ជំពូក 1 ៖ អាតូម** ............ 5

1. ទ្រឹស្តីអាតូម ............ 6

2. ទម្រង់អាតូម ............ 12

**ជំពូក 2 ៖ តារាងខួបនៃធាតុគីមី** ............ 27

1. លក្ខណៈនៃតារាងខួប ............ 28

2. សិក្សាធាតុតាមក្រុម ............ 36

**ជំពូក 3 ៖ សម្ព័ន្ធគីមីនិងទម្រង់អង្គធាតុរឹង** ............ 51

1. សម្ព័ន្ធគីមី ............ 52

2. ទម្រង់អង្គធាតុរឹង ............ 64

**ជំពូក 4 ៖ គីមីសរីរាង្គ** ............ 77

1. ប្រេងកាតនិងឥន្ធនៈ ............ 78

2. អ៊ីដ្រូកាបួឆ្អែត ៖ អាល់កាន ............ 86

3. អ៊ីដ្រូកាបួមិនទាន់ឆ្អែត ............ 94

4. អ៊ីដ្រូកាបួប្រហើរ ៖ បង់សែន ............ 106

5. ជីគីមី ............ 116


For MPTC-Ebooks Only

# សេចក្តីផ្តើម

## 1. អ្វីទៅជាគីមី ?

**គីមី** គឺសិក្សាពី**រូបធាតុ**និងការបំប្លែងរបស់វា ដែលមាននៅជុំវិញយើងនិងក្នុងពិភពលោក ។ រូបធាតុដែលបង្កើតផែនដី សមុទ្រ និងខ្យល់ហៅថា**រូបធាតុដើម** ។ រូបធាតុទាំងនេះរួមបញ្ចូលទាំងធនធានធម្មជាតិសំខាន់ៗមាន រ៉ែ ថ្ម ធ្យូងថ្ម ប្រេងកាត និងឧស្ម័ន ។ ការងាររបស់អ្នកគីមី គឺសិក្សាស្រាវជ្រាវ អង្កេតលើរូបធាតុដើមនិងកំណត់លក្ខណៈរបស់រូបធាតុទាំងនោះ ។

រូបធាតុមានសារៈសំខាន់សម្រាប់មនុស្ស វាអាចប្តូរពីរូបធាតុមួយទៅរូបធាតុផ្សេងទៀតដូចជា លោហៈ ឥន្ធនៈ និងវត្ថុច្នៃប្រឌិត ។ រូបធាតុដើមភាគច្រើនមិនកើតឡើងវិញទេ ។ កំណើននៃការប្រើប្រាស់របស់មនុស្សធ្វើឱ្យរូបធាតុដើមមួយចំនួនដូចជា ធ្យូងថ្ម ប្រេងកាត និងឧស្ម័នធម្មជាតិនឹងអស់នៅពេលឆាប់ៗខាងមុខនេះ ។ ការណ៍នេះធ្វើឱ្យអ្នកគីមីខំស្វែងរកជម្រើសសម្រាប់ជំនួសរូបធាតុទាំងនេះ ។

ធនធានធម្មជាតិមានសារៈសំខាន់ណាស់សម្រាប់មនុស្ស ។ កំណើនប្រជាជនលើពិភពលោកធ្វើឱ្យមានតម្រូវការកសិផល និងម្ហូបអាហារយ៉ាងធំធេង ។ អ្នកគីមីបានផលិត ជី ថ្នាំសម្លាប់សត្វល្អិតចង្រៃ.... ដែលអាចបង្កើនទិន្នផលកសិកម្មនិងជួយធ្វើឱ្យកសិករមានជីវភាពប្រសើរឡើង ។ ម្យ៉ាងទៀតអ្នកគីមីយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការផលិតឱសថសម្រាប់ព្យាបាលជំងឺនិងថែរក្សាសុខភាព ។ លើសពីនេះទៀត គេបានខិតខំអភិវឌ្ឍសម្ភារៈទំនើបៗដែលធ្វើឱ្យការរស់នៅមានលក្ខណៈសមរម្យនិងសម្បូរបែប ។

For MPTC-Ebooks Only

## 2. ផ្នែកផ្សេងៗនៃគីមី

គីមីទំនើប (Modern Chemistry) មានផ្នែកផ្សេងៗជាច្រើនទៀតដូចជា : គីមីរ៉ែ គីមីសរីរាង្គ គីមីអនុវត្ត គីមីជីវៈ គីមីរូប និងគីមីវិភាគ ។

- **គីមីរ៉ែ** ( Inorganic Chemistry ) សិក្សាអំពីប្រតិកម្មគីមី និងលក្ខណៈគីមីរបស់ធាតុ និងសមាសធាតុរបស់វា លើកលែងតែសមាសធាតុកាបូនចេញ ។
- **គីមីសរីរាង្គ** ( Organic Chemistry ) សិក្សាអំពីសមាសធាតុកាបូន ។
- **គីមីអនុវត្ត** (Applied Chemistry ) សិក្សាពីគីមីឧស្សាហកម្ម គីមីកសិកម្ម និងគីមីឱសថ ។
- **គីមីវិភាគ** ( Analytical Chemistry ) សិក្សាលើការវិភាគបរិមាណ ដើម្បីកំណត់រកប្រភេទនៃធាតុគីមីក្នុងអង្គធាតុដែលគេសិក្សា និងវិភាគគុណភាពដើម្បីកំណត់រកសមាមាត្រនៃធាតុផ្សំទាំងនោះ ។

- **គីមីជីវៈ** ( Biochemistry ) សិក្សាអំពីផាតុបង្កនៃភាវៈរស់និងប្រតិកម្មគីមីដែលបង្កើតបានជាបណ្តួររូបធាតុដែលជាមូលដ្ឋានគ្រឹះនៃជីវិត ។
- **គីមីរូប** (Physical Chemistry) សិក្សាពីលក្ខណៈនៃការបំប្លែងរូបធាតុនិងទំនាក់ទំនងវាទៅនឹងថាមពលនិងទម្រង់ ។

## 3. ហេតុអ្វីត្រូវសិក្សាគីមី ?

យើងបានកំណត់និយមន័យគីមីថា ជាការសិក្សាពីរូបធាតុនិងការបំប្លែងរបស់វា ។

រូបធាតុនិងសារធាតុទាំងអស់ដែលនៅជុំវិញខ្លួនយើងគឺផ្សំឡើងពីធាតុគីមី ។ ខ្យល់ដែលយើងដកដង្ហើមជាល្បាយនៃធាតុគីមីដូចជា អុកស៊ីសែននិងអាសូត ។ សៀវភៅដែលអ្នកកំពុងអានគឺធ្វើឡើងដោយសែលុយឡូសដែលយកចេញពីសាច់ឈើនិងត្រូវបាន**ធ្វើប្រព្រឹត្តិកម្ម**ជាមួយនឹងធាតុគីមីផ្សេងៗទៀត ។ សម្លៀកបំពាក់ដែលយើងកំពុងស្លៀកពាក់បង្កើតឡើងពីការច្នៃប្រឌិតធាតុគីមីហៅថា**ប៉ូលីមែ** ដូចជា នីឡុង ឬប៉ូលីអេស្ទែ . . . ។ កៅអី តុ អគារ កុំព្យូទ័រ រថយន្ត និងសម្ភារៈប្រើប្រាស់ដទៃទៀតជាច្រើនគឺសុទ្ធសឹងតែជាផលិតផលដែលកើតនិងផ្សំឡើងពីធាតុគីមីទាំងអស់ ។ មានន័យថា គីមីមាននៅគ្រប់ទីកន្លែងហើយជះឥទ្ធិពលលើគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើងដែលចាំបាច់ត្រូវតែសិក្សា ។ ការយល់ដឹងពីមូលដ្ឋានគីមីនិងធាតុគីមីអាចជួយយើងក្នុងការបង្កើតរូបធាតុទាំងឡាយទូទាំងពិភពលោក ។




*រូបទី 1 : រូបវត្ថុប្រើប្រាស់ផ្សេងៗដែលជាផលិតផលនៃគីមី*

# 4. បំណិនរបស់អ្នកគីមី

នៅក្នុងវិទ្យាសាស្ត្រ ការសិក្សាគីមីទាក់ទងសំខាន់ទៅនឹងការសួរសំណួរនិងចម្លើយ “ជាអ្វីទៅ ?” “ដូចម្តេច ?” និង“ ហេតុអ្វី ”?។ ដើម្បីឆ្លើយសំណួរនិងចម្លើយទាំងនេះត្រូវទាក់ទងទៅនឹងបំណិនពិសេសរបស់អ្នកវិទ្យាសាស្ត្រ ។

ជាបឋម បំណិនលើការសង្កេតនិងកត់ត្រាគឺជាការចាំបាច់ ។ ការប្រើប្រាស់បំណិនទាំងនេះហាក់ដូចជាងាយស្រួលទេ ប៉ុន្តែដើម្បីធ្វើការកត់ត្រា គីមីវិទូត្រូវកត់ត្រាឱ្យបានច្បាស់លាស់និងជាក់លាក់នូវអ្វីដែលបានសង្កេតឃើញនិងត្រូវមានការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវ ។

បន្ទាប់មក ត្រូវមានបំណិនក្នុងការបកស្រាយរាល់ទិន្នន័យដែលទទួលបានពីពិសោធន៍ ។ ទិន្នន័យនិងបំណកស្រាយនេះ ធ្វើឱ្យយើងអាចអនុវត្តចំណេះដឹងគីមីទៅនឹងស្ថានភាពនានាបាន ។ បំណិនទាំងនេះទាក់ទងយ៉ាងខ្លាំង មិនត្រឹមតែនៅក្នុងផ្នែកវិទ្យាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងផ្នែកពាណិជ្ជកម្មនិងឧស្សាហកម្មផងដែរ ។



*រូបទី2 សិស្សកំពុងធ្វើពិសោធន៍គីមី*

ការវាយតម្លៃនិងវិភាគព័ត៌មាន គឺជាបំណិនចាំបាច់ផ្សេងទៀតដែលទាក់ទងទៅនឹងការសម្រេចចិត្តទៅលើព័ត៌មានដែលទទួលបានថា តើពិតឬមិនពិត ? រាល់ដំណោះស្រាយបញ្ហាទាំងឡាយ អាស្រ័យលើលទ្ធភាពវាយតម្លៃកត្តាដែលជះឥទ្ធិពលលើវា ។ កត្តាមួយចំនួនអាចប្រែប្រួលដោយអាស្រ័យទៅលើលក្ខខណ្ឌ ។ វាជាការចាំបាច់ក្នុងការសង្កេតតាមដានទៅលើកត្តាមួយក្នុងចំណោមកត្តាទាំងនេះ នៅពេលដែលកត្តាផ្សេងទៀតត្រូវបានរក្សាទុកឱ្យនៅថេរ ។ បន្ថែមទៅលើបំណិនខាងលើក្នុងការពិភាក្សា

For PIC-Books Only

ជាមួយអ្នកវិទ្យាសាស្ត្រផ្សេងទៀតអាចធ្វើអោយមានគំនិតកាន់តែទូលំទូលាយថែមទៀត ។ ដូចនេះ បំណិនក្នុងការទាក់ទងនិងពិភាក្សាគ្នាគឺជាកត្តាចាំបាច់បំផុត ។ បំណិនក្នុងការទាក់ទងត្រូវរួមបញ្ចូលទាំងការសរសេររបាយការណ៍អំពីពិសោធន៍ផ្សេងៗផង ។ របាយការណ៍នេះរួមមាន : ក្រាប តារាង ឬដ្យាក្រាម ។

សរុបសេចក្តីមក គ្រប់បំណិនទាំងអស់ត្រូវបានទាក់ទងគ្នាតាមគោលការណ៍នៃវិធីវិទ្យាសាស្ត្រ ដែលចាប់ផ្តើមពី :

1. ចំណោទបញ្ហា (ដូចម្តេច ? ហេតុអ្វី ?)
2. ការបង្កើតសម្មតិកម្ម (ព្រាងទុកចម្លើយ)
3. ការធ្វើតេសសម្មតិកម្ម (ការធ្វើពិសោធន៍)
4. ការវាស់វែងនិងការកត់ត្រាលទ្ធផល
5. ការសន្និដ្ឋាន

ប្រសិនបើសម្មតិកម្មផ្ទៀងផ្ទាត់ទៅឃើញថាត្រឹមត្រូវតាមគ្រប់កាលៈទេសៈទាំងអស់ ប៉ុន្តែមានតែករណីលើកលែងតិចតួច គេហៅថា **ទ្រឹស្តី** តែបើសម្មតិកម្មនោះមិនពិត គេត្រូវប្តូរឬបោះបង់ចោលបានដោយរិះរកសម្មតិកម្មថ្មី ។

For MPTC-EBooks Only

# ជំពូក 1 អាតូម



រូបធាតុទាំងអស់សុទ្ធសឹងបង្កឡើងដោយភាគល្អិតតូចបំផុតដែលមិនអាចមើលឃើញដោយភ្នែកទទេបាន ហៅថា **អាតូម** ។ តើអាតូមមានទម្រង់បែបណាបានជានាំឱ្យមានប្រតិកម្មគីមីនិងប្រតិកម្មនុយក្លេអ៊ែដែលបញ្ចេញថាមពលដ៏មហិមា ។

## មេរៀនទី 1 ៖ ទ្រឹស្ដីអាតូម

## មេរៀនទី 2 ៖ ទម្រង់អាតូម

For MPTC-Ebooks Only

មេរៀនទី

# 1 ទ្រឹស្តីអាតូម

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់ច្បាប់រក្សាម៉ាស ច្បាប់សមាមាត្រកំណត់ និងច្បាប់ពហុសមាមាត្រ ។
- ❒ ពណ៌នាចំណុចទាំងប្រាំនៃទ្រឹស្តីអាតូមរបស់ដាល់តុននិងចំណុចខ្វះខាតនៃទ្រឹស្តីនេះ ។
- ❒ ពន្យល់ពីទំនាក់ទំនងរវាងទ្រឹស្តីអាតូមរបស់ដាល់តុនទៅនឹងច្បាប់ទាំងបីខាងលើ ។

នៅប្រហែល 400 ឆ្នាំមុន គ.ស ទស្សនវិទូក្រិច **ដេម៉ូគ្រីត** (Democritus) បានលើកឡើងនូវទ្រឹស្តីដែលចែងថា “ គ្រប់វត្ថុទាំងអស់បង្កឡើងដោយភាគល្អិតតូចបំផុតដែលមិនអាចបំបែកបានហៅថា **អាតូម** ”(ដែលតាមភាសាក្រិចមានន័យថាមិនអាចបំបែកបាន) ។ ប៉ុន្តែនៅក្នុងសម័យនោះ ក៏មានទស្សនវិទូផ្សេងទៀតមិនយល់ស្របនឹងគំនិតអំពីអាតូមនោះទេ ។ លោក **អារីស្តូត**(Aristotle)( 384-322 ) ឆ្នាំមុន គ.ស មិនមានជំនឿទៅលើអាតូមទេ ។ គាត់យល់ថា វត្ថុទាំងអស់ផ្សំឡើងដោយធាតុបួនគឺ : ដី ទឹក ភ្លើង ខ្យល់ ដែលត្រូវបានលាយបញ្ចូលគ្នាតាមបរិមាណធាតុខុសៗគ្នា ។ គំនិតនេះបានបន្តអស់រយៈ ពេលប្រហែលជា 2000 ឆ្នាំទៅក្នុងវប្បធម៌របស់បស្ចិមប្រទេស ។ ប៉ុន្តែគំនិតដេម៉ូគ្រីតក្តី គំនិតអារីស្តូតក្តីមិនបានគាំទ្រដោយពិសោធន៍ឡើយ ។

## 1. មូលដ្ឋានគ្រឹះនៃទ្រឹស្តីអាតូម

នៅចុងសតវត្សទី 18 ការសិក្សាពីរូបធាតុតាមរយៈការពិសោធមានការអភិវឌ្ឍយ៉ាងខ្លាំង ដោយសារជញ្ជីងដែលគេបង្កើតឡើងកាន់តែមានភាពសុក្រិតដែលអាចឱ្យគេថ្លឹងម៉ាសអង្គធាតុប្រតិករនិងម៉ាសអង្គធាតុកកើតក្នុងប្រតិកម្មគីមីបានជាក់លាក់ ។ ពិសោធន៍ដោយប្រើជញ្ជីងកាន់តែសុក្រិតនាំទៅដល់ការរកឃើញនូវច្បាប់គ្រឹះមួយចំនួន ។

### 1.1 ច្បាប់រក្សាម៉ាស

**ពំនោលច្បាប់ :** “ **ក្នុងប្រតិកម្មគីមី ម៉ាសនៃអង្គធាតុប្រតិករស្មើនឹងម៉ាសនៃអង្គធាតុកកើត** ”

បានន័យថា គ្រប់បំលាស់ប្តូររូបឬគីមីពុំមានបម្រែបម្រួលម៉ាសនៃរូបធាតុទេ ។

For MPTC-Ebooks Only

## 1.2 ច្បាប់សមាមាត្រកំណត់

នៅក្នុងឆ្នាំ 1801 គីមីវិទូបារាំង សូសែបព្រូស (Joseph Louis Proust) បានបង្ហាញឱ្យឃើញថា ទង់ដែង(II) កាបូណាត ទោះបីគេផលិតវាតាមរបៀបណាក៏ដោយក៏សមាមាត្រនៃធាតុផ្សំគឺទង់ដែង 5 ភាគផ្សំនឹងកាបូន 1ភាគ និងអុកស៊ីសែន 4ភាគជានិច្ច ។

**ពំនោលច្បាប់ :** “ **អង្គធាតុសុទ្ធនីមួយៗមានភាគផ្សំ** (ធាតុគីមី) **ឋិតក្នុងសមាមាត្រជាម៉ាសកំណត់ហើយថេរជានិច្ច** ” ។

**ឧទាហរណ៍** : ទឹកគឺជាអង្គធាតុសមាសមួយដែលផ្សំដោយធាតុអ៊ីដ្រូសែននិងអុកស៊ីសែនមានសមាមាត្រជាម៉ាសរវាងធាតុគឺ (H) 11.11% និងធាតុ (O) 88.89% ជានិច្ចដោយមិនអាស្រ័យទៅនឹងប្រភពទេ ។



មិនថាទីណាទេ ទឹកផ្សំដោយធាតុ (H) 11.11% និងធាតុ (O) 88.89% ជានិច្ច

***រូបទី3 ទឹកជ្រោះប៊ូស្រា (ខេត្ត មណ្ឌលគិរី)***

## 1.3 ច្បាប់ពហុសមាមាត្រ

ជួនកាលធាតុគីមីពីរចូលផ្សំគ្នាបង្កើតបានជាសមាសធាតុច្រើនលើសពីមួយ ដូចជាធាតុកាបូននិងធាតុអុកស៊ីសែនចូលផ្សំគ្នាបង្កើតបានជាកាបូនម៉ូណូអុកស៊ីតនិងកាបូនឌីអុកស៊ីត ។ ការវិភាគរកម៉ាសនៃធាតុបង្ករបស់សមាសធាតុនីមួយៗបានលទ្ធផលដូចខាងក្រោម :

| **សមាសធាតុ** \ **ធាតុ** | **កាបូន** | **អុកស៊ីសែន** |
|---|---|---|
| កាបូនម៉ូណូអុកស៊ីត | 1.00g | 1.33g |
| កាបូនឌីអុកស៊ីត | 1.00g | 2.66g |
| $\frac{\text{ម៉ាសធាតុក្នុងកាបូនឌីអុកស៊ីត}}{\text{ម៉ាសធាតុក្នុងកាបូនម៉ូណូអុកស៊ីត}}$ | $\frac{1.00}{1.00} = 1$ | $\frac{2.66}{1.33} = 2$ |

តាមការគណនាបង្ហាញថា បើម៉ាសកាបូនស្មើគ្នា នោះផលធៀបម៉ាសអុកស៊ីសែនគឺ 2 ។ ការសង្កេតបែបនេះជាច្រើននាំឱ្យ **ចន ដាល់តុន** (*John Dalton*) លើកឡើងនូវច្បាប់ពហុសមាមាត្រនៅក្នុងឆ្នាំ1803 ។

**ពំនោលច្បាប់ :** “នៅពេលដែលធាតុគីមីពីរចូលផ្សំគ្នា បង្កើតបានជាសមាសធាតុពីរ ឬច្រើន នោះផលធៀបម៉ាសរវាងធាតុទី 2 ដែលផ្សំនឹងម៉ាសមួយដូចគ្នានៃធាតុទី 1 ជាចំនួនគត់តូច ” ។

For MPTC-Ebooks.COM

# 2. ទ្រឹស្ដីអាតូមរបស់ដាល់តុន

នៅក្នុងឆ្នាំ 1803 លោក **ដាល់តុន** បានលើកឡើងនូវការពន្យល់មួយពីច្បាប់រក្សាម៉ាស ច្បាប់សមាមាត្រកំណត់ និងច្បាប់ពហុសមាមាត្រ ។ ទ្រឹស្ដីរបស់គាត់អាចសង្ខេបបានដូចខាងក្រោម :

1. គ្រប់ធាតុទាំងអស់ផ្សំដោយភាគល្អិតតូចៗហៅថា **អាតូម** ។
2. អាតូមនៃធាតុតែមួយមាន ម៉ាស ទំហំ និងលក្ខណៈដូចគ្នា ។
   អាតូមនៃធាតុផ្សេងគ្នាមាន ម៉ាស ទំហំ និងលក្ខណៈខុសគ្នា ។
3. អាតូមមិនត្រូវបានបំបែក បង្កើតថ្មី ឬបំផ្លាញចោលទេ ។
4. អាតូមនៃធាតុផ្សេងគ្នា ចូលផ្សំគ្នាតាមផលធៀបជាចំនួនគត់ ដើម្បីបង្កើតជាសមាសធាតុ ។
5. ក្នុងពេលប្រតិកម្មគីមី អាតូមអាចចូលផ្សំគ្នា ផ្ដាច់ចេញពីគ្នា ឬតម្រៀបសាជាថ្មី ។



ចនដាល់តុន (***John Dalton***) (1766-1844)
រូបវិទូនិងគីមីវិទូអង់គ្លេសជាអ្នកបង្កើតទ្រឹស្ដីអាតូមនៅក្នុងឆ្នាំ 1803 ។

## បំណកស្រាយច្បាប់គីមីដោយទ្រឹស្ដីអាតូមដាល់តុន

**បំណកស្រាយច្បាប់រក្សាម៉ាស :** តាមច្បាប់រក្សាម៉ាស នៅក្នុងប្រតិកម្មគីមី ពុំមានអាតូមណាដែលត្រូវបាត់បង់ ឬបង្កើតថ្មី ឬរងការបំផ្លាញទេ អាតូមគ្រាន់តែផ្ដាច់ចេញពីគ្នា ចូលផ្សំឬតម្រៀបឡើងវិញតែប៉ុណ្ណោះ ។ ម៉ាសនិងចំនួននៃអាតូមនីមួយៗឋិតនៅមិនប្រែប្រួលទេ ព្រោះម៉ាសនៃរូបធាតុទទួលបានក្រោយប្រតិកម្មស្មើនឹងម៉ាសនៃរូបធាតុមុនប្រតិកម្ម ។

***ឧទាហរណ៍ :*** ការបង្កើតកាបូនម៉ូណូអុកស៊ីតពីកាបូន និងអុកស៊ីសែន និងការបំបែកកាបូនម៉ូណូអុកស៊ីតជាកាបូន និងអុកស៊ីសែន ។

ក.


កាបូន (C) | អុកស៊ីសែន (O) | កាបូនម៉ូណូអុកស៊ីត(CO)
ម៉ាស $x$ | ម៉ាស $y$ | ម៉ាស $x$ + ម៉ាស $y$

អាតូម C មួយនិងអាតូម O មួយចូលផ្សំគ្នាតាមបែបគីមីដើម្បីបង្កើតម៉ូលេគុល CO មួយ ។ ម៉ាសម៉ូលេគុលរបស់ CO ស្មើនឹងផលបូកម៉ាសអាតូម C និងម៉ាសអាតូម O ។

ខ.


កាបូនម៉ូណូអុកស៊ីត(CO) | កាបូន (C) | អុកស៊ីសែន (O)
ម៉ាស $x$ + ម៉ាស $y$ | ម៉ាស $x$ | ម៉ាស $y$

ម៉ាសនេះនៅតែស្មើគ្នាជានិច្ចទោះបីនៅពេលម៉ូលេគុល CO បំបែកទៅជាធាតុបង្កវាក៏ដោយ ។

For MPTC-Ebooks

**បំណកស្រាយច្បាប់សមាមាត្រកំណត់ :** តាមច្បាប់សមាមាត្រកំណត់ សមាសធាតុនីមួយៗមានភាគផ្សំកំណត់ ឬមានន័យថាអង្គធាតុសមាសមួយតែងតែបង្កដោយបន្សំនៃអាតូមដូចគ្នាជានិច្ចឬ ព្រោះធាតុគីមីដែលបង្កមាន ចំនួនអាតូមជាក់លាក់ ហើយអាតូមនីមួយៗមានម៉ាសកំណត់ស្រេច ។

ក.




ម៉ូលេគុល CO ផ្សំដោយ អាតូមកាបូន1 និងអាតូមអុកស៊ីសែន1ជានិច្ច ។

ខ.




ម៉ូលេគុលកាបូនឌីអុកស៊ីត $CO_2$ បង្កដោយអាតូម C មួយ និងអាតូមO ពីរជានិច្ច ។ នេះបង្ហាញថាម៉ូលេគុលកាបូនឌីអុកស៊ីតមានចំនួនអាតូមអុកស៊ីសែន 2 ដងនៃអាតូមអុកស៊ីសែនដែលមានក្នុងកាបូនម៉ូណូអុកស៊ីត ។

**បំណកស្រាយច្បាប់ពហុសមាមាត្រ :** ទ្រឹស្តីដាល់តុនបានពន្យល់ពីច្បាប់ពហុសមាមាត្រថា សមាសធាតុផ្សេងគ្នាដែលផ្សំដោយធាតុបង្កដូចគ្នា ខុសគ្នាតែចំនួនអាតូមនៃធាតុនីមួយៗតែប៉ុណ្ណោះ ដូចជាក្នុងករណីកាបូនអុកស៊ីតផលធៀប 2/1 បង្ហាញថា កាបូនឌីអុកស៊ីតមានចំនួនអាតូមអុកស៊ីសែនពីរដងនៃចំនួនអាតូមអុកស៊ីសែនដែលមានក្នុងកាបូនម៉ូណូអុកស៊ីត ។

## 3. ទ្រឹស្តីអាតូមទំនើប

ទ្រឹស្តីអាតូមរបស់ដាល់តុនបានបើកពិភពថ្មីនៃការពិសោធស្រាវជ្រាវ ។ ដោយមានការប្រមូលផ្តុំទិន្នន័យចាប់តាំងពីយុគសម័យដាល់តុនមក ចំណុចទាំងឡាយដែលមិនគ្រប់គ្រាន់នៅក្នុងទ្រឹស្តីដាល់តុនត្រូវបានលាតត្រដាងជាបណ្តើរៗ ។ ផ្ទុយពីទ្រឹស្តីដាល់តុនអាតូមខ្លះអាចចូលផ្សំជាមួយអាតូមដូចគ្នាដើម្បីបង្កើតជាម៉ូលេគុល ។ **ឧទាហរណ៍**ៈម៉ូលេគុលអ៊ីដ្រូសែន ($H_2$) ម៉ូលេគុលអុកស៊ីសែន ($O_2$) ម៉ូលេគុលអាសូត ($N_2$) ហើយនឹងមានម៉ូលេគុលផ្សេងៗទៀត ។ ការរកឃើញកាំរស្មី (X) និងវិទ្យុសកម្មនៅចុងសតវត្សទី19និងដើមសតវត្សទី20 បានបញ្ជាក់ថានៅក្នុងករណីខ្លះអាតូមត្រូវបានបំផ្លាញ ។ សព្វថ្ងៃនេះអ្នកវិទ្យាសាស្ត្រអាចបំបែកអាតូមឱ្យទៅជាភាគល្អិតតូចៗហើយអាចបំផ្លាញនិងបង្កើតអាតូមបាន ។

For MPTC Ebooks Only

## មេរៀនសង្ខេប

- ប្រហែលជា 400 ឆ្នាំមុន គ.ស ដែលទស្សនវិទូក្រិចដេម៉ូគ្រីត យល់ថារូបធាតុទាំងអស់បង្កដោយ អាតូម ។
- នៅឆ្នាំ 1803 ដាល់តុន បានចេញនូវទ្រឹស្ដីអាតូមដែលមាន 5 ចំណុច :
  - គ្រប់ធាតុទាំងអស់ផ្សំដោយភាគល្អិតតូចៗហៅថា អាតូម ។
  - អាតូមនៃធាតុតែមួយ មានម៉ាស ទំហំ និងលក្ខណៈដូចគ្នា ។
  - គេមិនអាចបំបែក បង្កើត ឬបំផ្លាញអាតូមបានទេ ។
  - អាតូមនៃធាតុផ្សេងគ្នា ចូលផ្សំគ្នាតាមផលធៀបជាចំនួនគត់ ។
  - ក្នុងពេលប្រតិកម្មគីមី អាតូមអាចចូលផ្សំគ្នា ផ្ដាច់ចេញពីគ្នា ឬតម្រៀបសាជាថ្មី ។
- **ច្បាប់រក្សាម៉ាស** : ម៉ាសនៃអង្គធាតុប្រតិករស្មើនឹងម៉ាសនៃអង្គធាតុកកើត ។
- **ច្បាប់សមាមាត្រកំណត់** : គ្រប់អង្គធាតុសុទ្ធមានភាគផ្សំឋិតក្នុងសមាមាត្រជាម៉ាសកំណត់ហើយ ថេរជានិច្ច ។
- **ច្បាប់ពហុសមាមាត្រ** : កាលណាធាតុពីរចូលផ្សំគ្នាបង្កើតបានជាសមាសធាតុពីរឬច្រើននោះ ផលធៀបម៉ាសរវាងធាតុទីពីរផ្សំនឹងម៉ាសមួយដូចគ្នានៃធាតុទីមួយជាចំនួនគត់តូច ។

For MPTC-Ebooks Only

## សំណួរនិងលំហាត់

1. ចូរពិពណ៌នាច្បាប់រក្សាម៉ាស និងពន្យល់ច្បាប់នេះដោយប្រើទ្រឹស្តីអាតូមរបស់ដាល់តុន ។ សំណួរដូចគ្នានេះដែរចំពោះច្បាប់សមាមាត្រកំណត់ និងច្បាប់ពហុសមាមាត្រ ។
2. ចូរពិពណ៌នាពីទ្រឹស្តីអាតូមរបស់ដាល់តុន និងចំណុចខ្វះខាតរបស់ទ្រឹស្តីនេះ ។
3. តើចំណុចណាខ្លះនៃទ្រឹស្តីអាតូមរបស់ដាល់តុនដែលមានតម្លៃរហូតដល់បច្ចុប្បន្ន?

For MPTC-Ebooks Only

មេរៀនទី

# 2 ទម្រង់អាតូម

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់បានពីសមាសភាពរបស់អាតូម និងលក្ខណៈរបស់ភាគល្អិតបង្កអាតូមនីមួយៗ ។
- ❒ ឱ្យនិយមន័យអ៊ីសូតូប ធាតុគីមី និងម៉ូល ។
- ❒ សរសេរបានពីតម្រៀបអេឡិចត្រុងនៅក្នុង 20 ធាតុដំបូង ។
- ❒ គណនាចំនួនម៉ូល និងម៉ាសនៃសារធាតុតាមរយៈរូបមន្ត : $m = n \times M$ ។

For MPTC-Ebooks Only

គ្រប់អង្គធាតុទាំងអស់បង្កឡើងដោយអាតូម ។ អាតូមនៃធាតុតែមួយដូចគ្នាហើយខុសពីអាតូមនៃធាតុផ្សេងទៀត ។ ដើម្បីកំណត់ធាតុគីមីមួយចាំបាច់គេត្រូវស្គាល់ពីទម្រង់អាតូមរបស់វា ។

## 1. អាតូម

អាតូមនីមួយៗមានពីរផ្នែកខុសគ្នា នៅចំកណ្ដាលគឺណៃ្វយ៉ូនិងនៅព័ទ្ធជុំវិញគឺពពកអេឡិចត្រុង ។

### 1.1 វិមាត្រអាតូម

អាតូមមានវិមាត្រតូចណាស់ គេចាត់ទុកអាតូមជាស្វ៊ែមួយដែលមានកាំប្រហែល $10^{-10}$m ឬ $\frac{1}{10}$nm ( 1 ណាណូម៉ែត្រ (1nm) = $10^{-9}$m ) ។ គេមិនបានដឹងពិតប្រាកដពីកាំរបស់អាតូមមួយដែលនៅដាច់តែឯងទេ ប៉ុន្តែគេគ្រាន់តែដឹងថាកាំរបស់អាតូមដែលធំជាងគេ គឺសេស្យូម មានប្រហែលប្រាំពីរដងនៃកាំអាតូមដែលតូចជាងគេ គឺអ៊ីដ្រូសែន ។

### 1.2 វិមាត្រណៃ្វយ៉ូ

គេអាចតាងណៃ្វយ៉ូជាស្វ៊ែមួយដែលមានកាំប្រហែល$10^{-15}$m ដូច្នេះកាំអាតូមធំជាងកាំណៃ្វយ៉ូ $10^5$ ដង ។

## 2. ភាគល្អិតបង្កអាតូម

អាតូមបង្កឡើងដោយភាគល្អិតតូចៗមាន ប្រូតុង ណឺត្រុង និងអេឡិចត្រុងដែលមានលក្ខណៈដូចបង្ហាញក្នុងតារាងខាងក្រោម :

| ភាគល្អិត | និមិត្តសញ្ញា | បន្ទុក( C គូឡំ ) | ម៉ាសធៀប | ម៉ាសពិត |
|---|---|---|---|---|
| ប្រូតុង | p | $+1\ (\approx 1.602\times10^{-19}C)$ | 1amu | $m_p = 1.673\times10^{-27}kg$ |
| ណឺត្រុង | n | 0 | 1amu | $m_n = 1.675\times10^{-27}kg$ |
| អេឡិចត្រុង | $e^-$ | $-1\ (\approx -1.602\times10^{-19}C)$ | $\frac{1}{1840}amu$ | $m_{e^-} = 9.109\times10^{-31}kg$ |

យើងឃើញថា :

- ប្រូតុងមានបន្ទុកអគ្គិសនីវិជ្ជមានដែលមានតម្លៃស្មើគ្នាទៅនឹងបន្ទុកអគ្គិសនីអវិជ្ជមាននៃអេឡិចត្រុង ឯណឺត្រុងគ្មានបន្ទុកអគ្គិសនីទេ ។
- ប្រូតុងនិងណឺត្រុងមានម៉ាសប្រហាក់ប្រហែលគ្នាហើយមានតម្លៃប្រហែលជា1840 ដងនៃម៉ាសអេឡិចត្រុងមួយ ។ ប្រសិនបើអាតូមមួយដែលមានអេឡិចត្រុងតិចជាង 100 នោះម៉ាសអេឡិចត្រុងទាំងអស់ជាតម្លៃមួយអាចចោលបានដោយធៀបនឹងម៉ាសប្រូតុងនិងម៉ាសណឺត្រុង ។ ដូច្នេះ ម៉ាសអាតូមទាំងមូលគឺជាម៉ាសនៃប្រូតុងនិងម៉ាសណឺត្រុង ។

  $m_p = m_n$ និង $m_p = 1840m_{e^-}$ ដូច្នេះ ម៉ាសអាតូម $\approx m_p + m_n$ ។

## 3. ទម្រង់អាតូម(ទីតាំងភាគល្អិតនៅក្នុងអាតូម)

### 3.1 ណ្វៃយ៉ូ

នៅក្នុងអាតូម ភាគល្អិតប្រូតុងនិងណឺត្រុងផ្តុំគ្នានៅក្នុងណ្វៃយ៉ូ ។ ដោយប្រូតុងផ្ទុកអគ្គិសនីវិជ្ជមាន ដូច្នេះណ្វៃយ៉ូ គឺជាផ្នែកនៃអាតូមដែលមានបន្ទុកអគ្គិសនីវិជ្ជមាន ។

### 3.2 អេឡិចត្រុង

អេឡិចត្រុងទាំងឡាយផ្លាស់ទីយ៉ាងលឿនជុំវិញណ្វៃយ៉ូ ហាក់ដូចជាភពទាំងឡាយដែលវិលជុំវិញព្រះអាទិត្យ បង្កើតបានជាពពកអេឡិចត្រុង ។ ពពកអេឡិចត្រុង គឺជាផ្នែកនៃអាតូមដែលមានបន្ទុកអគ្គិសនីអវិជ្ជមាន ។



*រូបទី1 : គំនូសតាងពពកអេឡិចត្រុងនៃអាតូមអ៊ីដ្រូសែន*

## 4. អត្តសញ្ញាណរបស់ធាតុ

ណ្វៃយ៉ូអាតូមនីមួយៗ មានចំនួនប្រូតុង $(Z)$ និងចំនួននុយក្លេអុង $(A)$ ។

**ចំនួនប្រូតុង** $(Z)$ ឬចំនួនបន្ទុក $(Z)$ ឬ**លេខអាតូម** $(Z)$ គឺជាចំនួនប្រូតុងដែលមាននៅក្នុងណ្វៃយ៉ូនៃអាតូមរបស់ធាតុមួយ ។

Hol MPTC-Ebooks Only

**ចំនួននុយក្លេអុង** ($A$) ឬ**ចំនួនម៉ាសអាតូម** ($A$) គឺជាចំនួនសរុបនៃប្រូតុងនិងណឺត្រុងដែលមាននៅក្នុងណៃ្វយ៉ូនៃអាតូមរបស់ធាតុមួយ ។

($Z$) និង ($A$) គឺជាចំនួនគត់ $A$ = ចំនួនប្រូតុង + ចំនួនណឺត្រុង

ឬ $A = Z +$ ចំនួនណឺត្រុង ឬ ចំនួនណឺត្រុង $= A - Z$

គេតាងណៃ្វយ៉ូនៃធាតុ $X$ មួយដោយនិមិត្តសញ្ញា ចំនួនម៉ាស $A$ / ចំនួនប្រូតុង $Z$ $\mathbf{X}$ ← និមិត្តសញ្ញាធាតុ

$$ {}^{A}_{Z}\mathbf{X} $$

បើអាតូមនៃធាតុ $X$ មួយមាន $Z$ ប្រូតុង វាក៏ត្រូវមាន $Z$ អេឡិចត្រុងដែរ ព្រោះថាអាតូមនីមួយៗ **ណឺត** តាមន័យអគ្គិសនី ។

ដូច្នេះ **ចំនួនប្រូតុង** ($Z$) = **ចំនួនអេឡិចត្រុង** = **លេខអាតូម ។**

កាលណាគេស្គាល់ $Z$ និង $A$ របស់ណៃ្វយ៉ូធាតុមួយគេអាចកំណត់ចំនួន p ចំនួន n និងចំនួន $e^-$ នៃធាតុនោះបាន ។

***ឧទាហរណ៍ :*** ទម្រង់អាតូមសូដ្យូម

និមិត្តសញ្ញាណៃ្វយ៉ូសរសេរ ${}^{23}_{11}Na$ អាតូមសូដ្យូមមាន 11p , 11$e^-$ និងចំនួនណឺត្រុង $= 23 - 11 = 12n$ ។

**តារាងបង្ហាញពីភាគល្អិតបង្កអាតូមរបស់ធាតុ ២០ដំបូង**

| ធាតុគីមី | លេខអាតូម $Z$ | ចំនួនម៉ាស $A$ | ចំនួន p | ចំនួន $e^-$ | ចំនួន n ($A - Z$) |
|---|---|---|---|---|---|
| អ៊ីដ្រូសែន (H) | 1 | 1 | 1 | 1 | 0 (1 – 1) |
| អេល្យូម (He) | 2 | 4 | 2 | 2 | 2 (4 – 2) |
| លីចូម (Li) | 3 | 7 | 3 | 3 | 4 (7 – 3) |
| បេរីល្យូម (Be) | 4 | 9 | 4 | 4 | 5 (9 – 4) |
| បរ (B) | 5 | 11 | 5 | 5 | 6 (11 – 5) |
| កាបូន (C) | 6 | 12 | 6 | 6 | 6 (12 – 6) |
| អាសូត (N) | 7 | 14 | 7 | 7 | 7 (14 – 7) |
| អុកស៊ីសែន (O) | 8 | 16 | 8 | 8 | 8 (16 – 8) |

For MPTC-Ebooks Only

| | | | | | |
|---|---|---|---|---|---|
| ភ្លុយអរ (F) | 9 | 19 | 9 | 9 | 10 (19 – 9) |
| ណេអុង (Ne) | 10 | 20 | 10 | 10 | 10 (20 – 10) |
| សូដ្យូម (Na) | 11 | 23 | 11 | 11 | 12 (23 – 11) |
| ម៉ាញេស្យូម (Mg) | 12 | 24 | 12 | 12 | 12 (24 – 12) |
| អាលុយមីញ៉ូម(Al) | 13 | 27 | 13 | 13 | 14 (27 – 13) |
| ស៊ីលីស្យូម (Si) | 14 | 28 | 14 | 14 | 14 (28 – 14) |
| ផូស្វ័រ (P) | 15 | 31 | 15 | 15 | 16 (31 – 15) |
| ស្ពាន់ធ័រ (S) | 16 | 32 | 16 | 16 | 16 (32 – 16) |
| ក្លរ (Cl) | 17 | 35 | 17 | 17 | 18 (35 – 17) |
| អាកុង (Ar) | 18 | 40 | 18 | 18 | 22 (40 – 18) |
| ប៉ូតាស្យូម (K) | 19 | 39 | 19 | 19 | 20 (39 – 19) |
| កាល់ស្យូម (Ca) | 20 | 40 | 20 | 20 | 20 (40 – 20) |

# 5. អ៊ីសូតូប

## 5.1 និយមន័យ

នៅក្នុងធម្មជាតិ ពេលខ្លះគេសង្កេតឃើញអាតូមនៃធាតុគីមីតែមួយមានម៉ាសខុសគ្នា ឧទាហរណ៍ ទង់ដែងធម្មជាតិមានអាតូមពីរប្រភេទគឺ ទង់ដែង 63 និងទង់ដែង 65 ។

| ប្រភេទអាតូម | និមិត្តសញ្ញាណ្វៃយ៉ូ | ចំនួននុយក្លេអុង | | % ក្នុងល្បាយធម្មជាតិ |
|---|---|---|---|---|
| | | p | n | |
| ទង់ដែង 63 | $^{63}_{29}Cu$ | 29 | 34 | 69.2 |
| ទង់ដែង 65 | $^{65}_{29}Cu$ | 29 | 36 | 30.8 |

អាតូមទង់ដែងទាំងពីរមានចំនួនប្រូតុងដូចគ្នា តែខុសគ្នាដោយចំនួនណឺត្រុង ដូច្នេះចំនួនម៉ាសរបស់វាខុសគ្នា។ ប្រភេទអាតូមទង់ដែងទាំងពីរជាអ៊ីសូតូបនឹងគ្នា។

For MPTC-Ebooks Only

**និយមន័យ ៖ អ៊ីសូតូបគឺជាប្រភេទអាតូមនៃធាតុតែមួយដែលមានចំនួនណឺត្រុងខុសគ្នា ។**

គេប្រទះឃើញមានអ៊ីសូតូបធម្មជាតិប្រមាណជាង300 ប្រភេទខុសគ្នានិងប្រមាណជា1500 អ៊ីសូតូបនិមិត្ត ។

### តារាងខាងក្រោមបង្ហាញពីអ៊ីសូតូបនៃធាតុមួយចំនួន

| ធាតុគីមី | និមិត្តសញ្ញាណៃ្យយ៉ូអ៊ីសូតូប | % អ៊ីសូតូបក្នុងធម្មជាតិ | ម៉ាសអាតូមមធ្យម (amu) |
|---|---|---|---|
| អ៊ីដ្រូសែន (H) | ${}^{1}_{1}\mathbf{H}$ | 99.98 | 1.008 |
| | ${}^{2}_{1}\mathbf{H}$ | 0.02 | |
| | ${}^{3}_{1}\mathbf{H}$ | (ធាតុនិមិត្ត) | |
| កាបូន (C) | ${}^{12}_{6}\mathbf{C}$ | 98.9 | 12.001 |
| | ${}^{13}_{6}\mathbf{C}$ | 1.1 | |
| | ${}^{14}_{6}\mathbf{C}$ | $10^{-10}$ | |
| នីត្រូសែនឬអាសូត (N) | ${}^{14}_{7}\mathbf{N}$ | 99.63 | 14.007 |
| | ${}^{15}_{7}\mathbf{N}$ | 0.37 | |
| អុកស៊ីសែន (O) | ${}^{16}_{8}\mathbf{O}$ | 99.76 | 15.994 |
| | ${}^{17}_{8}\mathbf{O}$ | 0.04 | |
| | ${}^{18}_{8}\mathbf{O}$ | 0.20 | |
| ក្លរ (Cl) | ${}^{35}_{17}\mathbf{Cl}$ | 75.76 | 35.48 |
| | ${}^{37}_{17}\mathbf{Cl}$ | 24.24 | |

លក្ខណៈដូចគ្នានិងខុសគ្នានៃអ៊ីសូតូបត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម ៖

| លក្ខណៈដូចគ្នា | លក្ខណៈខុសគ្នា |
|---|---|
| ចំនួនប្រូតុង | ចំនួនណឺត្រុង |
| ចំនួនអេឡិចត្រុង | ចំនួនម៉ាស |
| លេខអាតូម | |
| លក្ខណៈគីមី | លក្ខណៈរូប ៖ឧ. កម្រិតរលាយ ដង់ស៊ីតេ |

For MPTC-Ebooks Only

### 5.2 របៀបគណនាម៉ាសអាតូមមធ្យម

***ឧទាហរណ៍ :*** ម៉ាសអាតូមមធ្យមរបស់ក្លរគឺ 35.5 ។ ម៉ាសអាតូមរបស់ក្លរ គឺជាម៉ាសមធ្យមនៃនុយក្លេអុងទាំងអស់របស់អ៊ីសូតូបទាំងពីរ $^{35}_{17}\mathrm{Cl}$ និង $^{37}_{17}\mathrm{Cl}$ ហើយភាពសម្បូររបស់វាក្នុងធម្មជាតិត្រូវបានបង្ហាញក្នុងតារាងខាងលើ ។

$$\text{ម៉ាសអាតូមមធ្យម (Cl)} = \left(35 \times \frac{75.76}{100}\right) + \left(37 \times \frac{24.24}{100}\right)$$

$$= 35.48 \approx 35.5\text{amu} \text{ ឬ } 35.5 \text{ ខ.អ}$$

### 5.3 ធាតុគីមី

តាមរយៈអ៊ីសូតូប គេអាចឱ្យនិយមន័យធាតុគីមីថា **ធាតុគីមីមួយត្រូវកំណត់ដោយលេខអាតូម** $Z$ **ឬចំនួនប្រូតុងក្នុងណ្វៃយ៉ូ ។**

***ឧទាហរណ៍ :*** ធាតុគីមីទង់ដែង $Z = 29$ ។ អាតូមមួយនៅជាប់តែឯងក្តី នៅក្នុងបន្សំក្តីដែលមានលេខអាតូម $Z = 29$ គឺជាអាតូមទង់ដែង ។ អាតូមមួយដែលមាន 29 ប្រូតុងនៅក្នុងណ្វៃយ៉ូ គឺជាអាតូមទង់ដែង ។ អាតូមមួយដែលមានលេខអាតូមខុសពី 29 មិនមែនជាអាតូមទង់ដែងទេ ។

## 6. ស្រទាប់អេឡិចត្រុងនៃអាតូម



(11 ប្រូតុង និង 12 ណឺត្រុង)

***រូបទី 2 : តម្រៀបភាគល្អិតនៅក្នុងអាតូមសូដ្យូម***

យើងដឹងថា អេឡិចត្រុង $Z$ របស់អាតូមមួយផ្លាស់ទីយ៉ាងលឿនជុំវិញណ្វៃយ៉ូ ។ អេឡិចត្រុងទាំងនេះត្រូវបានទាញទៅខាងណ្វៃយ៉ូដោយសារកម្លាំងទំនាញរវាងបន្ទុក $+Z$ របស់ប្រូតុងនិងបន្ទុក $-Z$ របស់អេឡិចត្រុង ។ ដើម្បីផ្តាច់អេឡិចត្រុងទាំងនេះចេញពីអាតូមគេត្រូវប្រើថាមពលមួយ ។ ពិសោធន៍ បង្ហាញថាអេឡិចត្រុងខ្លះងាយផ្តាច់ជាងអេឡិចត្រុងខ្លះទៀត ។ យោងទៅតាមទ្រឹស្តី អេឡិចត្រុងត្រូវបានពង្រាយជាស្រទាប់ៗ ។ អេឡិចត្រុងដែលឋិតនៅក្នុងស្រទាប់ជាមួយគ្នាមានចម្ងាយជាមធ្យមទៅណ្វៃយ៉ូដូចគ្នាហើយត្រូវការថាមពលបណ្តាច់ អេឡិចត្រុងក៏ស្មើគ្នាដែរ ។ គេនិយាយថា អេឡិចត្រុងទាំងនោះឋិតក្នុង**នីវ៉ូថាមពល**ជាមួយគ្នា ។ ដោយអេឡិចត្រុងផ្លាស់ទីយ៉ាងលឿន គេមិនអាចកំណត់បានពីទីតាំងពិតប្រាកដរបស់អេឡិចត្រុងនៅក្នុងគន្លងវាទេ តែគេអាចនិយាយថា **អេឡិចត្រុងនេះឋិតក្នុងនីវ៉ូថាមពលណាមួយតែប៉ុណ្ណោះ ។**

For MPTC Ebooks Only

គេរាប់ស្រទាប់អេឡិចត្រុងពីណ្វៃយ៉ូទៅក្រៅ ដូចជា K , L , M , N . . . ។ ស្រទាប់ទី1 ឬ K គឺជាស្រទាប់ដែលនៅជិតណ្វៃយ៉ូជាងគេ ។

អេឡិចត្រុងដែលនៅជិតណ្វៃយ៉ូជាងគេ មានស្ថិរភាពជាងអេឡិចត្រុងដែលនៅស្រទាប់ខាងក្រៅបន្ទាប់ ។

ស្រទាប់នីមួយៗអាចផ្ទុកអេឡិចត្រុងបានអតិបរមាចំនួន $2n^2$ ដែល $n$ ជាលេខស្រទាប់ ។

ស្រទាប់ទី 1 ឬស្រទាប់K អាចផ្ទុកជាអតិបរមាចំនួន 2 អេឡិចត្រុង

ស្រទាប់ទី 2 ឬស្រទាប់L អាចផ្ទុកជាអតិបរមាចំនួន 8 អេឡិចត្រុង

ស្រទាប់ទី 3 ឬស្រទាប់M អាចផ្ទុកជាអតិបរមាចំនួន 18 អេឡិចត្រុង




| ស្រទាប់អេឡិចត្រុង | អេឡិចត្រុងអតិបរមា $2n^2$ |
|---|---|
| K $n = 1$ | $2 \cdot 1^2 = 2$ |
| L $n = 2$ | $2 \cdot 2^2 = 8$ |
| M $n = 3$ | $2 \cdot 3^2 = 18$ |

***ចំនួនអេឡិចត្រុងអតិបរមាតាមស្រទាប់***

## របៀបបំពេញអេឡិចត្រុងតាមស្រទាប់

ការតម្រៀបអេឡិចត្រុងតាមស្រទាប់ ត្រូវបំពេញទៅតាមលំដាប់ K L M N . . . ។ កាលណាស្រទាប់ K ផ្ទុកអេឡិចត្រុងអតិបរមា ទើបបំពេញស្រទាប់ L ។ បើស្រទាប់ L ផ្ទុកអេឡិចត្រុងអតិបរមា ទើបបំពេញស្រទាប់ M ។ ប៉ុន្តែកាលណាស្រទាប់ M ផ្ទុកអេឡិចត្រុងចំនួន 8 ហើយស្រទាប់នេះមានស្ថិរភាព ។ អេឡិចត្រុងបន្ទាប់ ត្រូវចូលទៅបំពេញនៅក្នុងស្រទាប់ N វិញ ទោះស្រទាប់ M មិនទាន់មានអេឡិចត្រុងគ្រប់ចំនួនក៏ដោយ ។

អេឡិចត្រុងដែលនៅលើស្រទាប់ក្រៅបង្អស់ ហៅថា **អេឡិចត្រុងវ៉ាឡង់** ដែលមាននាទីយ៉ាងសំខាន់ក្នុងការកំណត់លក្ខណៈរបស់ធាតុនិងក្នុងការចងសម្ព័ន្ធរវាងអាតូម ។

For MPTC Ebooks Only

## តារាងរបាយអេឡិចត្រុងតាមស្រទាប់របស់ធាតុ 20 ដំបូង

| ធាតុគីមី | និមិត្តសញ្ញា | លេខអាតូម | ចំនួនអេឡិចត្រុង | ស្រទាប់អេឡិចត្រុង | | | | ទម្រង់អេឡិចត្រូនិច ឬរបាយអេឡិចត្រុង |
|---|---|---|---|---|---|---|---|---|
| | | | | K | L | M | N | |
| អ៊ីដ្រូសែន | **H** | 1 | 1 | 1 | | | | $(K)^1$ |
| អេល្យូម | **He** | 2 | 2 | 2 | | | | $(K)^2$ |
| លីចូម | **Li** | 3 | 3 | 2 | 1 | | | $(K)^2(L)^1$ |
| បេរីល្យូម | **Be** | 4 | 4 | 2 | 2 | | | $(K)^2(L)^2$ |
| បរ | **B** | 5 | 5 | 2 | 3 | | | $(K)^2(L)^3$ |
| កាបូន | **C** | 6 | 6 | 2 | 4 | | | $(K)^2(L)^4$ |
| អាសូត | **N** | 7 | 7 | 2 | 5 | | | $(K)^2(L)^5$ |
| អុកស៊ីសែន | **O** | 8 | 8 | 2 | 6 | | | $(K)^2(L)^6$ |
| ភ្លុយអរ | **F** | 9 | 9 | 2 | 7 | | | $(K)^2(L)^7$ |
| ណេអុង | **Ne** | 10 | 10 | 2 | 8 | | | $(K)^2(L)^8$ |
| សូដ្យូម | **Na** | 11 | 11 | 2 | 8 | 1 | | $(K)^2(L)^8(M)^1$ |
| ម៉ាញេស្យូម | **Mg** | 12 | 12 | 2 | 8 | 2 | | $(K)^2(L)^8(M)^2$ |
| អាលុយមីញ៉ូម | **Al** | 13 | 13 | 2 | 8 | 3 | | $(K)^2(L)^8(M)^3$ |
| ស៊ីលីស្យូម | **Si** | 14 | 14 | 2 | 8 | 4 | | $(K)^2(L)^8(M)^4$ |
| ផូស្វរ | **P** | 15 | 15 | 2 | 8 | 5 | | $(K)^2(L)^8(M)^5$ |
| ស្ពាន់ធ័រ | **S** | 16 | 16 | 2 | 8 | 6 | | $(K)^2(L)^8(M)^6$ |
| ក្លរ | **Cl** | 17 | 17 | 2 | 8 | 7 | | $(K)^2(L)^8(M)^7$ |
| អាកុង | **Ar** | 18 | 18 | 2 | 8 | 8 | | $(K)^2(L)^8(M)^8$ |
| ប៉ូតាស្យូម | **K** | 19 | 19 | 2 | 8 | 8 | 1 | $(K)^2(L)^8(M)^8(N)^1$ |
| កាល់ស្យូម | **Ca** | 20 | 20 | 2 | 8 | 8 | 2 | $(K)^2(L)^8(M)^8(N)^2$ |

For MPTC-Ebooks Only

# របាយអេឡិចត្រុងតាមស្រទាប់របស់ធាតុ ២០ ដំបូង




***គំនូសតាងរបាយអេឡិចត្រុងតាមស្រទាប់របស់ធាតុ20 ដំបូង***

## 7. ម៉ូល (mole)

### 7.1 ម៉ូល

ដោយអាតូមទាំងឡាយមានម៉ាសអាតូមតូចពេក គីមីវិទូមិនអាចថ្លឹងអាតូមមួយឬមួយចំនួនតូចបានទេ តែគេអាចថ្លឹងបានចំនួនធំមួយ ។ ក្នុងគោលបំណងនេះ គីមីវិទូប្រើឯកតាមួយដែលហៅថា **ម៉ូល** ។ និមិត្តសញ្ញានៃម៉ូលតាងដោយ **mol** ។



**អាវ៉ូកាដ្រូ**

(*Amedeo Avogadro* 1776-1856)

រូបវិទូនិងគីមីវិទូអ៊ីតាលីបានទទួលការកោតសរសើរដោយសារការរកឃើញចំនួនអាវ៉ូកាដ្រូ

ម៉ូល គឺជាចំនួនសន្មតមួយដូចជាឡូឬផ្លូនដែរ ។

ក្រូច 1 ឡូ មានចំនួន 12 ផ្លែ

ភាគល្អិត 1 ម៉ូលមានចំនួន $6.02 \times 10^{23}$ ភាគល្អិត

ចំនួន $6.02 \times 10^{23}$ ហៅថា ចំនួនអាវ៉ូកាដ្រូដែលតាងដោយ $\mathcal{N} = 6.02 \times 10^{23}$

ដូចនេះ 1 ម៉ូលអាតូមមាន $6.02 \times 10^{23}$ អាតូម

1 ម៉ូលម៉ូលេគុលមាន $6.02 \times 10^{23}$ ម៉ូលេគុល

1 ម៉ូលអេឡិចត្រុងមាន $6.02 \times 10^{23}$ អេឡិចត្រុង ។

For MPTC-Ebooks Only

## 1.2 ម៉ាសម៉ូល ($M$)

ម៉ាសម៉ូល គឺជាម៉ាសក្នុង 1 ម៉ូលនៃអាតូមឬម៉ូលេគុល ។ ម៉ាសម៉ូល ត្រូវគិតជា $g.mol^{-1}$ ។

### ក. គណនាម៉ាសម៉ូលអាតូម

**ឧទាហរណ៍** គណនាម៉ាសម៉ូលអាតូមអ៊ីដ្រូសែន បើអាតូមអ៊ីដ្រូសែនមួយមានម៉ាស $0.167 \times 10^{-23}$g

$M(\text{H})$ = ម៉ាសអាតូមអ៊ីដ្រូសែនមួយ $\times \mathcal{N}$

$M(\text{H}) = 0.167 \times 10^{-23} \times 6.02 \times 10^{23} = 1\text{g}.\text{mol}^{-1}$

ក្នុងការអនុវត្ត គេតែងប្រាប់ម៉ាសម៉ូលអាតូម ដូចជា :

$M(\text{H}) = 1\text{g}.\text{mol}^{-1}$ , $M(\text{C}) = 12\text{g}.\text{mol}^{-1}$ , $M(\text{O}) = 16\text{g}.\text{mol}^{-1}$

### ខ. គណនាម៉ាសម៉ូលម៉ូលេគុល

ដើម្បីគណនាម៉ាសម៉ូលម៉ូលេគុល គេត្រូវធ្វើផលបូកម៉ាសម៉ូលអាតូមដែលបង្កវា ។

$M(\text{A}_x\text{B}_y) = xM(\text{A}) + yM(\text{B})$ ដែល $M(\text{A})$ ; $M(\text{B})$ ជាម៉ាសម៉ូលអាតូម

**ឧទាហរណ៍** គណនាម៉ាសម៉ូលម៉ូលេគុលឧស្ម័នកាបូនិច ($CO_2$)

$M(\text{CO}_2) = M(\text{C}) + 2M(\text{O}) = 12 + (2 \times 16) = 44\text{g} \cdot \text{mol}^{-1}$

## 1.3 ទំនាក់ទំនងរវាងម៉ាសម៉ូលនិងបរិមាណរូបធាតុ

តាមរយៈនិយមន័យរបស់ម៉ាសម៉ូលគេបាន :

$m = n \cdot M$ 
- $n$ បរិមាណរូបធាតុគិតជា (mol)
- $m$ ម៉ាសនៃរូបធាតុគិតជា (g)
- $M$ ម៉ាសម៉ូលជា($\text{g} \cdot \text{mol}^{-1}$)

***ឧទាហរណ៍ :*** បរិមាណរូបធាតុ (ឬចំនួនម៉ូល) ដែលមានក្នុងកាល់ស្យូម 0.2g ដែល $M(\text{Ca}) = 40\text{g} \cdot \text{mol}^{-1}$

តាមទំនាក់ទំនង $m = n.M$ គេបាន $n_{\text{Ca}} = \dfrac{m_{\text{Ca}}}{M(\text{Ca})}$

ដោយ $M(\text{Ca}) = 40\text{g}.\text{mol}^{-1}$ ; $m_{\text{Ca}} = 0.2\text{g}$

ដូច្នេះ $n_{\text{Ca}} = \dfrac{0.2}{40} = 5 \times 10^{-3}\text{mol}$

For MPTC Ebooks Only

## មេរៀនសង្ខេប

- ទម្រង់អាតូមនៃធាតុ X មួយត្រូវកំណត់ដោយលេខអាតូម $Z$ ឬចំនួនប្រូតុងនិងចំនួនម៉ាស $A$ ។ គេតាងណ្វៃយ៉ូនៃធាតុ X ដោយ ${}^{A}_{Z}\mathrm{X}$ ។

អាតូម
- ណ្វៃយ៉ូ ⟶ ចំនួននុយក្លេអុង $A$ = ចំនួនម៉ាស $A$
  - $Z$ ប្រូតុង
  - $(A\text{-}Z)$ ណឺត្រុង
- ពពកអេឡិចត្រុង ⟶ $Z$ អេឡិចត្រុង

- ធាតុគីមីមួយត្រូវកំណត់ដោយលេខអាតូម $Z$ ឬចំនួនប្រូតុង ។
- អ៊ីសូតូបគឺជាប្រភេទអាតូមនៃធាតុតែមួយ ដែលមានលេខអាតូម $Z$ ឬចំនួនប្រូតុងដូចគ្នា ប៉ុន្តែមានចំនួនម៉ាស $A$ ខុសគ្នា ។
- អេឡិចត្រុង $Z$ នៅក្នុងអាតូមមួយវិលជុំវិញណ្វៃយ៉ូ ហើយតម្រៀបជាស្រទាប់ ។ អេឡិចត្រុងត្រូវបានតម្រៀបទៅតាមស្រទាប់ K , L , M , N ... ។ ស្រទាប់ K , L , M , N ...ត្រូវនឹងស្រទាប់ទី 1 , 2 , 3 , 4 ... ។
  ស្រទាប់នីមួយៗអាចផ្ទុកអេឡិចត្រុងបានជាអតិបរមា $2n^2$ ដែល $n$ ជាលេខស្រទាប់ ។
  អេឡិចត្រុងនៅលើស្រទាប់ក្រៅបង្អស់ ហៅថា **អេឡិចត្រុងវ៉ាឡង់** ។
- មួយម៉ូលតាងដោយ $\mathcal{N} = 6.02 \times 10^{23}$ ។ ខ្នាតនៃម៉ូលគឺ mol ។
  ម៉ាសម៉ូល $(M)$ ជាម៉ាសក្នុង 1 ម៉ូលនៃប្រភេទគីមីដែលបានលើកឡើង ។

ម៉ាសនៃសារធាតុ ⟵ $m = n \cdot M$ ⟶ ម៉ាសម៉ូលនៃសារធាតុ

↓ ($n$) ចំនួនម៉ូលនៃសារធាតុ

ម៉ាសម៉ូលនៃសមាសធាតុ $M(\mathrm{A}x\mathrm{B}y) = xM(\mathrm{A}) + yM(\mathrm{B})$ ដែល $M(\mathrm{A})$ ; $M(\mathrm{B})$ ជាម៉ាសម៉ូលអាតូម ។

For MPTC-Ebooks Only

## សំណួរនិងលំហាត់

1. តើផ្នែកនៃអាតូមដែលផ្ទុកអគ្គិសនីវិជ្ជមាន មានឈ្មោះអ្វី ? តើផ្នែកនេះបង្កដោយភាគល្អិតអ្វីខ្លះ ? តើអាតូមបង្កដោយភាគល្អិតអ្វីខ្លះ ? ចូររៀបរាប់ពីលក្ខណៈនៃភាគល្អិតនីមួយៗ ។
2. តើអ្វីទៅជាចំនួនណុយក្លេអុងនៃធាតុមួយ ?តើលេខអាតូមអាចឱ្យដឹងព័ត៌មានអ្វីខ្លះពីអាតូមមួយ ?
3. តើអ្វីទៅជាអ៊ីសូតូប ? តើគេសំគាល់ធាតុគីមីមួយដោយសារអ្វី ?
4. តើស្រទាប់អេឡិចត្រុងនីមួយៗអាចផ្ទុកអេឡិចត្រុងបានជាអតិបរមាប៉ុន្មាន? ចូរឱ្យឧទាហរណ៍ ។
5. តើអ្វីទៅជាអេឡិចត្រុងវ៉ាឡង់ ?
6. តើ 1ម៉ូលអាតូមដែកមានប៉ុន្មានអាតូមដែក ?

For MPTC-Ebooks Only

## សំណួរនិងលំហាត់ជំពូក1

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់**

1. ក្នុងចំណោមអំណះអំណាងពីប្រូតុងខាងក្រោម តើណាមួយដែល***មិន*** ត្រឹមត្រូវ :

☐ ក. ប្រូតុងជាភាគល្អិតដែលផ្ទុកបន្ទុកវិជ្ជមាន

☐ ខ. ប្រូតុងជាភាគល្អិតដែលមានម៉ាសអាចចោលបាន

☐ គ. ប្រូតុងជាភាគល្អិតដែលមាននៅក្នុងណ្វៃយ៉ូ

☐ ឃ. ប្រូតុងជាភាគល្អិតដែលមានគ្រប់អាតូមទាំងអស់

2. អាតូមមួយមាន 3 ប្រូតុង និងចំនួនម៉ាស 7 ។ អាតូមនេះត្រូវមាន :

☐ ក. 7 អេឡិចត្រុងនៅស្រទាប់ក្រៅ ☐ ខ. 3 ប្រូតុងក្នុងណ្វៃយ៉ូ

☐ គ. 4 ណឺត្រុងនៅជុំវិញណ្វៃយ៉ូ ☐ ឃ. 3 អេឡិចត្រុងនៅស្រទាប់ក្រៅ ។

3. អ៊ីសូតូបនៃធាតុតែមួយមាន :

☐ ក. ចំនួនណឺត្រុងខុសគ្នា ☐ ខ. ចំនួនប្រូតុងខុសគ្នា

☐ គ. លក្ខណៈគីមីខុសគ្នា ☐ ឃ. ភាគល្អិតក្នុងណ្វៃយ៉ូមានចំនួនដូចគ្នា

4. ប្រសិនបើគេដកចំនួនប្រូតុងចេញពីចំនួនម៉ាស លទ្ធផលទទួលបានជា :

☐ ក. ចំនួនប្រូតុងនៅក្នុងណ្វៃយ៉ូ ☐ ខ. ចំនួនណឺត្រុងនៅក្នុងណ្វៃយ៉ូ

☐ គ. ចំនួនប្រូតុងនិងអេឡិចត្រុងនៅក្នុងអាតូម ☐ ឃ. ចំនួនប្រូតុងនិងណឺត្រុងនៅក្នុងអាតូម

5. ស្រទាប់ M មានអេឡិចត្រុងអតិបរមា :

☐ ក. 8 អេឡិចត្រុង ☐ ខ. 10 អេឡិចត្រុង ☐ គ. 18 អេឡិចត្រុង

II. ចូរសរសេរពាក្យ ត្រូវ ឬខុស នៅក្នុងប្រអប់មុខអំណះអំណាងខាងក្រោម :

☐ 1. ធាតុមួយកំណត់ដោយចំនួននុយក្លេអុងក្នុងណ្វៃយ៉ូ ។

☐ 2. ណ្វៃយ៉ូពីរនៃធាតុតែមួយអាចមានចំនួនម៉ាសខុសគ្នា ។

☐ 3. អាតូមដែលមានទម្រង់អេឡិចត្រូនិច $(K)^2(L)^8$ មានលេខអាតូម $Z = 8$ ។

☐ 4. ប្រូតុងមួយមានម៉ាសប្រហែល 1840 ដងនៃម៉ាសអេឡិចត្រុង ។

☐ 5. ប្រូតុងនិងណឺត្រុងមានម៉ាសប្រហាក់ប្រហែលគ្នា ។

**III.ចូរបំពេញល្បះខាងក្រោមឱ្យមានន័យត្រឹមត្រូវ :**

1. ....................ជាភាគល្អិតផ្ទុកអគ្គិសនីវិជ្ជមានដែលមាននៅក្នុង . . . . . . . នៃអាតូម ។

2. អាតូមនៃ . . .. តែមួយដែលមានម៉ាសខុសគ្នាហៅថា . . . . . ។ វាមានចំនួន . . . . ខុសគ្នា ។

3. ដើម្បីបានប្រាក់ចំនួន 0.2mol គេត្រូវប្រមូលអាតូមប្រាក់ចំនួន . . . . . . . ដែលត្រូវនឹងម៉ាស . . . . g នៃប្រាក់ ។

For MPTC-EBooks Only

**IV. លំហាត់**

## ច្បាប់រក្សាម៉ាស - ច្បាប់ពហុសមាមាត្រ

1. ដោយអនុវត្តទៅតាមច្បាប់រក្សាម៉ាសរបស់រូបធាតុ បើធាតុ A មួយមានម៉ាសអាតូម 2 ខ្នាតម៉ាស (2 ខ.អ) ហើយធាតុ B មានម៉ាសអាតូម 3 ខ្នាតម៉ាស (3 ខ.អ) តើសមាសធាតុ AB មានម៉ាសម៉ូលេគុលប៉ុន្មាន ? តើសមាសធាតុ $A_2B_3$ មានម៉ាសម៉ូលេគុលប៉ុន្មាន ?
2. គេមានសមាសធាតុឧស្ម័នបី A B និង C ដែលផ្សំដោយធាតុអាសូតនិងអុកស៊ីសែន ។ A ជាឧស្ម័នដែលធ្វើឱ្យហៀរទឹកភ្នែកមានអាសូត 63.65 % ។ B ជាឧស្ម័នគ្មានពណ៌ដែលមានអាសូត 46.68 % និង C ជាឧស្ម័នពណ៌ត្នោតដែលមានអាសូត 30.45 % ។

   ក. ចូរគណនាភាគរយនៃធាតុអុកស៊ីសែនដែលមានក្នុង A B និង C ។

   ខ. តើទិន្នន័យនេះគាំទ្រច្បាប់ពហុសមាមាត្រដែរឬទេ ?
3. គេមានសមាសធាតុពីរ សមាសធាតុទី 1 មានសូដ្យូម 2.00g ក្លរ 3.08g និងអុកស៊ីសែន 1.39g ។ សមាសធាតុទី 2 មានសូដ្យូម 1.00g ក្លរ 1.54g និងអុកស៊ីសែន 2.78g ។

   ចូរបង្ហាញថាទិន្នន័យទាំងនេះគាំទ្រច្បាប់ពហុសមាមាត្រ ។

## ទម្រង់អាតូម

1. ចូរកំណត់ភាគល្អិតបង្កអាតូមក្នុងករណីដូចតទៅ : $^{59}_{27}Co$ $^{84}_{36}Kr$ $^{209}_{83}Bi$ ។
2. ណ្វៃយ៉ូនៃអាតូមមួយមាន 15 ប្រូតុង និង 16 ណឺត្រុង ។

   ក. តើនៅក្នុងស្រទាប់អេឡិចត្រុងមានអេឡិចត្រុងចំនួនប៉ុន្មាន ?

   ខ. តើវាមានលេខអាតូមប៉ុន្មាន ? ចំនួនម៉ាសប៉ុន្មាន ?

## ទម្រង់អេឡិចត្រូនិច

ចូរឱ្យទម្រង់អេឡិចត្រូនិចនៃអាតូមដូចតទៅ : $^{7}_{3}Li$ $^{40}_{20}Ca$ $^{28}_{14}Si$ $^{20}_{10}Ne$ $^{40}_{18}Ar$ $^{39}_{19}K$ ។

## អ៊ីសូតូប

1. អ៊ីសូតូបនៃក្លរដែលសម្បូរជាងគេគឺ $^{35}_{17}Cl$ ។ អ៊ីសូតូបមួយទៀតនៃក្លរមានណឺត្រុងចំនួន 20 ។ ចូរសរសេរនិមិត្តសញ្ញាតាងអ៊ីសូតូបនេះ និងឱ្យទម្រង់អាតូមនៃអ៊ីសូតូបទាំងពីរ ។
2. គេមានអាតូមពីរ ដែលមួយៗមាន 14 ណឺត្រុង ។ អាតូមទីមួយមាន 13 ប្រូតុងនិង 13 អេឡិចត្រុង អាតូមទីពីរមាន 14 ប្រូតុង និង 14 អេឡិចត្រុង ។ តើអាតូមទាំងពីរជាអ៊ីសូតូបនៃធាតុតែមួយដែរឬទេ ? ចូរបញ្ជាក់ចម្លើយ ។

For MPTC-Ebooks Only

3. នៅក្នុងធម្មជាតិអាតូមបរ មានម៉ាសអាតូម 11.01amu មាន 80.20 % ហើយអ៊ីសូតូបនៃបរមួយទៀតមាន 19.80 % ។ តើអ៊ីសូតូបនេះមានម៉ាសអាតូមប៉ុន្មាន បើម៉ាសអាតូមមធ្យមនៃធាតុនេះគឺ 10.81amu ។

4. ក្នុងធម្មជាតិអុកស៊ីសែនមានអ៊ីសូតូបបីគឺ អុកស៊ីសែន 16 អុកស៊ីសែន 17 និងអុកស៊ីសែន 18 ។ គេដឹងថាអុកស៊ីសែនមាន 8 ប្រូតុង ។

ក. ចូរសរសេរនិមិត្តសញ្ញាតាងអ៊ីសូតូបទាំងបី ។

ខ. ចូរឱ្យទម្រង់អាតូមនៃអ៊ីសូតូបទាំងបី ។

គ. ចូរឱ្យទម្រង់អេឡិចត្រូនិចនៃអ៊ីសូតូបទាំងបី ។

**ម៉ូល** ***(mole)***

1. គណនាចំនួនម៉ូលដែលត្រូវនឹងធាតុខាងក្រោម :

ក. $6.02 \times 10^{23}$ អាតូម (Ne) ខ. $3.011 \times 10^{23}$ អាតូម (Mg)

គ. $3.25 \times 10^{5}$g (Pb) ឃ. 150g (S)

2. គណនាចំនួនអាតូមដែលត្រូវនឹង

ក. 1.50mol (Na) ខ. 0.75mol (Fe)

3. គណនាម៉ាសជា g ក្នុងករណីខាងក្រោម :

ក. 3.00mol (Al) ខ. 1.38mol (Cu)

គ. $4.86 \times 10^{24}$ អាតូម (Au) ឃ. $4.86 \times 10^{24}$ អាតូម (Hg)

4. លោហៈអាលុយមីញ៉ូម (Al) មានដង់ស៊ីតេ $2.7 \times 10^{3}$kg.m$^{-3}$ ។ តើមានអាតូមអាលុយមីញ៉ូមចំនួនប៉ុន្មាននៅក្នុងគូបមួយដែលមានទ្រនុង 1.0cm ?

For MPTC-Ebooks Only

# ជំពូក 2 តារាងខួបនៃធាតុគីមី




នៅក្នុងបណ្ណាល័យគេរៀបចំសៀវភៅដែលមានមុខវិជ្ជាដូចគ្នាឬខ្លឹមសារស្រដៀងគ្នានៅលើធ្នើរ ឬទូជាមួយគ្នា ។ ក៏ដូចគ្នាដែរ គេរៀបចំធ្វើចំណែកថ្នាក់នៃធាតុគីមីទាំងអស់តាមក្រុមនិងខួបជាមួយគ្នា។ ដោយពិនិត្យតាមតារាងនេះគេអាចប្រាប់បានយ៉ាងរហ័សពីធាតុដែលដូចគ្នានិងលក្ខណៈរបស់វាហើយ តារាងនេះរៀបចំដោយគីមីវិទូជនជាតិរុស្ស៊ីឈ្មោះឌីមេទ្រីមិនដេលេយេវ នៅឆ្នាំ1863 ហើយឱ្យឈ្មោះថា " តារាងខួបនៃធាតុគីមី " ។

### មេរៀនទី 1 : លក្ខណៈនៃតារាងខួប

### មេរៀនទី 2 : សិក្សាធាតុតាមក្រុម

មេរៀនទី

# 1 លក្ខណៈនៃតារាងខួប

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីរបៀបតម្រៀបធាតុគីមីក្នុងតារាងខួប ។
- ពណ៌នាពីលក្ខណៈសម្គាល់របស់ក្រុម និងខួប ។
- បង្ហាញទីតាំងលោហៈ អលោហៈ និងឧស្ម័នកម្រក្នុងតារាងខួប ។

## 1. អំបូរនៃធាតុគីមី

**តារាងខួប**នៃធាតុគីមី គឺជាតារាងចំណែកថ្នាក់នៃធាតុ ។ គេប្រើវាដើម្បីទាយទុកលក្ខណៈរបស់ធាតុ ។ បច្ចុប្បន្ននេះអ្នកវិទ្យាសាស្ត្របានស្គាល់ធាតុគីមីចំនួនជាងមួយរយហើយ ។ ចំនួនធាតុនេះមានការកើនឡើង ព្រោះមានអាតូមថ្មីៗបានបង្កើតឡើងដោយ**ប្រតិកម្មនុយក្លេអ៊ែ** ។ ធាតុគីមីជាច្រើន មានលក្ខណៈស្រដៀងគ្នា អាស្រ័យដោយលក្ខណៈរូប(ដូចជាៈភិនភាគខាងក្រៅ ភាពរូប **ដង់ស៊ីតេ** ពណ៌ ក្លិន ចំណុចរលាយ ចំណុចរំពុះ . . .) និងលក្ខណៈគីមី (ប្រតិកម្មជាមួយនឹងធាតុផ្សេងទៀត) ។ ការធ្វើចំណែកថ្នាក់ធាតុដោយផ្អែកលើលក្ខណៈរបស់វាបានបែងចែកធាតុទាំងនោះទៅជាអម្បូរគីមី ឬក្រុមនៃធាតុគីមី ។



លោក ***ឌីមេទ្រី មិនដេលេយេវ*** (រុស្ស៊ី) 1834-1907 ជាកូនពៅនៅក្នុងគ្រួសារដែលមានកូន 17 នាក់ ។ គាត់ជាអ្នកបង្កើតតារាងខួបមុនគេ ។

For MPTC-Ebooks Only




*រូបទី1 អម្បូរនៃធាតុគីមីក្នុងតារាងខួប*

ធាតុគីមីទាំងអស់ក្នុងតារាងខួបត្រូវបានរៀបចំតាមក្រុមឬអម្បូរនៃធាតុគីមី គឺៈ**លោហៈអាល់កាឡាំង លោហៈអាល់កាលីណូទែរ៉ឺលោហៈឆ្លង អាឡូសែននិងឧស្ម័នកម្រ** ។ នៅផ្នែកខាងក្រោមនៃតារាងមានធាតុពីរជួរដែលក្នុងមួយជួរៗមានធាតុគីមីចំនួន 15 ធាតុ ។ ធាតុទាំងអស់ដែលឋិតក្នុងជួរខាងលើមានលក្ខណៈស្រដៀងគ្នា នឹងធាតុឡង់តាន (La) មានលេខលំដាប់ 57 គេឱ្យឈ្មោះថា " **អម្បូរឡង់តានីត** " ។ ចំណែកធាតុនៅក្នុងជួរខាងក្រោមមានលក្ខណៈស្រដៀងគ្នានឹងធាតុអាក់ទីញ៉ូម(Ac) មានលេខលំដាប់ 89 គេឱ្យឈ្មោះថា " អម្បូរ**អាក់ទីនីត** " ។

## 2. ក្រុមនិងខួប

### 2.1 ជួរឈរឬក្រុម

នៅក្នុងតារាងខួបគេតម្រៀបធាតុគីមីតាមលំដាប់កើនឡើងនៃចំនួនប្រូតុង (លេខអាតូម) ដែលជាចំនួនប្រូតុងក្នុង**ណ្វៃយ៉ូ** នៃអាតូមនីមួយៗ ។ ជួរឈរឬបន្ទាត់ឈរក្នុងតារាងខួបហៅថា " **ក្រុម** " ។ លេខក្រុមគឺកំណត់ឱ្យចំនួនអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់របស់ធាតុ ។ ធាតុដែលឋិតនៅក្នុងក្រុមជាមួយគ្នាមានចំនួនអេឡិចត្រុងស្រទាប់ក្រៅដូចគ្នាហៅថា " **អេឡិចត្រុងវ៉ាឡង់** " ហើយមានលក្ខណៈគីមីស្រដៀងគ្នា ។ ធាតុគីមីទាំងអស់ក្នុងតារាងខួបចែកជាប្រាំបីក្រុមនិងក្រុមលោហៈឆ្លង ។

For MPTC-Ebooks Only

## 2.2 ជួរដេកឬខួប

នៅក្នុងតារាងខួបបន្ទាត់ដេកឬជួរដេកហៅថា “**ខួប** ” ។ តារាងនេះចែកជាប្រាំពីរខួប ហើយលេខលំដាប់ខួបសម្រាប់សម្គាល់ចំនួនស្រទាប់អេឡិចត្រុងរបស់ធាតុ ។ បើធាតុមួយឋិតនៅក្នុងខួបលេខ 3 មានន័យថាធាតុនោះមានបីស្រទាប់អេឡិចត្រុង ។ ធាតុគីមី ដែលស្ថិតនៅក្នុងខួបតែមួយដូចគ្នា មានចំនួនស្រទាប់អេឡិចត្រុងដូចគ្នា ហើយស្រទាប់ក្រៅបង្អស់បំពេញអេឡិចត្រុងជាបណ្ដើរៗរហូតដល់ផ្លែតអេឡិចត្រុង (8 អេឡិចត្រុង ) ។

***ឧទាហរណ៍ :*** ធាតុក្នុងខួបទី 3 បង្ហាញដូចខាងក្រោម :

| ខួបទី 3 | Na | Mg | Al | Si | P | S | Cl | Ar |
|---|---|---|---|---|---|---|---|---|
| ចំនួនប្រូតុង | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
| របាយអេឡិចត្រុង | 2,8,1 | 2,8,2 | 2,8,3 | 2,8,4 | 2,8,5 | 2,8,6 | 2,8,7 | 2,8,8 |
| ទម្រង់អ៊ីយ៉ុង | $Na^+$ | $Mg^{2+}$ | $Al^{3+}$ | ← កូវ៉ាឡង់ → | | | | |
| សកម្មភាព | សកម្ម ខ្លាំង | សកម្ម | សកម្ម ល្មម | មិនសកម្ម | សកម្ម ល្មម | សកម្ម | សកម្ម ខ្លាំង | និចល |
| ភាពចម្លងអគ្គិសនី | ល្អ | ល្អ | ល្អ | បង្គួរ | ខ្សោយ | ខ្សោយ | ខ្សោយ | ខ្សោយ |
| | លោហៈ | | | អលោហៈ | | | | |

ធាតុដែលស្ថិតនៅក្នុងខួបតែមួយមានលក្ខណៈប្រែប្រួលបន្តិចម្ដងៗពីលោហៈ (អ៊ីយ៉ុងវិជ្ជមាន) ទៅអលោហៈ (អ៊ីយ៉ុងអវិជ្ជមាន)ដោយឆ្លងកាត់ខួប ។

## 3. ទីតាំងលោហៈនិងអលោហៈក្នុងតារាងខួប

ធាតុគីមីទាំងអស់ក្នុងតារាងខួបចែកជា 2ក្រុម គឺក្រុម**លោហៈ** និងក្រុម**អលោហៈ**។ ក្រុមនីមួយៗមានលក្ខណៈសម្គាល់ផ្ទាល់របស់វា ។

For MPTC-Ebooks Only

## លក្ខណៈខុសគ្នារវាងលោហៈ និងអលោហៈ

| លោហៈ | អលោហៈ |
|---|---|
| • ជាអង្គធាតុរឹងនៅសីតុណ្ហភាពធម្មតា(លើកលែងបារត Hg ) | • ជាឧស្ម័ន (លើកលែងប្រូម $Br_{(l)}$ ស្ពាន់ធ័រ S(s) អ៊ីយ៉ូត I(s) កាបូន C(s) ប៊័រ B(s) ស៊ីលីស្យូម Si(s) ) |
| • ចំណុចរលាយ និងចំណុចរំពុះខ្ពស់(លើកលែងធាតុក្រុម I ) | • ចំណុចរលាយ និងចំណុចរំពុះទាប (លើកលែង B , C និង Si ) |
| • ចម្លងកម្តៅនិងអគ្គិសនីបានល្អ | |
| • មានផ្លេកលោហៈអាចផែជាសន្លឹក ឬហូតជាលួសបាននិងមានកម្លាំងខ្លាំងទប់នឹងតំណឹង | • ចម្លងកម្តៅនិងអគ្គិសនីខ្សោយ (លើកលែងកាបូន / ក្រាភីត ) |
| • ផ្តល់ឧស្ម័នអ៊ីដ្រូសែនពេលមានប្រតិកម្មជាមួយអាស៊ីតរាវ | • ស្រអាប់ ទន់ និងមិនអាចហូតជាលួស ឬផែជាសន្លឹកបាន |
| • ជាសមាសធាតុអ៊ីយ៉ុងភាគច្រើន | • មិនបង្កើតឧស្ម័នអ៊ីដ្រូសែនពេលមានប្រតិកម្មជាមួយអាស៊ីត |
| • ជាធម្មតាអុកស៊ីតរបស់វាជាអុកស៊ីតបាស ឬជាអុកស៊ីតអំផូទែ | • ជាសមាសធាតុកូវ៉ាឡង់ភាគច្រើន<br>• ជាធម្មតាអុកស៊ីតរបស់វាជាអុកស៊ីតអាស៊ីត ឬណឺត |
| • អ៊ីយ៉ុងមានបន្ទុកវិជ្ជមាន **(កាចុង)** | • អ៊ីយ៉ុងមានបន្ទុកអវិជ្ជមាន **(អាញ៉ុង)** |

នៅក្នុងតារាងខួបធាតុដែលនៅក្នុងថតពណ៌សជាលោហៈ ចំណែកធាតុដែលនៅក្នុងថតពណ៌ប្រផេះហើយដែលខណ្ឌចែកដាច់ពីគ្នាដោយបន្ទាត់កាច់ពណ៌ខ្មៅជិតរាងថ្នាក់ៗដូចកាំជណ្តើរជាអលោហៈ(រូបទី2) ។ មានធាតុមួយចំនួនដូចជាស៊ីលីស្យូម (Si) សែម៉ាញ៉ូម (Ge) មានលក្ខណៈទ្វេដែលជាលោហៈផង និងជាអលោហៈផងហៅថា ធាតុអំផូទែ (metalloids) ។

For MPTC-Ebooks Only

| **លោហៈក្រុម I និង II** | **ធាតុអំផូទែ** (metalloids) | **អលោហៈ** |
|---|---|---|
| ក្រុម I លោហៈអាល់កាឡាំង ក្រុម II លោហៈអាល់កាលីណូទែរី វាជាលោហៈសកម្ម ហើយសកម្មភាពរបស់វាកើនឡើងពីលើចុះក្រោម | ធាតុទាំងនេះនៅជិតបន្ទាត់ជិតខ្មៅរាងកាំជណ្ដើរមានលក្ខណៈជាលោហៈ និងជាអលោហៈ ។ ធាតុនៅក្រោមបន្ទាត់ជិតខ្មៅជាលោហៈខ្សោយដូចជា : សំណប៉ាហាំង (Sn) និងសំណ (Pb) | ច្រើនជាឧស្ម័ន (លើកលែងតែប្រូម Br(l) ) ផូស្វ័រ P(s) ស្ពាន់ធ័រ S(s) កាបូន C(s) ប៊័រ B(s) សេលេញ៉ូម Se(s) មានចំណុចរលាយទាប ។ |




***រូបទី 2 : ទីតាំងលោហៈ និងអលោហៈក្នុងតារាងខួប***

## លោហៈឆ្លង

លោហៈទាំង 30 ដែលឋិតនៅផ្នែកកណ្ដាលនៃតារាងខួបហៅថា **លោហៈឆ្លង** ។ វាមិនមានសកម្មភាពខ្លាំងទេ ហើយសមាសធាតុដែលកើតឡើងពីវាមានពណ៌សម្គាល់ ។ លក្ខណៈនេះអាចយកទៅប្រើដើម្បីធ្វើអត្តសញ្ញាណអ៊ីយ៉ុងលោហៈឆ្លងបាន ។

***ឧទាហរណ៍ :*** នៅក្នុងករណីភាគច្រើនសមាសធាតុទង់ដែង (II) មានពណ៌ខៀវ សមាសធាតុដែក (II) មានពណ៌បៃតងខ្ចី សមាសធាតុដែក (III) មានពណ៌លឿង សមាសធាតុម៉ង់កាណាត (VII) មានពណ៌ស្វាយ និងសមាសធាតុឌីក្រូម៉ាត (VI) មានពណ៌ទឹកក្រូច ។

លោហៈឆ្លងទាំងអស់មានលក្ខណៈរឹងខ្លាំង ចម្លងកម្ដៅនិងអគ្គិសនីបានល្អហើយមានចំណុចរំពុះខ្ពស់ ។ លោហៈឆ្លងជាច្រើនមាន **ចំនួនអុកស៊ីតកម្ម** ប្រែប្រួល ។

***ឧទាហរណ៍ :*** ទង់ដែង (I) $Cu^{+}$ និងទង់ដែង (II) $Cu^{2+}$ ដែក (II) $Fe^{2+}$ និងដែក (III) $Fe^{3+}$ … ។ គេប្រើលោហៈឆ្លង និងសមាធាតុរបស់វាជា **កាតាលីករ** ដើម្បីបង្កើនល្បឿនប្រតិកម្មនៅក្នុងឧស្សាហកម្ម ។

***ឧទាហរណ៍ :*** លោហៈដែកក្នុង**លំនាំហាបើ** Haber process (ផលិតកម្មអាម៉ូញ៉ាក់) និងប្លាទីន Pt ឬវ៉ាណាដ្យូម (V) អុកស៊ីតក្នុងលំនាំផលិតកម្មអាស៊ីតស៊ុលផួរិច ។

# លក្ខណៈរបស់ធាតុមួយចំនួននៅក្នុងតារាងខួប

| ធាតុពិសេស | | ធាតុនិងនិមិត្តសញ្ញា | ភាពរូប | ចំណុចរលាយ (°C) | ចំណុចរំពុះ (°C) | ដង់ស៊ីតេ $g/cm^3$ |
|---|---|---|---|---|---|---|
| លីចូម (Li) លោហៈស្រាលបំផុត<br>ដង់ស៊ីតេ : $0.53 g \cdot cm^{-3}$<br>អូសម៉្យូម (Os) លោហៈធ្ងន់បំផុត<br>ដង់ស៊ីតេ : $22.48 g \cdot cm^{-3}$<br>បារត (Hg) ចំណុចរលាយទាបបំផុត $-38.9°C$<br>តង់ស្តែន : ចំណុចរលាយខ្ពស់បំផុត $+3410°C$ | លោហៈ | អាលុយមីញ៉ូម Al | រឹង | 660 | 2470 | 2.7 |
| | | ទង់ដែង Cu | រឹង | 1083 | 2595 | 8.9 |
| | | មាស Au | រឹង | 1063 | 2970 | 19.3 |
| | | ដែក Fe | រឹង | 1535 | 3000 | 7.9 |
| | | សំណ Pb | រឹង | 327 | 1744 | 11.3 |
| | | ម៉ាញេស្យូម Mg | រឹង | 650 | 1110 | 1.7 |
| | | បារត Hg | រាវ | –39 | 357 | 13.6 |
| | | នីកែល Ni | រឹង | 1453 | 2730 | 8.9 |
| | | ប្រាក់ Ag | រឹង | 961 | 2210 | 10.5 |
| | | សំណប៉ាហាំង Sn | រឹង | 232 | 2270 | 7.3 |
| | | សង្កសី Zn | រឹង | 420 | 907 | 7.1 |
| អ៊ីដ្រូសែន (H) ឧស្ម័នស្រាលបំផុត<br>ដង់ស៊ីតេ : $0.08988 g \cdot L^{-1}$<br>រ៉ាដុង : (Rn) ឧស្ម័នធ្ងន់បំផុត<br>ដង់ស៊ីតេ : 111.5 ដងនៃទំងន់អ៊ីដ្រូសែន<br>អេល្យូម (He) ឧស្ម័នមានចំណុចរំពុះទាបបំផុត : $-268.9°C$<br>ក្លរ (Cl) : ឧស្ម័នមានចំណុចរំពុះខ្ពស់បំផុត : $-34.1°C$ | អលោហៈ | ប្រូម Br | រាវ | –7 | 59 | 3.1 |
| | | កាបូន C | រឹង | 3730 | 4830 | 2.3 |
| | | ក្លរ Cl | ឧស្ម័ន | –101 | –35 | 0.3 |
| | | អ៊ីដ្រូសែន H | ឧស្ម័ន | –259 | –252 | 0.009 |
| | | អ៊ីយ៉ូត I | រឹង | 184 | 184 | 4.9 |
| | | អាសូត N | ឧស្ម័ន | –210 | –196 | 0.1 |
| | | អុកស៊ីសែន O | ឧស្ម័ន | –218 | –183 | 0.1 |
| | | ផូស្វ័រ P | រឹង | 44 | 280 | 1.8 |
| | | ស៊ីលីស្យូម Si | រឹង | 1410 | 2360 | 2.3 |
| | | ស្ពាន់ធ័រ S | រឹង | 113 | 444 | 2.0 |

For MPTC-Ebooks Only

## មេរៀនសង្ខេប

- នៅក្នុងតារាងខួបគេតម្រៀបធាតុគីមីតាមលំដាប់កើនឡើងនៃចំនួនប្រូតុង ។
- ជួរឈរនៅក្នុងតារាងខួបហៅថា " ក្រុម " ហើយលេខលំដាប់ក្រុមសម្គាល់ឱ្យចំនួន អេឡិចត្រុងវ៉ាឡង់របស់ធាតុ ។
- ជួរដេកនៅក្នុងតារាងខួបហៅថា "ខួប " ហើយលេខលំដាប់ខួបសម្រាប់កំណត់ចំនួនស្រទាប់អេឡិចត្រុងរបស់ធាតុ ។
- ធាតុគីមីទាំងអស់នៅក្នុងតារាងខួបត្រូវបានរៀបចំឡើងទៅតាមអម្បូរនៃធាតុគីមី : ក្រុមលោហៈអាល់កាឡាំង លោហៈអាល់កាលីណូទែរី ឧស្ម័នកម្រ ក្រុមលោហៈឆ្លង . . . ។

## សំណួរនិងលំហាត់

1. ចូរបង្ហាញពីភាពខុសគ្នារវាងក្រុមនិងខួបនៃធាតុ ។
2. នៅក្នុងតារាងខួប តើឧស្ម័នកម្រស្ថិតនៅផ្នែកខាងណា ?
3. តើលោហៈនិងអលោហៈស្ថិតនៅត្រង់ណាក្នុងតារាងខួប ?
4. តើទីតាំងត្រង់ណាក្នុងតារាងខួបដែលគេសម្គាល់ឃើញមានលោហៈសកម្មច្រើន ?
5. ចូររៀបរាប់លក្ខណៈខុសគ្នារវាងលោហៈនិងអលោហៈ ។
6. តើធាតុអំផូទែមានលក្ខណៈដូចម្តេច ?
7. ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវ ។ ខួបនៃធាតុនៅក្នុងតារាងខួបគឺ :
   - ☐ ក. ជាបញ្ជីនៃលោហៈតាមលំដាប់នៃសកម្មភាព
   - ☐ ខ. ជាជួរឈរនៃធាតុ
   - ☐ គ. ជាជួរដេកនៃធាតុ
   - ☐ ឃ. មានចំនួនអេឡិចត្រុងដូចគ្នានៅស្រទាប់ក្រៅបង្អស់ ។
8. ក្នុងតារាងខួប គេរៀបធាតុគីមីយ៉ាងដូចម្តេច ?
9. ដូចម្តេចហៅថាក្រុម ?
10. ដូចម្តេចហៅថាខួប ?

for MPTC-Ebooks Only

11. គេចែកធាតុគីមីជាប៉ុន្មានក្រុម ? គឺក្រុមអ្វីខ្លះ ?
12. អម្បូរឡង់តានីតនិងអាក់ទីនីតមានទីតាំងត្រង់ណាក្នុងតារាងខួប ?
13. ដូចម្ដេចហៅថា អេឡិចត្រុងវ៉ាឡង់ ?
14. សូដ្យូមមានលេខអាតូម 11 ។ ចូរសរសេររបាយអេឡិចត្រុងរបស់វា ។
15. ក្លរមានលេខអាតូម 17 ។ ចូរសរសេររបាយអេឡិចត្រុងរបស់វា ។
16. ដូចម្ដេចហៅថា ធាតុអំផូទែ ?
17. តើលោហៈឆ្លងណាមួយដែលគេប្រើជាកាតាលីករក្នុងលំនាំ ហេប៊ឺ ?

For MPTC-Ebooks Only

មេរៀនទី

# 2 សិក្សាធាតុតាមក្រុម

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពណ៌នាលក្ខណៈរូប លក្ខណៈគីមីរបស់លោហៈអាល់កាឡាំង ក្រុមអាឡូសែននិងក្រុមឧស្ម័នកម្រ ។
- ❒ បង្ហាញពីលក្ខណៈ ទីតាំង និងបម្រែបម្រួលរបស់ក្រុមលោហៈឆ្លងពន្យល់ពីទំនាក់ទំនង រវាងទ្រឹស្តីអាតូមរបស់ដាល់តុនទៅនឹងច្បាប់ទាំងបីខាងលើ ។
- ❒ ពណ៌នាពីភាពស្រដៀងគ្នានៃរូបមន្តគីមី ៖ រូបមន្តអុកស៊ីត អ៊ីដ្រុកស៊ីត នីត្រាត ស៊ុលផាត កាបូណាត និងក្លរួ ។

តារាងដែលយើងឃើញនៅក្នុងបន្ទប់គីមីហៅថា "**តារាងខួបនៃធាតុគីមី**" ។ តាមរយៈតារាងនេះ យើងអាចស្គាល់និមិត្តសញ្ញា ឈ្មោះ លក្ខណៈព្រមទាំងទម្រង់អាតូមរបស់ធាតុ ។ តារាងនេះមាន 8ក្រុម ធាតុគីមី និងក្រុមលោហៈឆ្លង ហើយយើងនឹងលើកយកមកសិក្សាលំអិតធាតុ 4ក្រុមគឺ ៖ ក្រុម I លោហៈអាល់កាឡាំង ក្រុមVII អាឡូសែន ក្រុមVIII ឧស្ម័នកម្រ និងក្រុមលោហៈឆ្លង ។

## 1. ក្រុម I លោហៈអាល់កាឡាំង

ក្រុម **លោហៈអាល់កាឡាំង** ស្ថិតនៅជួរឈរទីមួយផ្នែក ក្រុមI ខាងឆ្វេងនៃតារាងខួប ។ លោហៈអាល់កាឡាំងមាន 6ធាតុគឺ ៖ លីចូម (Li) សូដ្យូម (Na) ប៉ូតាស្យូម (K) រុយប៊ីដ្យូម (Rb) សេស្យូម (Cs) និងប្រង់ស្យូម (Fr) ។




*រូបទី1 ៖ ទីតាំងលោហៈអាល់កាឡាំងក្នុងតារាងខួប*

### 1.1 លក្ខណៈរូប

លោហៈអាល់កាឡាំងមានលក្ខណៈដូចខាងក្រោម ៖

- ជាលោហៈសកម្មខ្លាំង
- ចម្លងកម្តៅនិងអគ្គិសនីបានល្អ
- ទន់ជាងលោហៈដទៃទៀតហើយអាចកាត់ ឬចិតនឹងកាំបិតបាន

For MPTC-Ebooks Only

- ស្រាលជាងលោហៈដទៃទៀត មានដង់ស៊ីតេ និងចំណុចរលាយទាប ។ លោហៈបីខាងលើ Li Na K អណ្តែតលើទឹក ហើយមានប្រតិកម្មជាមួយទឹកយ៉ាងខ្លាំងក្លា គេរក្សាវាដោយត្រាំនៅក្នុងប្រេងកាត ។ រុយប៊ីដ្យូម និងសេស្យូម គឺជាធាតុដែលមានគ្រោះថ្នាក់ ។ ប្រសិនបើគេដាក់វានៅក្នុងកែវដែលមានទឹក នោះប្រតិកម្មខ្លាំងក្លាមួយនឹងកើតមានឡើង ដែលធ្វើឱ្យកែវបែកខ្ចាយ ។ ចំណែកប្រង់ស្យូមគឺជាធាតុដែលមានគ្រោះថ្នាក់បំផុត វាជា**ធាតុវិទ្យុសកម្ម** ។ ដូចនេះធាតុ Rb និង Cs កម្រឃើញមាននៅទីពិសោធន៍ណាស់ ។

**តារាងលក្ខណៈរូបលោហៈអាល់កាឡាំង**

| ឈ្មោះធាតុ | និមិត្តសញ្ញា | អាការៈខាងក្រៅ(ពណ៌) | ចំណុចរលាយ °C | ដង់ស៊ីតេ $g.cm^{-3}$ |
|---|---|---|---|---|
| លីចូម | Li | ទន់ ពណ៌ប្រផេះ | 181 | 0.54 |
| សូដ្យូម | Na | ទន់ ពណ៌ប្រផេះស្រាល | 97 | 0.97 |
| ប៉ូតាស្យូម | K | ទន់ ពណ៌ខៀវ/ប្រផេះ | 63 | 0.86 |
| រុយប៊ីដ្យូម | Rb | ពណ៌សប្រាក់ | 39 | 1.53 |
| សេស្យូម | Cs | ពណ៌សប្រាក់ | 29 | 1.90 |

## 1.2 លក្ខណៈគីមី

លោហៈអាល់កាឡាំងជាលោហៈសកម្មខ្លាំងហើយសកម្មភាពនេះកើនឡើងពីលើចុះក្រោម ព្រោះកាលណាអាតូមកាន់តែធំស្រទាប់អេឡិចត្រុងកាន់តែកើនហើយកម្លាំងទំនាញពីណ្វៃយ៉ូទៅ **អេឡិចត្រុង** កាន់តែខ្សោយធ្វើឱ្យវាងាយផ្តាច់អេឡិចត្រុងវ៉ាឡង់ទោលនៅស្រទាប់ក្រៅបង្អស់ក្លាយទៅជាអ៊ីយ៉ុងវិជ្ជមាន ។លោហៈអាល់កាឡាំងទាំងអស់បង្កើតជាអ៊ីយ៉ុងវិជ្ជមាន$M^+$ ($Li^+$ , $Na^+$ , $K^+$ , $Rb^+$ , $Cs^+$ ) ។



### ក. ប្រតិកម្មជាមួយទឹក

លោហៈអាល់កាឡាំងមានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយទឹកឱ្យផលជាអ៊ីដ្រូសែននិងសូលុយស្យុង អ៊ីដ្រុកស៊ីត ( ជាបាសអាល់កាលីដែលអាចប្រែពណ៌អង្គធាតុចង្អុលពណ៌ )។

*ឧទាហរណ៍ :*

សូដ្យូម + ទឹក ⟶ សូដ្យូមអ៊ីដ្រុកស៊ីត + អ៊ីដ្រូសែន

$$2Na(s) + 2H_2O(l) \longrightarrow 2NaOH(aq) + H_2(g)$$

### ខ. ប្រតិកម្មជាមួយអលោហៈ

លោហៈអាល់កាឡាំងជាលោហៈសកម្ម វាអាចចូលផ្សំដោយផ្ទាល់ជាមួយអលោហៈសកម្មដូចជា អាឡូសែន ។

• **ប្រតិកម្មជាមួយក្លរ ($Cl_2$)**

កាលណាគេដាក់លោហៈសូដ្យូមដែលដុតកម្តៅទៅក្នុងឧស្ម័នក្លរនោះ គេឃើញមានអណ្តាតភ្លើង ភ្លឺកើតឡើង ។ លោហៈនេះឆេះដោយបញ្ចេញពន្លឺ និងផ្សែងពណ៌សយ៉ាងខ្លាំងហើយមានកកើតអង្គធាតុ រឹងពណ៌សហៅថា : សូដ្យូមក្លរួ (អំបិលសំល) ។

សូដ្យូម + ក្លរ ⟶ សូដ្យូមក្លរួ

$$2Na(s) + Cl_2(g) \longrightarrow 2NaCl(s)$$

• **ប្រតិកម្មជាមួយអុកស៊ីសែន ($O_2$)**

លោហៈអាល់កាឡាំងមានប្រតិកម្មខ្លាំងក្លាជាមួយខ្យល់ ឬអុកស៊ីសែនឱ្យជាអង្គធាតុរឹងពណ៌ស ហៅថា “ **អុកស៊ីត** ” ។ លោហៈអាល់កាឡាំងឆេះឱ្យជាអណ្តាតភ្លើងមានពណ៌ផ្សេងៗគ្នា ។

### តារាងបង្ហាញពីពណ៌អណ្តាតភ្លើងលោហៈអាល់កាឡាំង

| លោហៈអាល់កាឡាំង | ពណ៌អណ្តាតភ្លើង |
|---|---|
| លីចូម (Li) | ពណ៌ ក្រហម |
| សូដ្យូម (Na) | ពណ៌ លឿង |
| ប៉ូតាស្យូម (K) | ពណ៌ផ្កាឈូក - ស្វាយ |
| រូប៊ីដ្យូម (Rb) | ពណ៌ផ្កាឈូក - ស្វាយ |

For MPTC-Ebooks Only

# តារាងសង្ខេបប្រតិកម្មលោហៈអាល់កាឡាំង

| អាល់កាឡាំង | ប្រតិកម្មជាមួយខ្យល់(អុកស៊ីសែន) | ប្រតិកម្មជាមួយទឹក ($H_2O$) | ប្រតិកម្មជាមួយក្លរ ($Cl_2$) |
|---|---|---|---|
| លីចូម (Li) | ឆេះឲ្យជាអណ្ដាតភ្លើងពណ៌ក្រហមឲ្យលីចូមអុកស៊ីតដែលជាអង្គធាតុរឹងពណ៌ស $4Li(s) + O_2(g) \rightarrow 2Li_2O(s)$ | ប្រតិកម្មខ្លាំងក្លា អណ្ដែតលើទឹក ឲ្យផលជាលីចូមអ៊ីដ្រុកស៊ីតនិងឧស្ម័នអ៊ីដ្រូសែន $2Li(s) + 2H_2O(l) \rightarrow 2LiOH(aq) + H_2(g)$ | ឆេះឲ្យអណ្ដាតភ្លើងភ្លឺឲ្យផលជាអង្គធាតុរឹងពណ៌ស គឺលីចូមក្លរួ $2Li(s) + Cl_2(g) \rightarrow 2LiCl(s)$ |
| សូដ្យូម (Na) | ឆេះឲ្យជាអណ្ដាតភ្លើងលឿងភ្លឺឲ្យផលជាសូដ្យូមអុកស៊ីតពណ៌ស $4Na(s) + O_2(g) \rightarrow 2Na_2O(s)$ | អណ្ដែតលើទឹក និងប្រតិកម្មយ៉ាងរហ័ស ឲ្យផលជាសូដ្យូមអ៊ីដ្រុកស៊ីតនិងឧស្ម័នអ៊ីដ្រូសែន $2Na(s) + 2H_2O(l) \rightarrow 2NaOH(aq) + H_2(g)$ | ឆេះឲ្យអណ្ដាតភ្លើងភ្លឺ ឲ្យផលជាអង្គធាតុរឹងពណ៌ស គឺសូដ្យូមក្លរួ $2Na(s) + Cl_2(g) \rightarrow 2NaCl(s)$ |
| ប៉ូតាស្យូម (K) | ឆេះខ្លាំងក្លាឲ្យជាអណ្ដាតភ្លើងពណ៌ផ្កាឈូកស្វាយ ឲ្យផលជាប៉ូតាស្យូមអុកស៊ីត $4K(s) + O_2(g) \rightarrow 2K_2O(s)$ | អណ្ដែតលើទឹកមានប្រតិកម្មខ្លាំងក្លា(ផ្ទុះ)ឲ្យផលជាប៉ូតាស្យូមអ៊ីដ្រុកស៊ីត និងឧស្ម័នអ៊ីដ្រូសែន $2K(s) + 2H_2O(l) \rightarrow 2KOH(aq) + H_2(g)$ | ឆេះយ៉ាងខ្លាំងក្លាឲ្យអណ្ដាតភ្លើងភ្លឺ និងអោយផលជាអង្គធាតុរឹងពណ៌ស គឺប៉ូតាស្យូមក្លរួ $2K(s) + Cl_2(g) \rightarrow 2KCl(s)$ |

**សម្គាល់** : រឹង (s) , រាវ (l) , ឧស្ម័ន (g) , សូលុយស្យុងរាវ (aq)

For MPTC-Ebooks Only

# 2. ក្រុម VII : ក្រុមអាឡូសែន

ធាតុនៅក្នុងក្រុម VII នេះសុទ្ធតែជាអលោហៈមានធាតុ : ភ្លុយអរ (F) ក្លរ (Cl) ប្រូម (Br) និង អ៊ីយ៉ូត (I) វាជាអលោហៈសកម្មខ្លាំង ។ គេឱ្យឈ្មោះធាតុនៅក្នុងក្រុម VII នេះជា **ក្រុមអាឡូសែន** ព្រោះធាតុទាំងអស់នៅក្នុងក្រុមនេះមានប្រតិកម្មជាមួយលោហៈភាគច្រើនឱ្យជាអំបិល ។ អាឡូសែនជាពាក្យក្រិចមានន័យថា "អ្នកបង្កើតអំបិល" ។ សកម្មភាពគីមីរបស់ធាតុក្នុងក្រុម VII ថយចុះពីលើចុះក្រោម នេះបណ្ដាលមកពីទំហំអាតូមកាន់តែធំ ហើយស្រទាប់អេឡិចត្រុងកាន់តែកើនធ្វើឱ្យណ្វៃយ៉ូរបស់វាពិបាកទាញយកអេឡិចត្រុងដើម្បីក្លាយជា **អ៊ីយ៉ុង** ។ អ៊ីយ៉ុង អាឡូសែនទាំងអស់មានបន្ទុកអវិជ្ជមាន –1 ($F^-$ , $Cl^-$ , $Br^-$ និង $I^-$ ) ហើយម៉ូលេគុលរបស់វានីមួយៗមាន 2 អាតូម (ឌីអាតូម) $F_2$, $Cl_2$, $Br_2$ និង $I_2$ ។




*រូបទី2 : ទីតាំងរបស់ធាតុគីមីក្រុមVII (អាឡូសែន)នៅក្នុងតារាងខួប*

## 2.1 លក្ខណៈរូប

ធាតុទាំងអស់នៅក្នុងក្រុមអាឡូសែនសុទ្ធតែជាអលោហៈដែលក្នុងនោះភ្លុយអរ និងក្លរជាឧស្ម័ន ប្រូមជាអង្គធាតុរាវហើយអ៊ីយ៉ូតជាអង្គធាតុរឹង (មើលតារាងខាងក្រោម) ។ ធាតុក្នុងក្រុមអាឡូសែនទាំងអស់ជាធាតុពុល ដូចនេះយើងត្រូវប្រុងប្រយ័ត្ននៅពេលធ្វើពិសោធន៍ ។

### តារាងលក្ខណៈរូបរបស់អាឡូសែន

| ឈ្មោះ | ម៉ូលេគុល | អាការៈខាងក្រៅ(ពណ៌) | ចំណុចរលាយ °C | ចំណុចរំពុះ °C | ភាពរូប |
|---|---|---|---|---|---|
| ភ្លុយអរ | $F_2$ | ពណ៌លឿងព្រលែត | –220 | –188 | ឧស្ម័ន |
| ក្លរ | $Cl_2$ | ពណ៌ត្រួយចេក | –101 | –35 | ឧស្ម័ន |
| ប្រូម | $Br_2$ | ពណ៌ក្រហមត្នោត | –7 | 59 | រាវ |
| អ៊ីយ៉ូត | $I_2$ | ពណ៌ស្វាយ | 114 | 184 | រឹង |

For MPTC-Ebooks Only

- **ក្លរ** ($Cl_2$) ៖ ជាឧស្ម័នពណ៌ត្រួយចេកមានម៉ូលេគុលឌីអាតូម ។ នៅក្នុងភាពរូបជាឧស្ម័នម៉ូលេគុលរបស់វាតាំងនៅឆ្ងាយពីគ្នា និងធ្វើចលនាដោយល្បឿនលឿន ។




- **ប្រូម** ($Br_2$) ៖ ជាអង្គធាតុរាវពណ៌ក្រហមត្នោតងាយហើរ មានចំណុចរំពុះទាប 59°C ហើយងាយក្លាយទៅជាចំហាយ ។




- **អ៊ីយ៉ូត** ($I_2$) ៖ ជាអង្គធាតុរឹងពណ៌ស្វាយ ។ ម៉ូលេគុលឌីអាតូមរបស់អ៊ីយ៉ូតភ្ជាប់គ្នាទៅវិញទៅមកនិងការតម្រៀបទៀងទាត់ ។ បើគេដុតកម្តៅ អ៊ីយ៉ូតប្លែងដោយផ្ទាល់ទៅជាចំហាយពណ៌ស្វាយដោយមិនឆ្លងកាត់ភាពរាវ ។ អាតូមទាំងពីររបស់ម៉ូលេគុលអាឡូសែនចងភ្ជាប់គ្នាដោយសម្ព័ន្ធកូវ៉ាឡង់ ប៉ុន្តែកម្លាំងចន្លោះម៉ូលេគុលវាខ្សោយណាស់ ដូចនេះចំណុចរលាយ និងចំណុចរំពុះរបស់ធាតុទាំងនេះទាប (ក្រោម 200°C ) ។




## 2.2 លក្ខណៈគីមី

### ក. ប្រតិកម្មជាមួយលោហៈ

អាឡូសែនទាំងអស់មានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយលោហៈបង្កើតបានជាអំបិល ។

***ឧទាហរណ៍ ៖*** សូដ្យូមឆេះក្នុងក្លរដោយបញ្ចេញអណ្តាតភ្លើងភ្លឺ ៖

$$\text{សូដ្យូម} + \text{ក្លរ} \longrightarrow \text{សូដ្យូមក្លរួ}$$

$$2Na(s) + Cl_2(g) \longrightarrow 2NaCl(s)$$

ភាពសកម្មរបស់អាឡូសែនថយចុះពីលើចុះក្រោមគឺ ប្រូមខ្សោយជាងក្លរ ហើយអ៊ីយ៉ូតខ្សោយជាងប្រូម ។

For MPTC-Ebooks Only

## ២. ប្រតិកម្មជំនួស

អាឡូសែនដែលសកម្មខ្លាំងអាចជំនួសអាឡូសែនដែលមិនសូវសកម្មពីសូលុយស្យុងអំបិលរបស់វាបាន ។

*ឧទាហរណ៍ :* ក្លរអាចជំនួសអ៊ីយ៉ូតពីសូលុយស្យុងប៉ូតាស្យូមអ៊ីយ៉ូឌួបាន :

ក្លរ + ប៉ូតាស្យូមអ៊ីយ៉ូឌួ ⟶ ប៉ូតាស្យូមក្លរួ + អ៊ីយ៉ូត

$$Cl_2(g) + 2KI(aq) \longrightarrow 2KCl(aq) + I_2(s)$$

ប្រតិកម្មរបស់អាឡូសែននេះជាប្រតិកម្មរេដុក ។នៅពេលក្លរជំនួសអ៊ីយ៉ូតក្នុងប្រតិកម្មខាងលើ អាតូមក្លរចំណេញអេឡិចត្រុងមួយដើម្បីក្លាយជាអ៊ីយ៉ុងក្លរ ។ ចំណែកអ៊ីយ៉ុងអ៊ីយ៉ូតបាត់អេឡិចត្រុងមួយដើម្បីក្លាយជាអាតូមអ៊ីយ៉ូត ។ អ៊ីយ៉ុងអ៊ីយ៉ូតរងអុកស៊ីតកម្ម ។

$$Cl_2(g) + 2I^-(aq) \longrightarrow 2Cl^-(aq) + I_2(s)$$

អាតូមក្លរតូចជាងអាតូមអ៊ីយ៉ូត ។ ដូចនេះអាតូមក្លរប្រទាញយកអេឡិចត្រុងបានខ្លាំងជាងអាតូមអ៊ីយ៉ូត នេះបញ្ជាក់ថាអាតូមក្លរជាភ្នាក់ងារ**អុកស៊ីតកម្ម** (អុកស៊ីតករ) ខ្លាំងជាងអាតូមអ៊ីយ៉ូត ។

# 3. ក្រុម VIII : ឧស្ម័នកម្រ

## 3.1 លក្ខណៈទូទៅ

ក្រុម VIII (ឧស្ម័នកម្រ)ឋិតនៅជួរឈរផ្នែកខាងស្តាំនៃតារាងខួប ។ ធាតុទាំងអស់នៅក្នុងក្រុមនេះសុទ្ធតែជាឧស្ម័នអសកម្មឬធាតុគីមីនិចលគេឱ្យឈ្មោះថាឧស្ម័នកម្រ ។ វាជាឧស្ម័នម៉ូណូអាតូម (អាតូមមួយ) ហើយមានចំណុចរលាយនិងចំណុចរំពុះទាប ។និចលភាពនេះដោយសារតែស្រទាប់ក្រៅបំផុតនៃធាតុត្រូវបំពេញ 8 អេឡិចត្រុងលើកលែងតែអេល្យូម ។ ឧស្ម័នទាំងនេះមិនមានទំនោរចូលផ្សំជាមួយធាតុផ្សេងទៀត ដើម្បីបង្កើត**សមាសធាតុអ៊ីយ៉ុង** ឬ**សមាសធាតុកូវ៉ាឡង់**ទេ ។ ដូចនេះវាមានលក្ខណៈអសកម្មហើយស្ថិតក្នុងភាពជាអាតូមទោលឬហៅថាៈ ម៉ូណូអាតូម ។ ឧស្ម័នទាំងអស់នៅក្នុងក្រុម VIII ជាឧស្ម័នគ្មានពណ៌ ហើយវាមានចំណុចរលាយនិងចំណុចរំពុះទាប ។




*រូបទី3 : ទីតាំងឧស្ម័នកម្រក្នុងតារាងខួប*

For MPTC-Ebooks Only

# តារាងលក្ខណៈរូបរបស់ឧស្ម័នកម្រ

| ឈ្មោះ | និមិត្តសញ្ញា | ចំណុចរលាយ (°C) | ចំណុចរំពុះ (°C) | បម្រើបម្រាស់ |
|---|---|---|---|---|
| អេល្យូម | He | –270 | –269 | យានអវកាស បាល់ឡុងអាកាស |
| នេអុង | Ne | –249 | –246 | អំពូលភ្លើងផ្សាយពាណិជ្ជកម្ម |
| អាកុង | Ar | –189 | –186 | ឧស្ម័ននិចលក្នុងអំពូលភ្លើងមូល |
| គ្រីបតុង | Kr | –157 | –153 | ឧស្ម័នសម្រាប់បំពេញបរិក្ខាអេឡិចត្រូនិចនិងឡាស៊ែរ |
| សេណុង | Xe | –112 | –109 | ឧបករណ៍បញ្ចេញពន្លឺរបស់កាំភ្លើង |
| រ៉ាដុង | Rn | –71 | –62 | ឧស្ម័នវិទ្យុសកម្មធម្មជាតិ |

## 3.2 បម្រើបម្រាស់

អេល្យូម នេអុង និងអាកុងជាឧស្ម័នកម្រដែលគេនិយមប្រើជាងគេ ។ គេប្រើអាកុងនៅក្នុងអំពូលភ្លើងមូលព្រោះសរសៃតង់ស្តែននៃអំពូលភ្លើងមិនមានអំពើជាមួយវាទេ ។ ប្រសិនបើគេប្រើខ្យល់ជំនួសវិញនោះ សរសៃលោហៈក្តៅនឹងមានប្រតិកម្មជាមួយអុកស៊ីសែននៅក្នុងខ្យល់ ។ ហេតុនេះហើយបានជាគេប្រើអាកុងនៅក្នុងឧស្សាហកម្មដែកថែប ដោយសារតែវាគ្មានអំពើជាមួយដែករលាយ ។

នេអុងប្រើនៅក្នុងអំពូលភ្លើងផ្សាយពាណិជ្ជកម្ម ។អេល្យូមគេប្រើក្នុងបាឡុងតូចៗនិងយានអវកាសទំនើប ព្រោះវាមានដង់ស៊ីតេទាប ។



នាវាអវកាស



អំពូលភ្លើងផ្សាយពាណិជ្ជកម្ម



អំពូលភ្លើងមូល

*រូបទី4 : ការប្រើឧស្ម័នកម្រក្នុងជីវភាព*

# 4. ក្រុមលោហៈឆ្លង

លោហៈឆ្លងគឺជាក្រុមលោហៈដែលឋិតនៅក្នុងផ្នែកកណ្ដាលនៃតារាងខួប ។ធាតុទាំងអស់នៅក្នុងក្រុមនេះមានលក្ខណៈស្រដៀងគ្នា ។




*រូបទី5 : ទីតាំងលោហៈឆ្លងក្នុងតារាងខួប*

## 4.1 លក្ខណៈរូប

លោហៈឆ្លងមានដង់ស៊ីតេ និងចំណុចរលាយខ្ពស់ធៀបនឹងលោហៈដទៃទៀត ។

**តារាងប្រៀបធៀបលក្ខណៈរូបលោហៈឆ្លង និងលោហៈដទៃ**

| លោហៈឆ្លង | | | លោហៈដទៃទៀត | | |
|---|---|---|---|---|---|
| លោហៈ | ដង់ស៊ីតេ $g/cm^3$ | ចំណុចរលាយ (°C) | លោហៈ | ដង់ស៊ីតេ $g/cm^3$ | ចំណុចរលាយ (°C) |
| ក្រូម (Cr) | 7.2 | 1857 | សូដ្យូម (Na) | 0.97 | 98 |
| ដែក (Fe) | 7.9 | 1535 | ម៉ាញេស្យូម (Mg) | 1.7 | 650 |
| នីកែល (Ni) | 8.9 | 1453 | អាលុយមីញ៉ូម (Al) | 2.7 | 660 |
| ទង់ដែង (Cu) | 8.9 | 1083 | កាល់ស្យូម (Ca) | 1.5 | 840 |

- លោហៈឆ្លងជាលោហៈរឹង ស្វិត មាំ និងភ្លឺ យើងមិនអាចកាត់វានឹងកាំបិតដូចលោហៈអាល់កាឡាំងបានទេ ។
- ចំណុចរលាយខ្ពស់ លើកលែងបារតចេញដែលជាអង្គធាតុរាវនៅសីតុណ្ហភាពបន្ទប់វារលាយនៅសីតុណ្ហភាព –39°C ។
- អាចដែនិងហូតជាលួសបាន ។
- ចម្លងកម្ដៅនិងអគ្គិសនីបានល្អ : ប្រាក់គឺជាធាតុដែលចម្លងអគ្គិសនីបានល្អជាងគេបំផុតហើយទង់ដែងល្អបន្ទាប់ពីប្រាក់ ។

For MPTC-Ebooks Only

- មិនដូចសូដ្យូមទេ លោហៈទាំងនេះលិចក្នុងទឹក ព្រោះដង់ស៊ីតេរបស់វាធំជាងដង់ស៊ីតេទឹក $1g/cm^3$ ។

## 4.2 លក្ខណៈគីមី

សកម្មភាពរបស់លោហៈឆ្លងខ្សោយជាងលោហៈអាល់កាឡាំងខ្លាំងណាស់ ។

*ឧទាហរណ៍ :*




***ទង់ដែងគ្មានប្រតិកម្មជាមួយទឹក***

(សូដ្យូមមានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយទឹក)



***ទង់ដែងមិនឆេះក្នុងខ្យល់***

(សូដ្យូមឆេះក្នុងខ្យល់យ៉ាងខ្លាំង)

- យើងអាចផលិតអំបិលរបស់លោហៈឆ្លងដោយឱ្យអុកស៊ីត ឬអ៊ីដ្រុកស៊ីតរបស់វាមានប្រតិកម្មជាមួយអាស៊ីត ។
- អុកស៊ីតឬអ៊ីដ្រុកស៊ីតរបស់លោហៈឆ្លងជា **បាស** ។ លក្ខណៈមិនសូវសកម្មរបស់វាមានន័យថា វាមិនរងកំណួតនៅក្នុងខ្យល់និងក្នុងទឹកទេ លើកលែងតែដែក ។ដែកងាយឡើងច្រែះ ហើយយើងបានចំណាយប្រាក់ជាច្រើនជារៀងរាល់ឆ្នាំដើម្បីការពារមិនអោយឡើងច្រែះនេះ ។

• **បម្រែបម្រួលវ៉ាឡង់ :អ៊ីយ៉ុងលោហៈឆ្លងមួយចំនួន មានវ៉ាឡង់ប្រែប្រួល ។**

*ឧទាហរណ៍ :* អ៊ីយ៉ុងវ៉ាឡង់ខុសគ្នា

អ៊ីយ៉ុងក្រូម : $Cr^{2+}$ និង $Cr^{3+}$

អ៊ីយ៉ុងដែក : $Fe^{2+}$ និង $Fe^{3+}$

អ៊ីយ៉ុងទង់ដែង : $Cu^{+}$ និង $Cu^{2+}$

• **អ៊ីយ៉ុងកុំផ្លិច** : លោហៈឆ្លងបង្កើតជាអ៊ីយ៉ុងកុំផ្លិចដែលមានបន្ទុកអវិជ្ជមាន :

*ឧទាហរណ៍ :* អ៊ីយ៉ុងក្រូម៉ាត : $CrO_4^{2-}$

អ៊ីយ៉ុងឌីក្រូម៉ាត : $Cr_2O_7^{2-}$

អ៊ីយ៉ុងពែម៉ង់កាណាត : $MnO_4^{-}$

For MPTC Ebooks Only

- **ពណ៌របស់សមាសធាតុៈសមាសធាតុរបស់លោហៈឆ្លងសុទ្ធតែមានពណ៌សំគាល់ជានិច្ច ។**

*ឧទាហរណ៍ :* សមាសធាតុដែលមានអ៊ីយ៉ុងដែក (*II*) : $Fe^{2+}$ ពណ៌ត្រួយចេក

សមាសធាតុដែលមានអ៊ីយ៉ុងដែក (*III*) : $Fe^{3+}$ ពណ៌លឿង

សមាសធាតុដែលមានអ៊ីយ៉ុងទង់ដែង (*II*) : $Cu^{2+}$ ពណ៌ខៀវខ្ចី

សមាសធាតុដែលមានអ៊ីយ៉ុងក្រូម៉ាត : $CrO_4^{2-}$ ពណ៌លឿង

សមាសធាតុដែលមានអ៊ីយ៉ុងឌីក្រូម៉ាត : $Cr_2O_7^{2-}$ ពណ៌ទឹកក្រូច

សមាសធាតុដែលមានអ៊ីយ៉ុងពែម៉ង់កាណាតៈ $MnO_4^-$ ពណ៌ស្វាយស្លែត

- **លក្ខណៈកាតាលីករ : មានលោហៈឆ្លងនិងសមាសធាតុវាជាច្រើនមាននាទីជាកាតាលីករក្នុងពេលប្រតិកម្មគីមី ។**

*ឧទាហរណ៍ :* កាតាលីករ

- វ៉ាណាដ្យូមអុកស៊ីត : ជាកាតាលីករក្នុងឧស្សាហកម្មអាស៊ីតស៊ុលផួរិច
- ដែក : ជាកាតាលីករក្នុងឧស្សាហកម្មអាម៉ូញ៉ាក់

## 4.3 បម្រើបម្រាស់

លោហៈឆ្លងភាគច្រើនប្រើនៅក្នុងជីវភាពប្រចាំថ្ងៃ ដូចជានៅក្នុងផ្ទះបាយ សាលារៀននិងទីកន្លែងជាច្រើនទៀត ។ ភាពរឹងស្វិតរបស់វាអាចយកមកប្រើប្រាស់ក្នុងការសាងសង់អាគារនិងសំណង់ផ្សេងៗ ។ ដែកជាធាតុដែលគេប្រើច្រើនជាងគេនៅក្នុងសំណង់ ។ ជាធម្មតាគេប្រើវាជាដែកថែប ឬជា**សំលោហៈ**ដែក ។ គេប្រើលោហៈឆ្លងសម្រាប់វត្ថុទាំងឡាយណាដែលធ្វើឱ្យកម្តៅនិងចរន្តអគ្គិសនីឆ្លងកាត់បានយ៉ាងងាយ ។ គេប្រើដែកថែបនៅក្នុងម៉ាស៊ីនរ៉ាដ្យាទ័រហើយគេប្រើទង់ដែងក្នុងខ្សែកាបអគ្គិសនី ។គេប្រើលោហៈឆ្លងនិងសមាសធាតុរបស់វាជា**កាតាលីករ** ដើម្បីបង្កើនល្បឿនប្រតិកម្មដោយគ្មានការប្រែប្រួលលក្ខណៈគីមីរបស់វាទេ ។

# 5. ភាពស្រដៀងគ្នានៃរូបមន្តគីមី

ភាពស្រដៀងគ្នានៃរូបមន្តគីមីត្រូវបានកំណត់តាមរយៈក្រុមដែលធាតុនោះឋិតនៅ ។ធាតុនីមួយៗនៅក្នុងក្រុម I មានអេឡិចត្រុងតែមួយគត់នៅស្រទាប់ក្រៅបង្អស់ ដូចនេះអ៊ីយ៉ុងវាមានបន្ទុក$+1$ ។ អាស្រ័យហេតុនេះ វ៉ាឡង់ ឬទំនោរចងសម្ព័ន្ធនៃធាតុនីមួយៗនៅក្នុងក្រុមតែមួយ គឺដូចគ្នា ។

For MPTC-Ebooks Only

ធាតុនីមួយៗនៅក្នុងក្រុមតែមួយ មានចំនួនអេឡិចត្រុងស្រទាប់ក្រៅបង្អស់ដូចគ្នា ដូចនេះបន្ទុកលើអ៊ីយ៉ុងរបស់វា ឬចំនួនអេឡិចត្រុងដាក់ហ៊ុននៅពេលបង្កើតជាសមាសធាតុគឺដូចគ្នា។ តារាងខាងក្រោមនេះបង្ហាញពីវ៉ាឡង់ ឬទំនោរចងសម្ព័ន្ធនៃធាតុក្នុងក្រុមតែមួយដែលធ្វើឱ្យរូបមន្តគីមីរបស់សមាសធាតុមានផលធៀបអាតូមដូចគ្នា។

## តារាងភាពស្រដៀងគ្នានៃរូបមន្តគីមី

| ក្រុម | និមិត្តសញ្ញា | អុកស៊ីត | អ៊ីដ្រុកស៊ីត | នីត្រាត | ស៊ុលផាត | កាបូណាត | ក្លរួ |
|---|---|---|---|---|---|---|---|
| I | Na | $Na_2O$ | NaOH | $NaNO_3$ | $Na_2SO_4$ | $Na_2CO_3$ | NaCl |
| | K | $K_2O$ | KOH | $KNO_3$ | $K_2SO_4$ | $K_2CO_3$ | KCl |
| II | Mg | MgO | $Mg(OH)_2$ | $Mg(NO_3)_2$ | $MgSO_4$ | $MgCO_3$ | $MgCl_2$ |
| | Ca | CaO | $Ca(OH)_2$ | $Ca(NO_3)_2$ | $CaSO_4$ | $CaCO_3$ | $CaCl_2$ |
| III | B | $B_2O_3$ | $B(OH)_3$ | *$B(NO_3)_3$ | *$B_2(SO_4)_3$ | *$B_2(CO_3)_3$ | $BCl_3$ |
| | Al | $Al_2O_3$ | $Al(OH)_3$ | $Al(NO_3)_3$ | $Al_2(SO_4)_3$ | $Al_2(CO_3)_3$ | $AlCl_3$ |

(* សម្គាល់ : សមាសធាតុគ្មានស្ថិរភាព)

### មេរៀនសង្ខេប

- ធាតុនៅក្នុងក្រុម I ឈ្មោះថា "**លោហៈអាល់កាឡាំង**"។ វាជាលោហៈទន់មានចំណុចរលាយ និងដង់ស៊ីតេទាប។ វាជាលោហៈសកម្មខ្លាំង មានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយទឹក រំដោះអ៊ីដ្រូសែន។ នៅក្នុងក្រុមសកម្មភាពរបស់វាកើនឡើងពីលើចុះក្រោម។
- លោហៈអាល់កាឡាំងជារេដុករខ្លាំងអាតូមរបស់វាបោះបង់អេឡិចត្រុងមួយដើម្បីក្លាយជាកាចុង។

  **ឧទាហរណ៍ :** $Na \rightarrow Na^+ + 1\bar{e}$
- ធាតុនៅក្រុម VII ហៅថា "**អាឡូសែន**"។ អាឡូសែនជាអលោហៈសកម្មខ្លាំងហើយនៅក្នុងក្រុមសកម្មភាពនេះថយចុះពីលើចុះក្រោម។ វាជាអលោហៈដែលមានម៉ូលេគុលឌីអាតូម។ អាឡូសែនដែលខ្លាំងអាចជំនួសអាឡូសែនដែលខ្សោយចេញពីអំបិលរបស់វាបាន។
- ធាតុនៅក្រុមទី VIII ហៅថា "**ឧស្ម័នកម្រ**"។ វាជាធាតុអសកម្មខ្លាំងព្រោះស្រទាប់ក្រៅបង្អស់របស់វាមានអេឡិចត្រុង 8 (ផ្លែតអេឡិចត្រុង)។
- លោហៈឆ្លង គឺជាក្រុមធាតុដែលឋិតនៅផ្នែកកណ្តាលនៃតារាងខួប មានដង់ស៊ីតេ និងចំណុចរំពុះខ្ពស់។ លោហៈឆ្លង និងសមាសធាតុរបស់វាខ្លះជាកាតាលីករដ៏ល្អ។

For MPTC-Ebooks Only

## ? សំណួរនិងលំហាត់

1. ចូរប្រើតារាងខួបនៃធាតុគីមីដើម្បីឆ្លើយនឹងសំណួរខាងក្រោម ៖

ក. ឱ្យឈ្មោះ និងនិមិត្តសញ្ញាលោហៈពីរក្នុងក្រុម III

ខ. ឱ្យឈ្មោះ និងនិមិត្តសញ្ញាអលោហៈពីរក្នុងក្រុម VI

គ. ឱ្យឈ្មោះ និងនិមិត្តសញ្ញាឧស្ម័នពីរក្នុងក្រុមអាឡូសែន

ឃ. ឱ្យឈ្មោះ និងនិមិត្តសញ្ញាលោហៈពីរក្នុងក្រុមលោហៈអាល់កាឡាំង

2. តើធាតុណាមួយដែលឋិតនៅក្នុងក្រុម **I** ?

ក. ម៉ាញេស្យូម

ខ. ដែក

គ. ទង់ដែង

ឃ. ប៉ូតាស្យូម

3. បើពិនិត្យលក្ខណៈនៃធាតុនៅក្នុងក្រុម VII ពីលើចុះក្រោម ? តើប្រយោគខាងក្រោមនេះណាមួយដែលត្រឹមត្រូវ ?

ក. ពណ៌របស់ធាតុកាន់តែចាស់ទៅៗ　　ខ. ចំណុចរំពុះរបស់វាថយចុះ

គ. ភាពរូបរបស់ធាតុប្រែប្រួលពីរឹងទៅឧស្ម័ន　　ឃ. ធាតុគីមីកាន់តែសកម្មខ្លាំង

4. សេណុងជាឧស្ម័នកម្រ ។ តើប្រយោគណាមួយខាងក្រោមដែលត្រឹមត្រូវ ៖

ក. ម៉ូលេគុលរបស់សេណុងមានពីរអាតូម　　ខ. សេណុងទ្រទ្រង់ចំហេះ

គ. សេណុងជាឧស្ម័នអសកម្ម　　ឃ. សេណុងមិនមាននៅក្នុងខ្យល់

5. ក្នុងចំណោមរូបមន្តខាងក្រោមរបស់សមាសធាតុបារ្យូម តើរូបមន្តណាមួយដែលពុំត្រឹមត្រូវ ?

ក. $BaCl_2$　　ខ. $Ba(OH)_2$　　គ. $BaNO_3$　　ឃ. $BaSO_4$

6. $X$ , $Y$ និង $Z$ ជាធាតុ 3 នៅក្នុងខួបតែមួយនៃតារាងខួប ។

$X$ ជាអលោហៈ , $Y$ ជាលោហៈ និង $Z$ ជាលោហៈឆ្លង ។

តើលំដាប់ណាមួយខាងក្រោមនេះដែលត្រឹមត្រូវតាមតារាងខួបពីឆ្វេងទៅស្តាំ ?

ក. $X\ Y\ Z$　　ខ. $X\ Z\ Y$　　គ. $Z\ Y\ X$　　ឃ. $Y\ Z\ X$

For MPTC-Ebooks Only

## សំណួរនិងលំហាត់ជំពូក 2

**I.** ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវមានតែមួយគត់ :

1. ក្នុងតារាងខួបគេតម្រៀបធាតុគីមីទៅតាម :

☐ ក. ចំនួនស្រទាប់អេឡិចត្រុង ☐ ខ. លំដាប់កើនឡើងនៃចំនួនប្រូតុង

☐ គ. ប្រភេទក្រុមធាតុគីមី ☐ ឃ. សកម្មភាពគីមីរបស់ធាតុ

2. តើក្រុមណាមួយដែលបង្ហាញពីចំនួនប្រូតុងរបស់លោហៈអាល់កាឡាំង

☐ ក. 7 , 23 , 39 ☐ ខ. 12 , 20 , 38

☐ គ. 18 , 36 , 54 ☐ ឃ. 19 , 37 , 55

3. ក្នុងក្រុម VII ធាតុ $X$ ឋិតនៅក្រោមក្លរ ។ តើប្រយោគណាមួយដែលត្រឹមត្រូវចំពោះធាតុ $X$ ?

☐ ក. $X$ អាចជំនួសក្លរពីសូលុយស្យុងក្លរួ

☐ ខ. $X$ ជាឧស្ម័ននៅលក្ខខណ្ឌបន្ទប់

☐ គ. ម៉ូលេគុលរបស់ $X$ មាន 2 អាតូម

☐ ឃ. $X$ មានប្រតិកម្មជាមួយក្លរបង្កើតបានសមាសធាតុអ៊ីយ៉ុង

4. នៅក្នុងអំពូលមូលគេបំពេញឧស្ម័ន :

☐ ក. ខ្យល់ ☐ ខ. អុកស៊ីសែន ☐ គ. ក្លរ ☐ ឃ. អាកុង

5. ក្នុងចំណោមធាតុខាងក្រោម តើធាតុណាមួយដែលឋិតនៅក្នុងក្រុមលោហៈឆ្លង ?

☐ ក. Li ☐ ខ. Fe ☐ គ. Mg ☐ ឃ. Br

**II.** ចូរបំពេញល្បះខាងក្រោមឱ្យមានន័យត្រឹមត្រូវ

1. នៅក្នុងតារាងខួបធាតុគីមីត្រូវបាន . . . . . . តាមលំដាប់កើនឡើងនៃ . . . . . . ។

2. នៅក្នុងក្រុមពីលើចុះក្រោមសកម្មភាពគីមីរបស់លោហៈ . . . . . ឯសកម្មភាពគីមីរបស់អលោហៈ . . . . . . . . . . . . ។

3. ប៉ូតាស្យូមជាលោហៈ . . . . . . នីកែលជា . . . . . . ចំណែកសេណុងគឺជា . . . . . . ។

**III.** ចូរសរសេរពាក្យ "ខុស" ឬ "ត្រូវ" ក្នុងប្រអប់នៅមុខអំណះអំណាងខាងក្រោម :

☐ ក. ក្នុងតារាងខួបលោហៈឋិតនៅផ្នែកខាងស្តាំ ហើយអលោហៈឋិតនៅផ្នែកខាងឆ្វេង ។

☐ ខ. នៅក្នុងក្រុម VII ភ្លុយអរជាអលោហៈសកម្មជាងគេ ។

☐ គ. លោហៈឆ្លងជាធាតុដែលមានចំណុចរលាយ និងដង់ស៊ីតេខ្ពស់ ។

☐ ឃ. ធាតុទាំងអស់ក្នុងក្រុម VIII ជាធាតុសកម្ម ។

**IV.** លំហាត់

1. ក. ចូរបំពេញតារាងដែលពណ៌នាពីធាតុអាឡូសែន :

| អាឡូសែន | ភាពរូបនៅសីតុណ្ហភាពបន្ទប់ | ពណ៌ | របាយអេឡិចត្រុង |
|---|---|---|---|
| ភ្លុយអរ | . . . . . . . . . . . . . . . | លឿងស្លែត | . . . . . . . . . . . . . |
| . . . . . . . . | ឧស្ម័ន | . . . . . . . . . . . . | . . . . . . . . . . . . . |
| . . . . . . . . | . . . . . . . . . . . . . . . . | ក្រហមត្នោត | 2 , 8 , 18 , 7 |
| អ៊ីយ៉ូត | រឹង | . . . . . . . . . . . . | 2 , 8 , 18 , 18 , 7 |

ខ. តាមតារាងខាងលើនេះ តើធាតុអាឡូសែនណាមួយដែលគេស្គាល់ច្រើនជាងនៅក្នុងជីវភាពប្រចាំថ្ងៃ ?

គ. តើអាឡូសែនណាមួយដែលសកម្មតិចបំផុត ?

2. លីចូមជាលោហៈស្រាលបំផុត (ដង់ស៊ីតេ $0.54 g \cdot cm^{-3}$ ) និងមានចំណុចរលាយ $181°C$ ។ វាមានពណ៌ប្រផេះ និងឡើងស្រអាប់ពេលត្រូវខ្យល់ ។ លីចូមមានប្រតិកម្មជាមួយទឹកត្រជាក់ អាឡូសែន និងឧស្ម័នអាសូត ។

ក. តើអ្នកគួរដាក់លីចូមក្នុងក្រុមណានៃតារាងខួប ?

ខ. សរសេររូបមន្ត លីចូមអុកស៊ីត លីចូមអ៊ីដ្រុកស៊ីត និងលីចូមក្លរួ ។

គ. តើនឹងមានអ្វីកើតឡើងពេលលីចូមប្រតិកម្មជាមួយទឹកត្រជាក់ ? សរសេរសមីការគីមីតាងប្រតិកម្ម ។

3. នេះជាទម្រង់គូទខ្យងរបស់តារាងខួប




ក. បំពេញទម្រង់ខាងលើនៃតារាងខួបដោយដាក់និមិត្តសញ្ញា និងចំនួនប្រូតុងនៃធាតុ 20 ដំបូង ។

ខ. តើផ្នែកណាមួយជា : លោហៈអាល់កាឡាំង ? អាឡូសែន ? ឧស្ម័នកម្រ ?

For MPTC-Ebooks Only

# ជំពូក 3 សម្ព័ន្ធគីមីនិងទម្រង់អង្គធាតុរឹង





នៅពេលធាតុគីមីមានប្រតិកម្មជាមួយគ្នា តើមានអ្វីកើតឡើង ? អាតូមនៃធាតុគីមីបានផ្គុំគ្នាបង្កើតជាសារធាតុច្រើនប្រភេទដែលមានលក្ខណៈនិងសារប្រយោជន៍ផ្សេងៗពីគ្នា ។

អាតូមទាំងឡាយចងសម្ព័ន្ធជាមួយគ្នាបង្កើតជាសមាសធាតុផ្សេងៗដែលមានលក្ខណៈរូប លក្ខណៈគីមីខុសៗគ្នា ហើយតាមរយៈលក្ខណៈទាំងនេះ យើងអាចប្រើវាបានសមស្រប ។ ដូចនេះការចងសម្ព័ន្ធគឺជាប្រធានបទមួយដែលគួរឱ្យចាប់អារម្មណ៍និងមានសារៈសំខាន់បំផុតសម្រាប់គីមីវិទូ ។

នៅក្នុងជំពូកនេះ យើងនឹងសិក្សាពីរបៀបចងសម្ព័ន្ធរបស់អាតូមនៃធាតុគីមី ហេតុអ្វីបានជាឧស្ម័ននិចលមានស្ថិរភាព មិនចងសម្ព័ន្ធជាមួយធាតុផ្សេងទៀត ? យើងនឹងសិក្សាផងដែរអំពីប្រភេទខុសគ្នានៃការចងសម្ព័ន្ធនិងទម្រង់របស់អង្គធាតុរឹងដែលបានមកពីការចងសម្ព័ន្ធ ។

For MPTC-Ebooks Only

### មេរៀនទី 1 : សម្ព័ន្ធគីមី

### មេរៀនទី 2 : ទម្រង់អង្គធាតុរឹង

មេរៀនទី

# 1 សម្ព័ន្ធគីមី

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពន្យល់អំពីកំណសម្ព័ន្ធកូវ៉ាឡង់ដោយការដាក់ហ៊ុនគូអេឡិចត្រុង ។
- ❒ ពន្យល់ពីកំណអ៊ីយ៉ុងដោយការបាត់បង់ឬការទទួលយកអេឡិចត្រុង ។
- ❒ ញែកសម្គាល់រវាងសារធាតុអ៊ីយ៉ុងនិងសារធាតុកូវ៉ាឡង់ ។

ការចងសម្ព័ន្ធរបស់អាតូមទាំងឡាយ បង្កើតបានរូបធាតុជាច្រើនប្រភេទ ។ ការចងសម្ព័ន្ធរបស់អាតូមមួយចំនួនជាមួយអាតូមផ្សេងទៀត បណ្ដាលឱ្យមានប្រតិកម្មយ៉ាងរហ័ស និងថែមទាំងអាចមានបន្ទុះទៀតផង ។ ធាតុគីមីទាំងនេះជាធាតុគីមីសកម្ម ។ មានឧស្ម័នតែមួយចំនួនតូចទេ (ឧស្ម័ននិចល) ដែលអាតូមរបស់វាស្ថិតនៅតែឯងដោយមិនត្រូវការចងសម្ព័ន្ធ ។

## 1. ការចងសម្ព័ន្ធគីមី

យើងបានសិក្សាពីទម្រង់អាតូមដែលបង្ហាញពីការតម្រៀបប្រូតុងណឺត្រុងនិងអេឡិចត្រុងក្នុងអាតូម ។ចំណុចសំខាន់ក្នុងការចងសម្ព័ន្ធគឺការតម្រៀបរបស់អេឡិចត្រុង ជាពិសេស**អេឡិចត្រុងវ៉ាឡង់** ។ **ការចងសម្ព័ន្ធ** គឺជារបៀបមួយដែលអាតូមទាំងឡាយចូលផ្តុំជាមួយគ្នា ។

ទាក់ទងនឹងការចងសម្ព័ន្ធ យើងគួរចងចាំនូវចំណុចសំខាន់ដូចខាងក្រោមនេះ :

1. មានតែអេឡិចត្រុងនៅស្រទាប់ក្រៅប៉ុណ្ណោះ (អេឡិចត្រុងវ៉ាឡង់) ដែលចូលរួមនៅក្នុងការចងសម្ព័ន្ធ ។
2. គ្រប់អាតូមទាំងអស់មានទំនោរទៅរកទម្រង់អេឡិចត្រុងដូចឧស្ម័ននិចល ដែលធ្វើឱ្យវាមានស្ថិរភាពបំផុត ។
3. ចំនួនអេឡិចត្រុងឆ្អែតនៅស្រទាប់ទីមួយគឺ 2 ស្រទាប់ទីពីរគឺ 8 ស្រទាប់ទីបីគឺ 18 ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មានធាតុជាច្រើនដែលអេឡិចត្រុងចាប់ផ្តើមបំពេញស្រទាប់ទីបួននៅពេលដែលស្រទាប់ទីបីមានតែ 8 អេឡិចត្រុង ។
4. អាតូមទាំងឡាយមានទំនោរ ធ្វើឱ្យស្រទាប់វ៉ាឡង់ទទេ ឬស្រទាប់វ៉ាឡង់ពេញដោយអេឡិចត្រុង 8 (មួយអដ្ឋតា ឬ 4 ទ្វេតាអេឡិចត្រុង) ។ នេះហៅថា “ **ច្បាប់អដ្ឋតា** ” ។

For MPTC-Ebooks Only

**ច្បាប់អុកតេត** : “គ្រប់អាតូមទាំងអស់វិវត្តតាមន័យគីមីដើម្បីឱ្យស្រទាប់ក្រៅបង្អស់របស់វាផ្ទុកគឺមួយអុកតេតអេឡិចត្រុង (លើកលែងតែអ៊ីដ្រូសែនដែលស្រទាប់ក្រៅផ្ទុកមាន 2 អេឡិចត្រុងដូចអេល្យូម He )” ។

យើងនឹងសិក្សាពីការចងសម្ព័ន្ធបង្កើតជា **សម្ព័ន្ធកូវ៉ាឡង់ សម្ព័ន្ធអ៊ីយ៉ុង** និង**សម្ព័ន្ធលោហៈ** (មេរៀនទី2) ។ ចំពោះ សម្ព័ន្ធអ៊ីដ្រូសែន ជាប្រភេទពិសេសមួយដែលកើតឡើងពីកម្លាំងនៃអន្តរកម្មរវាងម៉ូលេគុល និងម៉ូលេគុលដែលក្នុងនោះអាតូមអ៊ីដ្រូសែនដើរតួជាស្ពាននៅចន្លោះអាតូមពីរដូចជា O ,N ឬ F ។

***ឧទាហរណ៍ :*** ទឹក ($H_2O$) សូលុយស្យុងអាម៉ូញាក់ $NH_3$ ... ។



***រូបទី1 សម្ព័ន្ធអ៊ីដ្រូសែនដែលកើតមាននៅក្នុងទឹក ($H_2O$) និងសូលុយស្យុងអាម៉ូញាក់ ($NH_3$)***

## 2. ម៉ូលេគុលនិងសម្ព័ន្ធកូវ៉ាឡង់

ការកើតបានជាម៉ូលេគុល គឺទាក់ទងនឹងការដាក់ហ៊ុនអេឡិចត្រុងរវាងអាតូម និងអាតូមដោយមិនមានការផ្ទេរអេឡិចត្រុងពីអាតូមមួយទៅអាតូមមួយផ្សេងទៀតឡើយ ។ លទ្ធផលនៃការដាក់ហ៊ុនអេឡិចត្រុងនេះ គឺការកើតឡើងជាភាគល្អិតដែលមិនមានបន្ទុកឡើយ វាគ្រាន់តែជាភាគល្អិតនៃក្រុមអាតូមប៉ុណ្ណោះហៅថា **ម៉ូលេគុល** ។

ដើម្បីពន្យល់ពីប្រភេទសម្ព័ន្ធនេះ យើងសិក្សាពីម៉ូលេគុលងាយមួយគឺ**ឌីស្ល័រក្លរ** ។ អាតូមនីមួយៗមានអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ចំនួន7 ។ របាយអេឡិចត្រុងតាមស្រទាប់គឺ 2 ,8,7 មានន័យថាវាខ្វះអេឡិចត្រុង 1 ទៀតនៅស្រទាប់ទី3 ដើម្បីមានស្ថិរភាពតាមច្បាប់ អុកតេត។ អាតូមក្លរ1នឹងមានស្ថិរភាពដោយការ**ដាក់ហ៊ុន** អេឡិចត្រុង1 ជាមួយអាតូមក្លរមួយផ្សេងទៀត ។ ជាលទ្ធផល វាមាន2 អេឡិចត្រុង ( 1ទ្វេតាអេឡិចត្រុង) ដែលដាក់ហ៊ុនជាមួយគ្នា។ មួយទ្វេតាអេឡិចត្រុងដែលដាក់ហ៊ុននេះបង្កើតបានជា **សម្ព័ន្ធកូវ៉ាឡង់ទោល** ។




***រូបទី2 : សម្ព័ន្ធកូវ៉ាឡង់ទោល***

ឥឡូវយើងសិក្សាអំពីម៉ូលេគុលឌីស្ល័រអុកស៊ីសែន ។ អាតូមអុកស៊ីសែននីមួយៗមានអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ចំនួន6 ។ របាយអេឡិចត្រុងតាមស្រទាប់គឺ 2 ,6 មានន័យថាវាខ្វះអេឡិចត្រុង2

For MPTC-Ebooks Only

ទៀតនៅស្រទាប់ទី2 ដើម្បីមានស្ថិរភាពតាមច្បាប់អដ្ឋតា។ អាតូមអុកស៊ីសែន1 នឹងមានស្ថិរភាពដោយដាក់ហ៊ុន2 អេឡិចត្រុងជាមួយអាតូមអុកស៊ីសែនមួយផ្សេងទៀត។ ជាលទ្ធផលវាមាន4 អេឡិចត្រុង ( 2ទេ្វតាអេឡិចត្រុង ) ដែលបានដាក់ហ៊ុនជាមួយគ្នា។ 2ទេ្វតាអេឡិចត្រុងដែលដាក់ហ៊ុននេះបង្កើតបានជា **សម្ព័ន្ធកូវ៉ាឡង់ពីរជាន់**។




***រូបទី3 : សម្ព័ន្ធកូវ៉ាឡង់ពីរជាន់***

តារាងទី1 : ទម្រង់អេឡិចត្រុងនៃម៉ូលេគុលកូវ៉ាឡង់ងាយៗមួយចំនួន

| ម៉ូលេគុល | ការចងសម្ព័ន្ធកូវ៉ាឡង់ |
|---|---|
| អ៊ីដ្រូសែន $H_2(g)$ |  |
| មេតាន $CH_4(g)$ |  |
| ទឹក $H_2O(g)$ |  |
| អាម៉ូញ៉ាក់ $NH_3(g)$ |  |
| កាបូនឌីអុកស៊ីត $CO_2(g)$ |  |



ម៉ូលេគុលអ៊ីដ្រូសែន ($H_2$)



ម៉ូលេគុលអុកស៊ីសែន ($O_2$)



ម៉ូលេគុលអាម៉ូញ៉ាក់ ($NH_3$)

***រូបទី 4 : គំរូម៉ូលេគុលសារធាតុកូវ៉ាឡង់***

For MPTC-Ebooks Only

## 3. អ៊ីយ៉ុងនិងសម្ព័ន្ធអ៊ីយ៉ុង

សម្ព័ន្ធអ៊ីយ៉ុង គឺជាការចងសម្ព័ន្ធនឹងគ្នានៃអាតូមដែលកើតឡើងដោយការ**ផ្ទេរអេឡិចត្រុង** ។ ការផ្ទេរអេឡិចត្រុងនេះ ទាក់ទងនឹងការបាត់បង់អេឡិចត្រុងឬការទទួលអេឡិចត្រុង ហើយជាលទ្ធផល គឺវាបង្កើតបានជា **អ៊ីយ៉ុង ។** អ៊ីយ៉ុងទាំងនេះ ជាភាគល្អិតដែលមានបន្ទុកអគ្គិសនី ហើយប្រទាញគ្នាចូល ដោយសារកម្លាំង**ទំនាញអេឡិចត្រូស្តាទិច** ។

ដើម្បីពន្យល់ពីប្រភេទសម្ព័ន្ធនេះ យើងលើកយកសូដ្យូមក្លរួមកសិក្សា ។ វាជាសារធាតុសាមញ្ញ បំផុតដែលគេស្គាល់ថាជាអំបិលសម្ល ។ អំបិលនេះមានសារៈសំខាន់ណាស់សម្រាប់ជីវិតនិងមិនមានគ្រោះ ថ្នាក់អ្វីឡើយ វាបង្កឡើងពីធាតុគីមីពីរប្រភេទគឺសូដ្យូមដែលងាយឆេះក្នុងខ្យល់និងក្លរដែលជាធាតុពុល ខ្លាំង ។តើធាតុទាំងពីរនេះមានប្រយោជន៍ដូចម្តេចពេលវាផ្សំគ្នាបង្កើតបានជាអំបិលសម្ល (NaCl) ។

| **បន្ទុកនៅលើអ៊ីយ៉ុងសូដ្យូម** | |
|---|---|
| បន្ទុកនៅលើ 11 ប្រូតុង | = +11 |
| បន្ទុកនៅលើ 10 អេឡិចត្រុង | = - 10 |
| បន្ទុកសរុប | = +1 |

អាតូមសូដ្យូមមានប្រតិកម្មខ្លាំង អាស្រ័យដោយការ តម្រៀបអេឡិចត្រុងរបស់វា 2 , 8, 1 ។ វាមានអេឡិចត្រុង វ៉ាឡង់មួយនៅស្រទាប់ទី 3 ដែលមានទំនោរនឹងបោះបង់ ។ អេឡិចត្រុងវ៉ាឡង់នេះ មានកម្លាំងទំនាញខ្សោយពីព្រោះវា នៅឆ្ងាយពីណ្វៃយ៉ូដែលមានបន្ទុកវិជ្ជមាន ។ នៅពេលអាតូម សូដ្យូមបាត់បង់អេឡិចត្រុង 1 នៅស្រទាប់ទី 3 វានឹងមានស្ថិរភាព មានន័យថាស្រទាប់ក្រៅបង្អស់របស់ វាឆ្អែតតាមច្បាប់អុកតេ ។ បន្ទាប់មកអាតូមសូដ្យូមនេះបានក្លាយជាអ៊ីយ៉ុងវិជ្ជមាន ពីព្រោះវាបាត់បង់អេ ឡិចត្រុងអវិជ្ជមាន 1 (ភាគល្អិតនេះមាន 11 ប្រូតុង ប៉ុន្តែវាមានអេឡិចត្រុងតែ 10 ប៉ុណ្ណោះ) ។

$$\underset{2,\,8,\,1}{Na} \longrightarrow \underset{2,\,8}{Na^{+}} + 1e^{-}$$

| **បន្ទុកនៅលើអ៊ីយ៉ុងក្លរ** | |
|---|---|
| បន្ទុកនៅលើ 17 ប្រូតុង | = +17 |
| បន្ទុកនៅលើ 18 អេឡិចត្រុង | = - 18 |
| បន្ទុកសរុប | = -1 |

អាតូមក្លរអាចជួយអាតូមសូដ្យូមក្នុងការបាត់បង់ 1 អេឡិចត្រុងនេះ ។ របាយអេឡិចត្រុងរបស់អាតូមក្លរគឺ 2, 8, 7 មានន័យថាវាត្រូវការ 1 អេឡិចត្រុងដើម្បីបំពេញស្រទាប់ ទី 3 ឱ្យឆ្អែត (មានស្ថិរភាព) តាមច្បាប់អុកតេ ។ ណ្វៃយ៉ូរបស់ អាតូមក្លរទាញយកអេឡិចត្រុងមួយពីអាតូមសូដ្យូម បន្ទាប់ មកអាតូមក្លរក្លាយជាអ៊ីយ៉ុងក្លរដែលមានបន្ទុកអវិជ្ជមាន (អ៊ីយ៉ុងវាមាន 17 ប្រូតុង ប៉ុន្តែមាន 18 អេឡិច ត្រុង) ។

$$\underset{2,\,8,\,7}{Cl} + 1e^{-} \longrightarrow \underset{2,\,8,\,8}{Cl^{-}}$$

For MPTC E-Books Only

យើងអាចបង្ហាញពីការផ្ទេរអេឡិចត្រុងនេះដោយដ្យាក្រាម “ ចំណុចមូល ខ្វែង ” បញ្ជាក់ពីអេឡិចត្រុងក្នុងអាតូមផ្សេងគ្នា ។




***រូបទី5 : ដ្យាក្រាមបង្ហាញពីការផ្ទេរអេឡិចត្រុងរវាងអាតូមសូដ្យូមនិងក្លរ***

សម្ព័ន្ធអ៊ីយ៉ុងអាចកើតមានចំពោះសមាសធាតុដូចក្នុងតារាងខាងក្រោម :

តារាងទី2 : ដ្យាក្រាមបង្ហាញពីការបង្កើតសមាសធាតុអ៊ីយ៉ុង

| សមាសធាតុ | ការបង្កើតជាអ៊ីយ៉ុង |
|---|---|
| ប៉ូតាស្យូមភ្លុយអរួ (KF) |  |
| លីចូមក្លរួ (LiCl) |  |
| ម៉ាញ៉េស្យូមអុកស៊ីត (MgO) |  |
| កាល់ស្យូមក្លរួ ($CaCl_2$) |  |
| ប៉ូតាស្យូមអុកស៊ីត ($K_2O$) |  |

សម្ព័ន្ធអ៊ីយ៉ុង ងាយកើតឡើងពីបន្សំរវាងលោហៈក្រុមI និងក្រុមII ជាមួយអលោហៈក្នុងក្រុមVI និង ក្រុម VII នៃតារាងខួប ។ ក្រុមធាតុនៅកណ្តាលតារាងខួប ( មានអេឡិចត្រុងនៅស្រទាប់ក្រៅបំផុតច្រើន )មិនអាចបង្កើតជាអ៊ីយ៉ុងបាន ពីព្រោះវាទាក់ទងនឹងថាមពលច្រើនក្នុងការបោះបង់ឬទទួលយកបីឬបួនអេឡិចត្រុង ។ ចំពោះអ៊ីយ៉ុងអាលុយមីញ៉ូម ($Al^{3+}$ ) ជាករណីលើកលែង វាមានលក្ខណៈជាសម្ព័ន្ធអ៊ីយ៉ុងផងនិងជាសម្ព័ន្ធកូវ៉ាឡង់ផង ។ ធាតុដែលអាចបង្កើតជាសម្ព័ន្ធអ៊ីយ៉ុងក្នុងចំណោមធាតុ 20 ដំបូង និងបង្ហាញក្នុងរូបទី6 ។

For MPTC-Ebooks Only

| ក្រុម I | 2 | | 3 | 4 | 5 | 6 | 7 | 0 |
|---|---|---|---|---|---|---|---|---|
| | | $H^+$ អ៊ីដ្រូសែន | | | | | | គ្មាន |
| $Li^+$ លីចូម | $Be^{2+}$ បេរីល្យូម | | | | | $O^{2-}$ អុកស៊ីត | $F^-$ ភ្លុយអរួ | គ្មាន |
| $Na^+$ សូដ្យូម | $Mg^{2+}$ ម៉ាញេស្យូម | | $Al^{3+}$ អាលុយមីញ៉ូម | | | $S^{2-}$ ស៊ុលផួ | $Cl^-$ ក្លរួ | គ្មាន |
| $K^+$ ប៉ូតាស្យូម | $Ca^{2+}$ កាល់ស្យូម | លោហៈឆ្លង | | | | | | |

*រូបទី 6 : អ៊ីយ៉ុងនៃធាតុមួយចំនួនក្នុងចំណោមធាតុ 20 ដំបូង*

# 4. សមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់

## 4.1 សមាសធាតុអ៊ីយ៉ុង

ការចងជាសម្ព័ន្ធអ៊ីយ៉ុងកើតឡើងតែរវាង**លោហៈ**និង**អលោហៈ**ប៉ុណ្ណោះ ។

តារាងទី 3 : ឧទាហរណ៍សមាសធាតុអ៊ីយ៉ុងមួយចំនួន

| សមាសធាតុអ៊ីយ៉ុង | ធាតុគីមី | | រូបមន្តគីមី |
|---|---|---|---|
| | លោហៈ | អលោហៈ | |
| សូដ្យូមក្លរួ (អំបិលសម្ល) | សូដ្យូម | ក្លរ | $NaCl$ |
| កាល់ស្យូមអុកស៊ីត (កំបោររស់) | កាល់ស្យូម | អុកស៊ីសែន | $CaO$ |
| កាល់ស្យូមកាបូណាត (ដីស) | កាល់ស្យូម | កាបូន និងអុកស៊ីសែន | $CaCO_3$ |
| ប៉ូតាស្យូមនីត្រាត | ប៉ូតាស្យូម | អាសូត និងអុកស៊ីសែន | $KNO_3$ |
| សូដ្យូមកាបូណាត(សូដាលាង) | សូដ្យូម | កាបូន និងអុកស៊ីសែន | $Na_2CO_3$ |
| សូដ្យូមកាបូណាតអាស៊ីត(ម្សៅដុតនំ) | សូដ្យូម | អ៊ីដ្រូសែន កាបូន និងអុកស៊ីសែន | $NaHCO_3$ |

For MPTC-EBooks Only




***រូបទី7 : សមាសធាតុអ៊ីយ៉ុង***

## 4.2 សមាសធាតុកូវ៉ាឡង់

សម្ព័ន្ធកូវ៉ាឡង់កើតឡើងតែរវាងអាតូមអលោហៈនិងអលោហៈប៉ុណ្ណោះ ។ អាតូមទាំងនេះអាចជាអាតូមប្រភេទដូចគ្នាឬជាអាតូមប្រភេទខុសគ្នា ។

តារាងទី4 : ឧទាហរណ៍សមាសធាតុកូវ៉ាឡង់មួយចំនួន

| សមាសធាតុកូវ៉ាឡង់ | អលោហៈ | រូបមន្តគីមី | ឃើញមាននៅ |
|---|---|---|---|
| អុកស៊ីសែន | អុកស៊ីសែនសុទ្ធ | $O_2$ | ក្នុងខ្យល់ |
| អាសូត | អាសូតសុទ្ធ | $N_2$ | ក្នុងខ្យល់ |
| មេតាន | កាបូន និងអ៊ីដ្រូសែន | $CH_4$ | ក្នុងឧស្ម័នធម្មជាតិ |
| ប៊ុយតាន | កាបូន និងអ៊ីដ្រូសែន | $C_4H_{10}$ | ដែកកេះហ្កាស |
| អុកតាន | កាបូន និងអ៊ីដ្រូសែន | $C_8H_{18}$ | ប្រេងសាំង |
| ស្ពាន់ធ័រឌីអុកស៊ីត | ស្ពាន់ធ័រ និងអុកស៊ីសែន | $SO_2$ | ក្នុងខ្យល់កង្វក់ |
| កាបូនឌីអុកស៊ីត | កាបូន និងអុកស៊ីសែន | $CO_2$ | បំពង់ពន្លត់អគ្គីភ័យ |
| អេតាណុល | កាបូន អ៊ីដ្រូសែន និងអុកស៊ីសែន | $C_2H_5OH$ | ស្រាបៀរ ស្រា |
| អាស៊ីតអេតាណូអ៊ិច | កាបូន អ៊ីដ្រូសែន និងអុកស៊ីសែន | $CH_3COOH$ | ទឹកខ្មេះ |
| គ្លុយកូស | កាបូន អ៊ីដ្រូសែន និងអុកស៊ីសែន | $C_6H_{12}O_6$ | គ្រឿងទេសសម្រាប់ធ្វើម្ហូប |

For MPTC-Ebooks Only




*រូបទី 8 : សមាសធាតុកូវ៉ាឡង់*

# 5. លក្ខណៈរបស់សមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់

ការប្រៀបធៀបរវាងសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់ គឺមានលក្ខណៈជាច្រើនដូចជា ចំណុចរំពុះ ចំណុចរលាយ កម្រិតរលាយក្នុងទឹក និងការចម្លងចរន្តអគ្គិសនីដូចដែលបានបង្ហាញក្នុង តារាងទី 5 ទំព័រទី (60) ។

## 5.1 ការប្រៀបធៀបលក្ខណៈរូប

សមាសធាតុអ៊ីយ៉ុង ជាអង្គធាតុរឹងដែលមានសីតុណ្ហភាពរលាយនិងរំពុះខ្ពស់ ។ នេះគឺដោយ សមាសធាតុអ៊ីយ៉ុងមានកម្លាំងទំនាញអេឡិចត្រូស្តាទិចខ្លាំងរវាងអ៊ីយ៉ុងដែលមានបន្ទុកផ្ទុយគ្នា ។ កម្លាំង នេះធ្វើឱ្យទម្រង់មានស្ថិរភាពហៅថា **បណ្តាញក្រាម** ដែលពិបាករលាយ ។ នៅក្នុងបណ្តាញក្រាមនេះ អ៊ីយ៉ុងតែងស្ថិតនៅផ្ទុំគ្នាជាប្រព័ន្ធទៀងទាត់មួយដើម្បីបង្កើតជាទ្រង់ទ្រាយទាំងមូលរបស់ក្រាម ។ ចំពោះ បណ្តាញក្រាមសូដ្យូមក្លរួ អ៊ីយ៉ុងស្ថិតនៅផ្ទុំគ្នាជាគូបដែលកំណត់ឱ្យក្រាមទាំងមូលមានរាងជាគូបដែរ ។



*រូបទី9 : ក្រាមអំបិលសូដ្យូមក្លរួនិងបណ្តាញក្រាមអំបិលសូដ្យូមក្លរួ*

For MPTC-Ebooks Only

តារាងទី 5 : លក្ខណៈរូបរបស់សមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់

| សម្ព័ន្ធ | សមាសធាតុ | ចំណុចរលាយ(°C) | ចំណុចរំពុះ (°C) | កម្រិតរលាយក្នុងទឹក | ការចម្លងចរន្ត (ពេលរលាយ) |
|---|---|---|---|---|---|
| អ៊ីយ៉ុង | សូដ្យូមក្លរួ | + 801 | + 1413 | រលាយ | ចម្លងបានល្អ |
| | ទង់ដែង(II) ក្លរួ | + 620 | + 990 | រលាយ | ចម្លងបានល្អ |
| | ប៉ូតាស្យូមប្រូមួ | + 728 | + 1376 | រលាយ | ចម្លងបានល្អ |
| | កាល់ស្យូមក្លរួ | + 778 | + 1600 | រលាយ | ចម្លងបានល្អ |
| កូវ៉ាឡង់ | មេតាន | –182 | –161 | មិនរលាយ | ចម្លងមិនបានល្អ |
| | កាបូនឌីអុកស៊ីត | - | - | រលាយតិចតួច | ចម្លងមិនបានល្អ |
| | ទឹក | 0 | + 100 | - | ចម្លងមិនបានល្អ |
| | អ៊ីយ៉ូត | + 114 | + 184 | រលាយតិចតួច | ចម្លងមិនបានល្អ |
| | ស្ពាន់ធ័រ | + 115 | + 444 | មិនរលាយ | ចម្លងមិនបានល្អ |

ជាទូទៅសមាសធាតុកូវ៉ាឡង់ជាឧស្ម័ន ជាអង្គធាតុរាវងាយហើរ ឬជាអង្គធាតុរឹងដែលមានចំណុចរលាយនិងរំពុះទាបមានន័យថាវាងាយហួតនិងបង្កើរជាក្លិន ។ដូចនេះហើយបានជាសមាសធាតុកូវ៉ាឡង់អាចប្រើជាគ្រឿងបង្កើនឱជារសឬជាគ្រឿងក្រអូប ។ ឥន្ធនភណ្ឌ ដូចជាប្រេងសាំងនិងឧស្ម័នធម្មជាតិ សារធាតុក្នុងបំពង់ពន្លត់អគ្គីភ័យនិងអាអេរ៉ូសុល សុទ្ធតែជាសមាសធាតុកូវ៉ាឡង់ ។

## 5.2 កម្រិតរលាយ

សមាសធាតុអ៊ីយ៉ុងភាគច្រើនតែងតែរលាយក្នុងទឹក ទោះបីទឹកជាសមាសធាតុកូវ៉ាឡង់ក៏ដោយ ។ នេះគឺដោយសារម៉ូលេគុលទឹកមានបន្ទុកដោយផ្នែកដែលផ្នែកខាងអុកស៊ីសែនមានបន្ទុកអវិជ្ជមាន ហើយផ្នែកខាងអ៊ីដ្រូសែនមានបន្ទុកវិជ្ជមាន ។ អ៊ីយ៉ុងវិជ្ជមានទាញផ្នែកអវិជ្ជមាននៃម៉ូលេគុលទឹក (ខាងអុកស៊ីសែន) ហើយអ៊ីយ៉ុងអវិជ្ជមានទាញផ្នែកវិជ្ជមាននៃម៉ូលេគុលទឹក(ខាងអ៊ីដ្រូសែន) ។ លំនាំរលាយនេះនឹងបង្ហាញក្នុងរូបទី 10 ខាងក្រោមនេះ :

For MoEYS-Ebooks Only




*រូបទី10 : ការរលាយនៃសារធាតុអ៊ីយ៉ុង*

សមាសធាតុកូវ៉ាឡង់ភាគច្រើនមិនរលាយក្នុងទឹកទេ ប៉ុន្តែវារលាយក្នុងសារធាតុរំលាយដូចជាអាល់កុល តេត្រាក្លរ៉ូមេតានឬប្រេងសាំង ។ សារធាតុទាំងនេះហៅថា **ធាតុរំលាយសរីរាង្គ**។ សមាសធាតុអ៊ីយ៉ុងមិនរលាយក្នុងធាតុរំលាយសរីរាង្គឡើយ ។

## 5.3 ការចម្លងចរន្តអគ្គិសនី

សមាសធាតុអ៊ីយ៉ុងជាអង្គធាតុរឹង វាមិនចម្លងចរន្តអគ្គិសនីទេ ប៉ុន្តែពេលវារលាយដោយកម្តៅ ឬរលាយក្នុងទឹក វាអាចចម្លងចរន្តអគ្គិសនីបាន ។ ការចម្លងអគ្គិសនីបាននេះ បណ្តាលមកពីបណ្តាញក្រាមអ៊ីយ៉ុងបានបំបែកធ្វើឱ្យអ៊ីយ៉ុងអាចផ្លាស់ទីបានហើយដោយសារអ៊ីយ៉ុងផ្លាស់ទីនេះហើយដែលដឹកនាំចរន្តអគ្គិសនី ។

សមាសធាតុកូវ៉ាឡង់ ចម្លងចរន្តអគ្គិសនីបានខ្សោយណាស់ ទោះបីវារលាយដោយកម្តៅក៏ដោយ នេះដោយសារវាមិនផ្ទុកអ៊ីយ៉ុងឡើយ តែវាកើតពីម៉ូលេគុលដែលមិនអាចដឹកនាំចរន្តអគ្គិសនីបាន ។




*រូបទី11 : ការបំបែកបណ្តាញក្រាមដោយកម្តៅ*



For MPTC-Ebooks Only

## មេរៀនសង្ខេប

- គ្រប់អាតូមទាំងអស់មានទំនោរទៅរកទម្រង់ដូចឧស្ម័ននិចល ។
- ក្នុងការចងសម្ព័ន្ធ មានតែអេឡិចត្រុងវ៉ាឡង់នៅស្រទាប់ក្រៅបង្អស់ប៉ុណ្ណោះដែលចូលរួម ។
- សម្ព័ន្ធកូវ៉ាឡង់គឺជាការហ៊ុនអេឡិចត្រុង ហើយវាបង្កើតបានជាម៉ូលេគុល ។
- សមាសធាតុកូវ៉ាឡង់ងាយៗមួយចំនួនមាន ទឹក $H_2O$ មេតាន $CH_4$ អាម៉ូញាក់ $NH_3$ និង កាបូនឌីអុកស៊ីត $CO_2$ ។
- ការចងជាសម្ព័ន្ធអ៊ីយ៉ុងទាក់ទងនឹងការផ្ទេរអេឡិចត្រុង ។
- អាតូមដែលបាត់បង់អេឡិចត្រុង កើតជាអ៊ីយ៉ុងវិជ្ជមាន ។ អាតូមដែលទទួលអេឡិចត្រុងកើតជាអ៊ីយ៉ុងអវិជ្ជមាន ។
- សម្ព័ន្ធអ៊ីយ៉ុង ធម្មតាកើតឡើងរវាងធាតុក្នុងក្រុម I ឬ II ជាមួយធាតុក្នុងក្រុម VI ឬ VII ។
- សមាសធាតុកូវ៉ាឡង់ មានសីតុណ្ហភាពរលាយ និងរំពុះទាប ភាគច្រើនមិនរលាយក្នុងទឹក និងមិនចម្លងចរន្តអគ្គិសនីនៅពេលរលាយដោយកម្តៅ ឬជាសូលុយស្យុង ។
- សមាសធាតុអ៊ីយ៉ុង មានសីតុណ្ហភាពរលាយ និងរំពុះខ្ពស់ រលាយក្នុងទឹក និងចម្លងចរន្តអគ្គិសនីនៅពេលរលាយដោយកម្តៅឬជាសូលុយស្យុង ។

## ? សំណួរនិងលំហាត់

**I.** ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវ

1. អាតូមមួយ ឬក្រុមអាតូមដែលមានបន្ទុកអគ្គិសនី គេហៅថា :

☐ ក. អេឡិចត្រុង ☐ ខ. ម៉ូលេគុល ☐ គ. ច្បាប់អដ្ឋតា ☐ ឃ. អ៊ីយ៉ុង

2. ពេលអាតូមម៉ាញេស្យូមមួយបានក្លាយទៅជាអ៊ីយ៉ុងម៉ាញេស្យូម មានន័យថា :

☐ ក. វាទទួលបាន 1 អេឡិចត្រុង ☐ ខ. វាទទួលបាន 2 អេឡិចត្រុង

☐ គ. វាទទួលបាន 2 ប្រូតុង ☐ ឃ. វាបាត់បង់ 2 អេឡិចត្រុង

3. តើធាតុគូណាមួយដែលមានទំនោរបង្កើតជាសម្ព័ន្ធកូវ៉ាឡង់ខ្លាំងជាងគេ ?

☐ ក. លីចូម និងភ្លុយអរ ☐ ខ. សូដ្យូម និងស្ពាន់ធ័រ

☐ គ. ម៉ាញេស្យូម និងអុកស៊ីសែន ☐ ឃ. កាបូន និងក្លរ

For MPTC-Ebooks Only

4. តើសមាសធាតុណាមួយដែលមានរបាយអេឡិចត្រុងដូចបង្ហាញក្នុងដ្យាក្រាម ?

☐ ក. ឧស្ម័នអ៊ីដ្រូសែន ☐ ខ. សូដ្យូមក្លរួ

☐ គ. ឧស្ម័នអុកស៊ីសែន ☐ ឃ. អ៊ីដ្រូសែនក្លរួ



5. តើភាគល្អិតណាមួយមាន 12 ណឺត្រុង 11 ប្រូតុង និង 10 អេឡិចត្រុង ?

☐ ក. $^{16}_{8}O^{2-}$ ☐ ខ. $^{19}_{9}F^{-}$ ☐ គ. $^{23}_{11}Na^{+}$ ☐ ឃ. $^{24}_{12}Mg^{2+}$

**II.** សំណួរត្រិះរិះ

1. ចូរបញ្ជាក់សមាសធាតុខាងក្រោម តើវាជាសមាសធាតុអ៊ីយ៉ុងឬកូវ៉ាឡង់និងបញ្ជាក់ពីហេតុផល

   ក. ទឹកសុទ្ធ ($H_2O$) ខ. ប៉ូតាស្យូមក្លរួ ($KCl$) គ. មេតាន ($CH_4$)

   ឃ. លីចូមភ្លុយអរួ ($LiF$) ង. ដីខ្សាច់ ($SiO_2$) ច. អ៊ីយ៉ូត ($I_2$) ឆ. ស្ពាន់ធ័រ ($S_8$)

2. ក្នុងចំណោមធាតុសូដ្យូម អុកស៊ីសែន ប៉ូតាស្យូម កាបូន ម៉ាញេស្យូម និងក្លរ ។ ចូរជ្រើសរើស

   ក. ធាតុមួយគូបង្កើតសមាសធាតុកូវ៉ាឡង់ ខ. ធាតុបួនគូបង្កើតសមាសធាតុអ៊ីយ៉ុង

   គ. ធាតុពីរជាម៉ូលេគុលឌីអាតូមក្នុងធម្មជាតិ ឃ. ធាតុពីរជាឧស្ម័ន

   ង. ធាតុដែលមានសីតុណ្ហភាពរលាយខ្ពស់បំផុត

3. ចូរបង្ហាញដោយប្រើដ្យាក្រាម "ចំណុចមូល ខ្វែង" នូវសម្ព័ន្ធនៃសមាធាតុកូវ៉ាឡង់ខាងក្រោម ។

   គេឱ្យចំនួនប្រូតុងរបស់ធាតុ C = 6, Cl = 17, O = 8, F = 9, H = 1 ។

   ក. ឧស្ម័នអ៊ីដ្រូសែនភ្លុយអរួ ($HF$) ខ. តេត្រាក្លរូមេតាន ($CCl_4$)

   គ. ឧស្ម័នអ៊ីដ្រូសែនក្លរួ ($HCl$) ឃ. ឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$)

4. ធាតុគីមីបី P, Q និង R មានចំនួនប្រូតុងចន្លោះពី 2 ទៅ 10 ។ ទម្រង់អាតូម P មានអេឡិចត្រុងច្រើនជាងទម្រង់ឧស្ម័ននិចលចំនួន 1 ទម្រង់អាតូម Q មានអេឡិចត្រុងច្រើនជាងទម្រង់ឧស្ម័ននិចលចំនួន 3 ចំណែកទម្រង់អាតូម R មានអេឡិចត្រុងតិចជាងទម្រង់ឧស្ម័ននិចលចំនួន 2 ។

   ក. ចូរប្រាប់ឈ្មោះធាតុ $P$ , $Q$ និង $R$ ?

   ខ. តើធាតុណាមួយមានទំនោរកើតជាអ៊ីយ៉ុងដែលមានបន្ទុក $(i) +1$ $(ii) -2$

   គ. ចូរសរសេររូបមន្តងាយមួយដែលកើតពីសមាសធាតុ $(i)$ $P$ និង $R$ $(ii)$ $Q$ និង $R$

   ឃ. តើជាប្រភេទសម្ព័ន្ធអ្វីដែលកើតឡើងរវាង $(i)$ $Q$ និង $R$ $(ii)$ អាតូម $R$ ពីរ ?

   ង. ក្នុងចំណោមធាតុទាំងបី ធាតុណាខ្លះជាលោហៈនិងធាតុណាខ្លះជាអលោហៈ ?

For MPTC-Ebooks Only

មេរៀនទី

# 2 ទម្រង់អង្គធាតុរឹង

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់លក្ខណៈសមាសធាតុដែលមានទម្រង់ជាម៉ូលេគុល ។
- ❒ រៀបរាប់ពីលក្ខណៈនិងទម្រង់របស់ពេជ្រ ។
- ❒ ពន្យល់ពីលក្ខណៈនិងទម្រង់របស់សមាសធាតុអ៊ីយ៉ុង ។
- ❒ រៀបរាប់ពីទម្រង់លោហៈនិងសម្ព័ន្ធលោហៈ ។
- ❒ ធ្វើពិសោធន៍ពីការរលាយរបស់សមាសធាតុកូវ៉ាឡង់និងកូវ៉ាឡង់ ធៀបទៅនឹងសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់ ។

ភាគល្អិតនៃអង្គធាតុរឹងតម្រៀបនិងផ្តុំគ្នាតាមរបៀបមួយបង្កើតជាទម្រង់បណ្តាញ ។ អង្គធាតុរឹងភាគច្រើនត្រូវបានបែងចែកជាបួនប្រភេទដោយអាស្រ័យទៅចំណុចរំពុះរបស់វានិងលក្ខខណ្ឌនៃការចម្លងចរន្តអគ្គិសនី ។ ការបែងចែកនេះនឹងបង្ហាញដូចដ្យាក្រាមខាងក្រោម ៖




For MPTC-Ebooks Only

# 1. ទម្រង់ម៉ូលេគុល

សារធាតុដែលមានទម្រង់ម៉ូលេគុលងាយៗ ផ្សំពីម៉ូលេគុលកូវ៉ាឡង់តូចៗជាច្រើន ។ *ឧទាហរណ៍* ទឹកផ្សំពីម៉ូលេគុលទឹកជាច្រើន ។ កម្លាំងរវាងម៉ូលេគុលទឹកនិងម៉ូលេគុលទឹក (គេហៅថាកម្លាំងអន្តរម៉ូលេគុល)ខ្សោយនិងងាយផ្តាច់ ។ ដូចនេះ ទឹកជាអង្គធាតុរាវអាចបំបែកទៅជាឧស្ម័នបានយ៉ាងងាយ ដោយដុតកម្តៅហើយពុះនៅសីតុណ្ហភាព 100°C ។ ពេលពុះទឹកក្លាយជាឧស្ម័នឬចំហាយមានតែកម្លាំងអន្តរម៉ូលេគុលខ្សោយប៉ុណ្ណោះបានផ្តាច់ ចំណែកសម្ព័ន្ធកូវ៉ាឡង់មាំក្នុងម៉ូលេគុលទឹកមិនត្រូវបានបំបែកទេ (រូបទី1) ។

សារធាតុផ្សេងទៀតដែលមានទម្រង់ជាម៉ូលេគុលក៏មានលក្ខណៈស្រដៀងគ្នានឹងទឹកដែរ ។ សារធាតុទាំងនោះមានកម្លាំងអន្តរម៉ូលេគុលខ្សោយងាយបំបែក ដូចនេះចំណុចរំពុះនិងចំណុចរលាយរបស់វាទាប (ជាធម្មតាទាបជាង 200°C ) ។

ធាតុអលោហៈភាគច្រើនមានទម្រង់ជាម៉ូលេគុលដូចជា អ៊ីដ្រូសែន អុកស៊ីសែន អាសូត និងធាតុនៅក្នុងក្រុម VII ។ សមាសធាតុកូវ៉ាឡង់ភាគច្រើនមានទម្រង់ជាម៉ូលេគុល ដូចជា $CO_2$ , $SO_2$ , $CH_4$ និង $CCl_4$ ។

ដោយសារធាតុដែលមានទម្រង់ជាម៉ូលេគុលមានចំណុចរំពុះទាប វាច្រើនតែជាសារធាតុងាយហើរ និងជាឧស្ម័ន ។ ម៉ូលេគុលរបស់វាងាយហួតនិងមានក្លិនសំគាល់ ។ គេច្រើនប្រើវាជាគ្រឿងក្រអូប និងគ្រឿងបន្ថែមឱជារស ។



*រូបទី1 : មានតែកម្លាំងអន្តរម៉ូលេគុលខ្សោយ ប៉ុណ្ណោះបានបំបែកពេលទឹកពុះ*

សារធាតុម៉ូលេគុលភាគច្រើនមិនរលាយក្នុងទឹកទេ ផ្ទុយទៅវិញវារលាយក្នុងសារធាតុរំលាយសរីរាង្គ ។ សារធាតុរំលាយសរីរាង្គគឺជាសមាសធាតុកាបូន ដូចជាប្រេងសាំងនិងអេតាណុលជាដើម ។

ដើម្បីអាចចម្លងចរន្តអគ្គិសនីបានសារធាតុនោះត្រូវមានអ៊ីយ៉ុងឬ**អេឡិចត្រុងសេរី** ។ ចំពោះសារធាតុដែលម៉ូលេគុលវាមិនមានអ៊ីយ៉ុងសេរីទេ ហើយអេឡិចត្រុងរបស់វាស្ថិតនៅក្នុងទីតាំងជាក់លាក់ក្នុងម៉ូលេគុល មិនអាចផ្លាស់ទីពីម៉ូលេគុលមួយទៅម៉ូលេគុលមួយទៀតបាន នេះហើយដែលធ្វើឱ្យសារធាតុដែលមានទម្រង់ជាម៉ូលេគុលមិនអាចចម្លងចរន្តអគ្គិសនីបាន ។

For MPTC-Ebooks Only

# 2. ទម្រង់ម៉ូលេគុលធំៗ

ពេជ្របង្កើតឡើងដោយធាតុកាបូន ។ នៅក្នុងពេជ្រអាតូមទាំងអស់ចងសម្ព័ន្ធនឹងគ្នាដោយសម្ព័ន្ធកូវ៉ាឡង់រឹងមាំ។ ពេជ្រគឺជាឧទាហរណ៍មួយនៃ **ទម្រង់ម៉ូលេគុលធំៗ** ដែលពេលខ្លះគេហៅថាទម្រង់**ម៉ាក្រូម៉ូលេគុល** ។ ម៉ាក្រូម៉ូលេគុល មានន័យថា " **ម៉ូលេគុលធំ** " ដែលអាចថាក្រាមពេជ្រទាំងមូលជាម៉ូលេគុលធំមួយ ។

ធាតុស៊ីលីស្យូម ប្រើសម្រាប់ធ្វើឈីប (IC) កុំព្យូទ័រនិងសមាសធាតុស៊ីលីស្យូមឌីអុកស៊ីត $SiO_2$ (មានក្នុងដីខ្សាច់) ក៏ជាសមាសធាតុដែលមានទម្រង់កូវ៉ាឡង់ធំដែរ ។




*រូបទី2 : ទម្រង់របស់ពេជ្រ ស៊ីលីស្យូមនិងស៊ីលីស្យូមឌីអុកស៊ីត*

## 2.1 លក្ខណៈរូប

សារធាតុដែលមានទម្រង់ជាម៉ូលេគុលកូវ៉ាឡង់ធំៗមានចំណុចរលាយនិងរំពុះខ្ពស់ ពីព្រោះវាត្រូវការថាមពលកម្ដៅខ្ពស់ ដើម្បីបំបែកសម្ព័ន្ធកូវ៉ាឡង់មាំរបស់វា ។ ពេជ្ររលាយនៅសីតុណ្ហភាពប្រហែល 3500°C ។ ចំណុចរលាយឬរំពុះរបស់សមាសធាតុកូវ៉ាឡង់ធំៗខុសគ្នាឆ្ងាយធៀបទៅនឹងសមាសធាតុកូវ៉ាឡង់តូចៗដែលមានចំណុចរលាយនិងរំពុះទាប ។

សម្ព័ន្ធកូវ៉ាឡង់មាំនេះធ្វើឱ្យសារធាតុទាំងនេះរឹងខ្លាំង ដែលគេអាចប្រើវាជាឧបករណ៍ដុសខាត់ឬក្បាលខួង ។ សារធាតុដែលមានទម្រង់ជាម៉ូលេគុលកូវ៉ាឡង់ធំៗមិនចម្លងចរន្តអគ្គិសនីនិងមិនរលាយក្នុងទឹកទេ ។

## 2.2 ពេជ្រ

នៅក្នុងពេជ្រ អាតូមកាបូននីមួយៗចងសម្ព័ន្ធទៅនឹងអាតូមកាបូន 4ផ្សេងទៀត តម្រៀបជាចតុមុខនិយ័ត ហើយអាតូមកាបូននីមួយៗជាផ្ចិតនៃចតុមុខនិយ័ត ។ សម្ព័ន្ធកូវ៉ាឡង់មាំនិងទម្រង់បណ្ដាញជាចតុមុខនិយ័តរបស់ពេជ្រធ្វើឱ្យវាជាសារធាតុធម្មជាតិដែលរឹងមាំបំផុត ។

ដោយសារភាពរឹងរបស់វា គេប្រើពេជ្រសម្រាប់កាត់វត្ថុរឹងផ្សេងទៀត ដូចជាក្បាលខួងត្រូវបានគេបំពាក់ពេជ្រដើម្បីខួងទម្លុះថ្មក្រោមដីរាប់ពាន់ម៉ែតដើម្បីបូមយកប្រេងកាតនិងឧស្ម័ន ។

For MPTC-EBooks Only

## 2.3 ក្រាភីត

**ក្រាភីត**គឺជាទម្រង់មួយផ្សេងទៀតរបស់កាបូន ។ នៅក្នុងក្រាភីត អាតូមកាបូនទាំងឡាយតម្រៀបគ្នាជាស្រទាប់រាបហើយអាតូមក្នុងស្រទាប់នីមួយៗតម្រៀបគ្នាជារង្វង់ដែលមាន 6 អាតូមកាបូន ។ អាតូមកាបូននីមួយៗចងសម្ព័ន្ធទៅនឹងអាតូមកាបូន3ផ្សេងទៀតដោយសម្ព័ន្ធកូវ៉ាឡង់ ។



ការតម្រៀបអាតូមក្នុងមួយស្រទាប់ ការតម្រៀបជាស្រទាប់

*រូបទី3 : ការតម្រៀបអាតូមនៅក្នុងក្រាភីត*

កម្លាំងទំនាញរវាងស្រទាប់នីមួយៗ ខ្សោយធ្វើឱ្យស្រទាប់នេះអាចរអិលលើគ្នាបាន ។ លក្ខណៈទាំងនេះហើយធ្វើឱ្យក្រាភីតទន់និងរអិល ។ ក្រាភីតក៏ដូចពេជ្រដែរ វាអាចស្ថិតនៅជាអង្គធាតុរឹងរហូតដល់សីតុណ្ហភាពខ្ពស់ខ្លាំង ( 4000°C ទើបវាក្លាយទៅជាឧស្ម័ន) ។

ក្រាភីតត្រូវបានគេប្រើធ្វើជាបណ្តូលខ្មៅដៃ ព្រោះតែស្រទាប់នៃអាតូមវារអិលដាច់ចេញពីខ្មៅដៃជិតទៅលើក្រដាស ។ គេក៏ប្រើវាជាសារធាតុរំអិលដែរ ជាពិសេសសម្រាប់ម៉ាស៊ីនដែលក្តៅខ្លាំងពីព្រោះវាមិនបំបែកទៅជាសារធាតុផ្សេងឡើយនៅសីតុណ្ហភាពខ្ពស់ ។

ក្រាភីត គឺជាអលោហៈដែលចម្លងចរន្តអគ្គិសនីបានល្អ ពីព្រោះវាផ្ទុកអេឡិចត្រុងដែលអាចផ្លាស់ទីដោយសេរីបាន ។ គេប្រើវាជាអេឡិចត្រូតក្នុងម៉ូទ័រអគ្គិសនី និងប្រើជាអេឡិចត្រូតប៉ូលបូកក្នុងថ្មពិលធម្មតា ។

## 3. ទម្រង់អ៊ីយ៉ុង

សមាសធាតុអ៊ីយ៉ុងបង្កដោយអ៊ីយ៉ុងវិជ្ជមាននៃលោហៈនិងអ៊ីយ៉ុងអវិជ្ជមាននៃអលោហៈ ។

***ឧទាហរណ៍ :*** សូដ្យូមក្លរួ គឺជាក្រាមដែលបង្កដោយអ៊ីយ៉ុង $Na^{+}$ និង $Cl^{-}$ ដ៏ច្រើនតម្រៀបគ្នាក្នុងរបៀបមួយទៀងទាត់ ។




*រូបទី4 : ការតម្រៀបអ៊ីយ៉ុងក្នុងសូដ្យូមក្លរួ*

For MPTC Ebooks Only

ទម្រង់ខាងលើបង្ហាញថាអ៊ីយ៉ុងសូដ្យូមនិងអ៊ីយ៉ុងក្លរួមានសមាមាត្រ 1:1 ដូចនេះរូបមន្តរបស់សូដ្យូមក្លរួគឺ NaCl ។ អ៊ីយ៉ុងនៅក្នុងក្រាមអ៊ីយ៉ុងចងភ្ជាប់ជាមួយគ្នាដោយសម្ព័ន្ធអ៊ីយ៉ុងមាំឬកម្លាំងទំនាញ**អេឡិចត្រូស្តាទិច** ។

សមាសធាតុអ៊ីយ៉ុងមានចំណុចរលាយនិងរំពុះខ្ពស់ ពីព្រោះវាត្រូវការថាមពលកម្តៅច្រើនដើម្បីបំបែកសម្ព័ន្ធអ៊ីយ៉ុង ។ ***ឧទាហរណ៍ :*** សូដ្យូមក្លរួរលាយនៅសីតុណ្ហភាព 801°C និងពុះនៅសីតុណ្ហភាព 1413°C ។

ចំណុចរលាយរបស់សមាសធាតុអ៊ីយ៉ុងអាស្រ័យលើកម្លាំងសម្ព័ន្ធរបស់អ៊ីយ៉ុងវា ។ ប្រសិនបើបន្ទុកវិជ្ជមាននិងអវិជ្ជមានរបស់អ៊ីយ៉ុងកាន់តែធំ នោះកម្លាំងទំនាញរបស់សម្ព័ន្ធកាន់តែខ្លាំង ហើយចំណុចរលាយនិងរំពុះកាន់តែខ្ពស់ ។ ***ឧទាហរណ៍ :*** ដូចជាម៉ាញេស្យូមអុកស៊ីតបង្កដោយអ៊ីយ៉ុងមានបន្ទុក +2 និង –2 ($Mg^{2+}$ , $O^{2-}$) មានសីតុណ្ហភាពរលាយខ្ពស់ជាងសូដ្យូមក្លរួដែលបង្កដោយអ៊ីយ៉ុងបន្ទុក +1 និង –1 ($Na^{+}$ , $Cl^{-}$) ។

សមាសធាតុអ៊ីយ៉ុងខ្លះមានសីតុណ្ហភាពរលាយខ្ពស់ ដូចជាម៉ាញេស្យូមអុកស៊ីត (MgO) វារលាយនៅសីតុណ្ហភាព 2800°C ។ គេប្រើវាដាក់នៅចន្លោះខាងក្នុងឡស្លលោហៈធាតុ ។

សមាសធាតុអ៊ីយ៉ុងមិនចម្លងចរន្តអគ្គិសនីទេពេលវាជាអង្គធាតុរឹង ។ ប៉ុន្តែពេលគេដុតកម្តៅយ៉ាងខ្លាំងវារលាយជាអង្គធាតុរាវហើយអាចចម្លងចរន្តអគ្គិសនីបាន ។ សមាសធាតុអ៊ីយ៉ុងក៏អាចចម្លងចរន្តអគ្គិសនីបានដែរនៅពេលរលាយក្នុងទឹក ។ នេះមកពីអ៊ីយ៉ុងរបស់វាអាចផ្លាស់ទីបាន ខុសពីក្នុងភាពជាអង្គធាតុរឹងដែលអ៊ីយ៉ុងវាមិនអាចផ្លាស់ទីបាន ។

## 4. ទម្រង់លោហៈ

នៅក្នុងលោហៈ អាតូមទាំងឡាយស្ថិតនៅផ្ទុំគ្នាយ៉ាងជិតបំផុតទៅតាមការតម្រៀបដ៏មានសណ្តាប់ធ្នាប់ ។ អាតូមនីមួយៗបានឱ្យអេឡិចត្រុងខ្លះហើយក្លាយទៅជាអ៊ីយ៉ុងវិជ្ជមាន ។ អេឡិចត្រុងទាំងនេះទៅនៅតាមចន្លោះអ៊ីយ៉ុងវិជ្ជមាន ។ **សម្ព័ន្ធលោហៈ** គឺជាកម្លាំងទំនាញរវាងអេឡិចត្រុងអវិជ្ជមាននិងអ៊ីយ៉ុងវិជ្ជមានរបស់លោហៈ ។




***រូបទី5 : (ក)ការតម្រៀបអាតូម (ខ)ការចងសម្ព័ន្ធនៅក្នុងលោហៈ***

For MPTC Ebooks Only

អ៊ីយ៉ុងលោហៈមានទំហំធំនិងមិនអាចផ្លាស់ទីបានទេ រីឯអេឡិចត្រុងតូចណាស់ ហើយអាចផ្លាស់ទីបានដោយសេរីពាសពេញលោហៈ ។ ដូចនេះគេអាចនិយាយបានថា លោហៈទាំងឡាយផ្ទុកទៅដោយអ៊ីយ៉ុងវិជ្ជមានដែលរុំព័ទ្ធទៅដោយអេឡិចត្រុងដ៏ច្រើនសន្ធឹកសន្ធាប់ ។ លោហៈចម្លងចរន្តអគ្គិសនីបានដោយសារអេឡិចត្រុងរបស់វាអាចផ្លាស់ទីបានដោយសេរីទោះបីវាស្ថិតជាអង្គធាតុរឹងឬពេលរលាយ ។

សម្ព័ន្ធលោហៈមានលក្ខណៈរឹងមាំខ្លាំង ដូចនេះហើយលោហៈភាគច្រើនមានសីតុណ្ហភាពរលាយនិងរំពុះខ្ពស់ ។

## តារាងសង្ខេបទម្រង់សំខាន់ៗនៃអង្គធាតុរឹង

| ទម្រង់ | ភាគល្អិតក្នុងអង្គធាតុរឹង | សម្ព័ន្ធរវាងភាគល្អិត | ចំណុចរំពុះ | កម្រិតរលាយក្នុងទឹក | ការចម្លងចរន្តអគ្គិសនី | ឧទាហរណ៍ |
|---|---|---|---|---|---|---|
| ម៉ូលេគុល | ជាម៉ូលេគុលកូវ៉ាឡង់តូចៗ | ខ្សោយណាស់ | ទាប | មិនរលាយ | មិនចម្លងចរន្តក្នុងគ្រប់ភាពរូប | មេតាន ទឹក អ៊ីយ៉ូត |
| ម៉ូលេគុលធំៗ | ជាអាតូម | សម្ព័ន្ធកូវ៉ាឡង់ | ខ្ពស់ | មិនរលាយ | មិនចម្លងចរន្តក្នុងគ្រប់ភាពរូប | ពេជ្រ ស៊ីលីស្យូមអុកស៊ីត |
| អ៊ីយ៉ុង | អ៊ីយ៉ុងវិជ្ជមាន និងអវិជ្ជមាន | សម្ព័ន្ធអ៊ីយ៉ុងមាំ | ខ្ពស់ | រលាយ | ចម្លងពេលរលាយ មិនចម្លងពេលជាអង្គធាតុរឹង | សូដ្យូមក្លរួ ម៉ាញេស្យូមអុកស៊ីត |
| លោហៈ | អ៊ីយ៉ុងវិជ្ជមាននិងអេឡិចត្រុងសេរី | អ៊ីយ៉ុងលោហៈមាំ | ខ្ពស់ | មិនរលាយ | ចម្លងពេលជាអង្គធាតុរឹង និងពេលរលាយ | ម៉ាញេស្យូម ដែក សូដ្យូម ទង់ដែង |

For MPTC-Ebooks Only

# ពិសោធន៍ការរលាយចូលរវាងសារធាតុកូវ៉ាឡង់និងសារធាតុអ៊ីយ៉ុង

ជាទូទៅការរលាយចូលគ្នា គឺសារធាតុដូចគ្នារលាយចូលគ្នា ប៉ុន្តែយើងបានដឹងរួចមកហើយថាទឹកជាសារធាតុកូវ៉ាឡង់ មេតានក៏ជាសារធាតុកូវ៉ាឡង់ ប៉ុន្តែវាបែរជាមិនរលាយចូលគ្នា។ តើនេះបណ្តាលមកពីមូលហេតុអ្វី ? ហើយហេតុអ្វីបានជាអំបិលសម្ល (NaCl) ជាសារធាតុអ៊ីយ៉ុងបែរជាអាចរលាយក្នុងទឹកដែលជាសារធាតុកូវ៉ាឡង់ ? តើវាមានអ្វីជាលក្ខណៈដូចគ្នា ?

ខាងក្រោមនេះជាលំនាំពិសោធន៍មួយ ដែលបកស្រាយពីការរលាយចូលគ្នានៃសារធាតុកូវ៉ាឡង់ និងសារធាតុអ៊ីយ៉ុង ។

## 1. វត្ថុបំណង

ប្រៀបធៀបការរលាយចូលគ្នារវាងសារធាតុកូវ៉ាឡង់ និងសារធាតុកូវ៉ាឡង់ ធៀបនឹងការរលាយនៃសារធាតុអ៊ីយ៉ុង និងសារធាតុកូវ៉ាឡង់ ។

## 2. ចំណេះដឹងទូទៅ

- សារធាតុកូវ៉ាឡង់មានពីរប្រភេទគឺ**កូវ៉ាឡង់ប៉ូលែ**និង**កូវ៉ាឡង់មិនប៉ូលែ** ។ សារធាតុ**កូវ៉ាឡង់ប៉ូលែ** បង្កឡើងពីអាតូមប្រភេទខុសគ្នា និងមានអាតូមមួយមានចំណូលអេឡិចត្រុងខ្លាំងធៀបនឹងអាតូមមួយទៀតបង្កើតជាបន្ទុកបូកនិងដក នៅភាគម្ខាងៗក្នុងម៉ូលេគុល(ដូចជាអាម៉ូញ៉ាក់ $NH_3$ ដែលអាតូម N មានចំណូលអេឡិចត្រុងខ្លាំងជាងអាតូមH ) ។ ចំណែកសារធាតុ***កូវ៉ាឡង់មិនប៉ូលែ*** បង្កឡើងពីអាតូមប្រភេទដូចគ្នាឬពីអាតូមប្រភេទខុសគ្នាដែលមានចំណូលអេឡិចត្រុងប្រហាក់ប្រហែលគ្នា ( ដូចជា ឧស្ម័នអុកស៊ីសែន ($O_2$) , ក្លរ ($Cl_2$), មេតាន ($CH_4$) ) ។
- សារធាតុអ៊ីយ៉ុងបង្កឡើងពីភាគល្អិតដែលមានបន្ទុកផ្ទុយគ្នា ដូចជា NaCl ($Na^+$ , $Cl^-$), $MgCl_2$ ($Mg^{2+}$ , $2Cl^-$) ។
- ការរលាយចូលគ្នារវាងសារធាតុកូវ៉ាឡង់ និងសារធាតុអ៊ីយ៉ុងកើតឡើងដោយសារបន្ទុកប៉ូលែរបស់សារធាតុកូវ៉ាឡង់ និងបន្ទុកវិជ្ជមាន ឬអវិជ្ជមានរបស់សារធាតុអ៊ីយ៉ុង ។

For MPTC Ebooks Only

## 3. សម្ភារពិសោធន៍

- ឧបករណ៍ : កែវជ័រចំនួន4 ចង្កឹះសម្រាប់កូរចំនួន4 ស្លាបព្រាញ៉ាំបាយ 1
- សារធាតុគីមី : ទឹកសុទ្ធ 1 ដប ស្ករស (សាក់ការ៉ូស) 1 ស្លាបព្រា ប្រេងសាំងប្រហែល 10 មីលីលីត្រ អំបិលសម្ល (NaCl) 1 ស្លាបព្រា ។

## 4. ដំណើរការពិសោធ

- ចាក់ទឹកសុទ្ធចូលទៅក្នុងកែវទាំងបួន (កែវ A, B, C និង D) ប្រហែលកន្លះកែវ ។
- វាល់ទឹកសុទ្ធ 1 ស្លាបព្រា រួចដាក់ចូលទៅក្នុងកែវ A រួចសង្កេតមើលនិងកត់ត្រាលទ្ធផលដាក់ក្នុងតារាងខាងក្រោម ។
- ធ្វើដូចដំណាក់កាលទី 2 ដែរ ដោយដាក់ស្ករស 1 ស្លាបព្រាទៅក្នុងកែវ B រួចយកចង្កឹះកូររយៈពេល 30 វិនាទី ។ សង្កេតមើល និងកត់ត្រាលទ្ធផលចូលក្នុងតារាងខាងក្រោម ។
- ធ្វើដូចករណីដាក់ស្ករដែរ ចំពោះប្រេងសាំង និងអំបិលដោយដាក់ទៅក្នុងកែវ C និង D រៀងគ្នា ។




## 5. លទ្ធផល

| កែវ | រលាយ | មិនរលាយ |
|---|---|---|
| A បន្ថែមទឹក | | |
| B បន្ថែមស្ករស | | |
| C បន្ថែមសាំង | | |
| D បន្ថែមអំបិល | | |

For MPTC-Ebooks Only

## ៦. ពិភាក្សា

ក. តើទឹកជាសារធាតុកូវ៉ាឡង់ប៉ូលែ ឬមិនប៉ូលែ ? ហេតុអ្វី ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ខ. សាក់ការ៉ូសមានរូបមន្ត $C_{12}H_{22}O_{11}$ និងតាមរយៈលទ្ធផលពិសោធន៍ តើវាជាសារធាតុអ៊ីយ៉ុង កូវ៉ាឡង់ប៉ូលែ ឬមិនប៉ូលែ ? ចូរពន្យល់ ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

គ. តាមរយៈលទ្ធផលពិសោធន៍ តើអ្នកគិតថាអំបិលអាចរលាយក្នុងប្រេងសាំងដែរ ឬទេ ? ហេតុអ្វី ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ឃ. ចំពោះការរលាយក្នុងទឹក ចូររៀបរាប់សារធាតុផ្សេងទៀតដែលមានលក្ខណៈដូចប្រេងសាំង ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

### មេរៀនសង្ខេប

- សារធាតុដែលមានទម្រង់ជាម៉ូលេគុលកូវ៉ាឡង់ធំៗ
  - មានសីតុណ្ហភាពរលាយ និងរំពុះខ្ពស់
  - មិនរលាយក្នុងទឹក
  - មិនចម្លងចរន្តអគ្គិសនី (លើកលែងក្រាភីត)
  - មានសភាពរឹងខ្លាំង (លើកលែងក្រាភីត)
- នៅក្នុងលោហៈធាតុ មានអ៊ីយ៉ុងវិជ្ជមាន និងអេឡិចត្រុងសេរី ។
- សម្ព័ន្ធលោហៈជាកម្លាំងទំនាញរវាងអ៊ីយ៉ុងវិជ្ជមានរបស់លោហៈនិងអេឡិចត្រុងអវិជ្ជមាន ។
- សម្ព័ន្ធលោហៈមាំខ្លាំង ដូចនេះទើបលោហៈមានសីតុណ្ហភាពរលាយ និងរំពុះខ្ពស់ ។
- លោហៈអាចចម្លងចរន្តអគ្គិសនីបាន ពីព្រោះវាមានអេឡិចត្រុងដែលអាចផ្លាស់ទីបានដោយសេរីក្នុងដុំលោហៈ ។

For MPTC Ebooks Only

## សំណួរនិងលំហាត់

1. តើលក្ខណៈណាខ្លះនៃក្រាភីត និងពេជ្រដែលពន្យល់ពីការប្រើប្រាស់របស់វាដូចខាងក្រោម ?

ក. ពេជ្រប្រើសម្រាប់ខួងធ្មេញ

ខ. ពេជ្រប្រើសម្រាប់កាត់កញ្ចក់

គ. ក្រាភីតប្រើជាអេឡិចត្រូតសម្រាប់ទាញយកលោហៈអាលុយមីញ៉ូម

ឃ. ពេជ្រត្រូវបានគេប្រើធ្វើជាកញ្ចក់បង្អួចនៃយានអវកាសគ្មានមនុស្សចុះនៅភពពុធ ហើយសីតុណ្ហភាពផ្ទៃខាងក្រៅគឺ 500°C ។

2. ហេតុអ្វីបានជាសំបកក្រូចថ្មីៗមានក្លិន ប៉ុន្តែអំបិលបែរជាគ្មានក្លិន ?

3. អាលុយមីញ៉ូមអុកស៊ីត គឺជាសមាសធាតុអ៊ីយ៉ុង ។ វាជាអង្គធាតុរឹងគេប្រើជាអ៊ីសូឡង់អគ្គិសនី ។ ហេតុអ្វីបានជាវាមិនចម្លងចរន្តអគ្គិសនី និងក្នុងលក្ខខណ្ឌអ្វីដែលវាអាចចម្លងចរន្តអគ្គិសនីបាន ?

4. តារាងខាងក្រោមនិយាយអំពីការចម្លងចរន្តអគ្គិសនីរបស់សារធាតុបីប្រភេទ :

| សារធាតុ | ការចម្លងចរន្តអគ្គិសនី | |
|---|---|---|
| | ពេលជាអង្គធាតុរឹង | ពេលជាអង្គធាតុរាវ |
| A | មិនចម្លងចរន្ត | មិនចម្លងចរន្ត |
| B | មិនចម្លងចរន្ត | ចម្លងចរន្ត |
| C | ចម្លងចរន្ត | ចម្លងចរន្ត |

ក. តើសារធាតុណាមួយជាសមាសធាតុអ៊ីយ៉ុង ?

ខ. តើសារធាតុណាមួយជាលោហៈ?

គ. តើសារធាតុណាមួយបង្កឡើងពីម៉ូលេគុលកូវ៉ាឡង់តូចៗ ?

5. សេស្យូម (Cs) គឺជាធាតុនៅក្នុងក្រុម I នៃតារាងខួប ។

ក. តើវាមានអេឡិចត្រុងប៉ុន្មាននៅស្រទាប់ក្រៅបង្អស់ ?

ខ. ចូរសរសេររូបមន្តអ៊ីយ៉ុងរបស់វា ។

គ. ចូរសរសេររូបមន្តអំបិលក្លរួរបស់វា ។

ឃ. ចូរសរសេររូបមន្តអុកស៊ីតរបស់វា ។

ង. ចូររៀបរាប់ពីសកម្មភាពគីមីរបស់វា ។

For MPTC Ebooks Only

## សំណួរនិងលំហាត់ជំពូក 3

**I.** ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយមួយដែលត្រឹមត្រូវ

1. តើសមាសធាតុអ៊ីយ៉ុងណាមួយដែលកម្លាំងអេឡិចត្រូស្តាទិចរវាងអ៊ីយ៉ុងរបស់វាខ្លាំងជាងគេ ?

☐ ក. លីចូមអុកស៊ីត ☐ ខ. ម៉ាញេស្យូមអុកស៊ីត

☐ គ. សូដ្យូមក្លរួ ☐ ឃ. ប៉ូតាស្យូមក្លរួ

2. តើគូធាតុណាមួយដែលបង្កើតបានសមាសធាតុដែលមានសមាមាត្រអាតូម 1:1 ?

☐ ក. ម៉ាញេស្យូម និងក្លរួ ☐ ខ. សូដ្យូម និងអុកស៊ីសែន

☐ គ. ប៉ូតាស្យូម និងភ្លុយអរ ☐ ឃ. លីចូម និងស្ពាន់ធ័រ

3. ភាគល្អិតដែលមាន 20 ប្រូតុង 20 ណឺត្រុង និង 18 អេឡិចត្រុងគឺជា

☐ ក. អ៊ីយ៉ុងវិជ្ជមាន ☐ ខ. ពួកអាឡូសែន

☐ គ. អាតូមលោហៈ ☐ ឃ. អ៊ីយ៉ុងអវិជ្ជមាន

4. សមាសធាតុដែលមិនមែនជាអ៊ីយ៉ុងប្រហែលជា

☐ ក. កើតពីធាតុអលោហៈពីរ ☐ ខ. សារធាតុមានចំណុចរលាយខ្ពស់

☐ គ. រលាយក្នុងទឹក ☐ ឃ. ចម្លងចរន្តអគ្គិសនីពេលរលាយដោយកម្ដៅ

5. ក្នុងចំណោមសមាសធាតុខាងក្រោម តើអំណះអំណាងពីកំណសម្ព័ន្ធអ៊ីយ៉ុងណាមួយដែលមិនត្រឹមត្រូវ ?

☐ ក. $K^{+}$ $Cl^{-}$ : មានការផ្ទេរ 1 អេឡិចត្រុង

☐ ខ. $(Na^{+})_2O^{2-}$ : មានការផ្ទេរ 2 អេឡិចត្រុង

☐ គ. $(Al^{3+})_2(O^{2-})_3$ : មានការផ្ទេរ 4 អេឡិចត្រុង

☐ ឃ. $Mg^{2+}(Cl^{-})_2$ : មានការផ្ទេរ 2 អេឡិចត្រុង

6. ចូរពិនិត្យតារាងប្រៀបធៀបលក្ខណៈសារធាតុម៉ាញេស្យូមភ្លុយអរួនិងភ្លុយអរខាងក្រោមនេះ ។ តើលក្ខណៈត្រង់ចំណុចណាដែលមិនត្រឹមត្រូវ ?

For MPTC Ebooks Only

| | លក្ខណៈ | |
|---|---|---|
| | ម៉ាញេស្យូមក្លរួ | ក្លរ |
| ក | ជាអង្គធាតុចម្លងចរន្តអគ្គិសនីបានពេលរលាយដោយកម្តៅ | ជាអង្គធាតុមិនអាចចម្លងចរន្តអគ្គិសនីបាន |
| ខ | ជាអង្គធាតុរឹងនៅសីតុណ្ហភាពបន្ទប់ | ជាឧស្ម័ននៅសីតុណ្ហភាពបន្ទប់ |
| គ | បង្កឡើងជាម៉ូលេគុល | បង្កឡើងជាបណ្តាញក្រាម |
| ឃ | មានសីតុណ្ហភាពរលាយខ្ពស់ | មានសីតុណ្ហភាពរលាយទាប |

**II.** សំណួរត្រិះរិះ

1. ក. ចូរសរសេររូបមន្តប្រភេទគីមី អ៊ីយ៉ុងនីត្រាតនិងអ៊ីយ៉ុងកាបូណាត ។

   ខ. លោហៈស្ត្រុងចូមបង្កើតជាអ៊ីយ៉ុងមាននិមិត្តសញ្ញា $Sr^{2+}$ ។ ចូរសរសេររូបមន្តសមាសធាតុ ស្ត្រុងចូមអុកស៊ីត ស្ត្រុងចូមក្លរួ និងស្ត្រុងចូមនីត្រាត ។

2. ស៊ីលីស្យូមឋិតនៅក្រោមធាតុកាបូននៅក្នុងក្រុមIV នៃតារាងខួប ។ តារាងខាងក្រោមនេះបង្ហាញពីចំណុចរលាយ និងចំណុចរំពុះនៃស៊ីលីស្យូម កាបូន (ពេជ្រ) និងអុកស៊ីតរបស់វា ។

| សារធាតុ | និមិត្តសញ្ញា ឬរូបមន្ត | ចំណុចរលាយ (°C) | ចំណុចរំពុះ (°C) |
|---|---|---|---|
| កាបូន | C | 3730 | 4530 |
| ស៊ីលីស្យូម | Si | 1410 | 2400 |
| កាបូនឌីអុកស៊ីត | $CO_2$ | ហើរនៅ –78 | |
| ស៊ីលីស្យូមឌីអុកស៊ីត | $SiO_2$ | 1610 | 2230 |

ក. នៅសីតុណ្ហភាពបន្ទប់ 20°C តើប្រភេទគីមីខាងលើនេះឋិតក្នុងភាពរូបអ្វី ?

ខ. តើទម្រង់របស់កាបូន (ពេជ្រ) ជាទម្រង់ម៉ូលេគុលកូវ៉ាឡង់ធំៗឬទម្រង់ម៉ូលេគុលធម្មតា ?

គ. តើអ្នកគិតថា ស៊ីលីស្យូមមានទម្រង់ជាអ្វី ? ចូរពន្យល់ ។

ឃ. នៅសីតុណ្ហភាពបន្ទប់ តើអុកស៊ីតទាំងពីរនេះឋិតក្នុងភាពរូបអ្វី ?

For MPTC-Ebooks Only

3. ដោយគិតពីភាពខុសគ្នានៃលក្ខណៈរូបនិងទម្រង់របស់ពេជ្រ ក្រាភីត និងលោហៈ ចូរពន្យល់ថាហេតុអ្វីបានជា ៖

ក. ក្រាភីតត្រូវបានប្រើជាបណ្តូលខ្មៅដៃ ?

ខ. ពេជ្រត្រូវបានគេប្រើជាឧបករណ៍សម្រាប់កាត់ ?

គ. ក្រាភីតត្រូវបានគេប្រើជាអេឡិចត្រូត ?

ឃ. ទង់ដែងត្រូវបានគេប្រើជាខ្សែចម្លង ?

ង. ដែកថែបត្រូវបានគេប្រើជាគ្រឿងកម្តៅ?

For MPTC-Ebooks Only

# ជំពូក 4 គីមីសរីរាង្គ




ឧបករណ៍ប្រើប្រាស់ និងគ្រឿងបរិភោគមួយចំនួនធំត្រូវបានផលិតចេញអំពីសមាសធាតុសរីរាង្គ ដូចជា : ថ្នាំពេទ្យ ទឹកអប់ សាប៊ូ បំពង់ទឹក ប្រអប់ដាក់ម្ហូបអាហារ . . . ។

គីមីសរីរាង្គជាសាខានៃគីមីដែលសិក្សាអំពីសមាសធាតុដែលមានធាតុកាបូនចូលផ្សំ ។ សមាសធាតុទាំងនេះមាននៅក្នុងធម្មជាតិឬបានមកពីវិធីសំយោគ ។ ក្នុងជំពូកនេះយើងនឹងសិក្សាអំពីសមាសធាតុដែលផ្សំដោយកាបូននិងអ៊ីដ្រូសែន ។

**មេរៀនទី 1 : ប្រេងកាតនិងឥន្ធនះ**

**មេរៀនទី 2 : អ៊ីដ្រូកាបួឆ្អែត : អាល់កាន**

**មេរៀនទី 3 : អ៊ីដ្រូកាបួមិនទាន់ឆ្អែត : អាល់សែននិងអាល់ស៊ីន**

**មេរៀនទី 4 : អ៊ីដ្រូកាបួប្រហើរ : បង់សែន**

មេរៀនទី

# 1 ប្រេងកាតនិងឥន្ធនៈ

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់ពីរបៀបកំណកំណើតនៃប្រេងកាតនិងឧស្ម័នធម្មជាតិ ។
- ❒ រៀបរាប់ពីសមាសភាពប្រេងកាតនិងឧស្ម័នធម្មជាតិ ។
- ❒ ពណ៌នាពីវិធីចម្រាញ់ប្រេងកាត (វិធីបំណិត) ។

## 1. ប្រេងកាត : *ប្រភពនៃអ៊ីដ្រូកាបួ*

ប្រេងកាតនិងឧស្ម័នធម្មជាតិមានដើមកំណើតពី**មីក្រូសារពាង្គកាយ**ដែលរស់នៅក្នុងសមុទ្ររាប់លានឆ្នាំកន្លងមកហើយ ។ ដំបូងសាកសពមីក្រូសារពាង្គកាយធ្លាក់ទៅគរផ្តុំគ្នានៅបាតសមុទ្រជាមួយ**កម្ទេចកំណ**ផ្សេងៗ ។ ក្រោមអំពើនៃសីតុណ្ហភាពនិងសម្ពាធខ្ពស់ ព្រមទាំងគ្មានអុកស៊ីសែន សាកសពមីក្រូសារពាង្គកាយទាំងនោះត្រូវបានបំបែកធាតុយឺតៗហើយបំប្លែងទៅជាប្រេងកាតនិងឧស្ម័នធម្មជាតិ ។ ប្រេងកាតនិងឧស្ម័នធម្មជាតិ ដែលកកើតមកនេះឋិតនៅចន្លោះស្រទាប់សិលាមិនជ្រាបទឹកនិងក្រោមសម្ពាធខ្លាំង ។ ដោយសារមានចលនាសំបកផែនដី វាក៏ផ្តុំគ្នាក្នុងសិលាឃ្លាំង (រូបទី 1) ។



*រូបទី 1 : អណ្តូងប្រេងកាត*

ប្រេងកាត ឧស្ម័នធម្មជាតិ និងធ្យូងថ្ម ហៅថា **ឥន្ធនៈផូស៊ីល** ដោយសារវាកកើតយឺតៗ ក្នុង**ធរណីកាល** ។ ប្រេងកាតនិងឧស្ម័នធម្មជាតិ ជាប្រភពថាមពលនិងវត្ថុធាតុដើមសម្រាប់ផលិតវត្ថុប្រើប្រាស់យ៉ាងច្រើន ។

For MPTC Books Only

ប្រេងកាតនិងឧស្ម័នធម្មជាតិកាលណាវារីងស្ងួត វាមិនអាចកកើតឡើងសាជាថ្មីទេ ។ តម្រូវការប្រេងកាតនិងឧស្ម័នធម្មជាតិកើនឡើងជារៀងរាល់ថ្ងៃ ។ សព្វថ្ងៃនេះគេកំពុងស្វែងរកប្រភពថាមពលផ្សេងទៀត ដើម្បីជំនួសថាមពលឥន្ធនៈផូស៊ីល ដូចជាថាមពលដែលបានមកអំពី**ជីវឧស្ម័ន** អេតាណុល អេស្ទែ . . . ។

**រ៉ែប្រេងកាតនៅកម្ពុជា**

តាមការស្រាវជ្រាវ កម្ពុជាមានកំណប់រ៉ែប្រេងកាតនិងឧស្ម័នធម្មជាតិដែរ ។ កម្ពុជានឹងចាប់ផ្តើមទាញផលប្រយោជន៍ពីកំណប់រ៉ែប្រេងកាតនៅពេលអនាគតឆាប់ៗ ។

## 1.1 ធាតុបង្កប្រេងកាត

ប្រេងកាតនៅជាសារធាតុខ្មៅអន្ធិល (រូបទី2) ។ វាជាល្បាយសាំញ៉ាំនៃ**អ៊ីដ្រូកាបួ** (សមាសធាតុដែលផ្សំដោយកាបូននិងអ៊ីដ្រូសែន) ច្រើនប្រភេទដែលមានសមាសភាពប្រែប្រួលមិនកំណត់ ។ ម៉ូលេគុលនៃអ៊ីដ្រូកាបួនៅក្នុងប្រេងកាតមានអាតូមកាបូនចាប់ពី 1 រហូតដល់ច្រើនជាង 50 ។ អ៊ីដ្រូកាបួដែលជាធាតុបង្កទាំងឡាយនៃប្រេងកាតនៅមានសីតុណ្ហភាពរំពុះខុសៗគ្នា ។ ដូចនេះគេបានអ៊ីដ្រូកាបួទាំងនោះ ដោយធ្វើបំណិតប្រភាគ ។



*រូបទី2 លំហូរប្រេងកាតនៅ*

## 1.2 ធាតុបង្កឧស្ម័នធម្មជាតិ

ឧស្ម័នធម្មជាតិជាល្បាយនៃអ៊ីដ្រូកាបួដែលម៉ូលេគុលវាមានអាតូមកាបូនចាប់ពី 1 ទៅដល់ 4 ។ ធាតុបង្កសំខាន់នៃឧស្ម័នធម្មជាតិគឺមេតាន (ប្រហែល 90%) ។

សមាសភាពប្រេងកាតនិងឧស្ម័នធម្មជាតិប្រែប្រួលតាមទីកន្លែងកកើតរបស់វា ។

# 2. ការចម្រាញ់ប្រេងកាត

ប្រេងកាតនៅដែលបូមមកពីអណ្តូងរ៉ែមិនអាចប្រើការបានទេ ។ ដូចនេះគេចាំបាច់ត្រូវចម្រាញ់វា គឺជម្រះភាពមិនសុទ្ធ (ខ្សាច់ ទឹកប្រៃ អ៊ីដ្រូសែនស៊ុលផួ . . .) បន្ទាប់មកញែកប្រភេទអ៊ីដ្រូកាបួនិងបំលែងម៉ូលេគុលអ៊ីដ្រូកាបួ ។



*រូបទី3 បំពង់បំណិតប្រេងកាតនេះអាចបិតប្រេងកាតនៅបានរហូតដល់30 000 តោនក្នុងមួយថ្ងៃ ។*

For MPTC-Ebooks Only

## 2.1 បំណិតប្រភាគនៃប្រេងកាត

ប្រេងកាតជាល្បាយអ៊ីដ្រូកាបួច្រើនយ៉ាង ។ ដំណាក់កាលដំបូងនៃដំណើរការចម្រាញ់ប្រេងកាតគឺគេញែកអ៊ីដ្រូកាបួជាក្រុមតូចៗដែលមានសីតុណ្ហភាពរំពុះប្រហាក់ប្រហែលគ្នា ។ លំនាំនេះប្រព្រឹត្តទៅតាមបច្ចេកទេសដែលហៅថា**បំណិតប្រភាគ** ។

ក្នុងឧស្សាហកម្មចម្រាញ់ប្រេងកាតគេធ្វើបំពង់បំណិត(រូបទី 3) ដែលមានថាសជាច្រើន (រូបទី 4) ។ គេដុតកម្ដៅប្រេងកាតឆៅនៅសីតុណ្ហភាព 380°C ហើយបញ្ជូនទៅក្នុងបំពង់បំណិត ។ ចំហាយដែលភាយឡើងកជាញើសនៅក្នុងថាសដែលមាននៅតាមថ្នាក់នីមួយៗ ។ ក្នុងបំពង់បំណិតមានសីតុណ្ហភាពចុះជាលំដាប់ពីក្រោមទៅលើ ។ នៅកំពូលបំពង់បំណិតគេទទួលបានឧស្ម័ន ។




*រូបទី4 : ថាសនៅក្នុងបំពង់បំណិត ។ ចលនាឡើងនៃចំហាយ និងចលនាចុះនៃអង្គធាតុរាវ ។*

ប្រេងកាតនៅត្រូវបានគេបិតជាពីរដំណាក់គឺ បំណិតក្នុងបរិយាកាសនិងបំណិតក្នុង**សុញ្ញកាស** ។

- បំណិតក្នុងបរិយាកាសជាបំណិតក្នុងសម្ពាធបរិយាកាស
- បំណិតក្នុងសុញ្ញកាសជាបំណិតក្រោមសម្ពាធខ្សោយ ។

កាកសំណល់ដែលមិនអាចញែកបាននៅបំណិតក្នុងបរិយាកាស គេបញ្ជូនវាទៅក្នុងបំពង់បំណិតក្នុងសុញ្ញកាសដើម្បីបំណិតបន្តទៀត ។

For MPTC-Ebooks Only

## 2.2 គំនូសបំប្រួញលំនាំចំណិតប្រេងកាតក្នុងឧស្សាហកម្ម




*រូបទី5 : ដំណើរប្រព្រឹត្តទៅនៃការចម្រាញ់ប្រេងកាត*

For MPTC-Ebooks Only

## 3. ក្រាគិញនៃផលិតផលប្រេងកាត

ការធ្វើបំណិតប្រភាគប្រេងកាត គេបានផលិតផលធ្ងន់ (ប្រភាគធ្ងន់)ច្រើនហួសពីសេចក្ដីត្រូវការ តែគេត្រូវការផលិតផលស្រាល (ប្រភាគស្រាល) ច្រើនជាង ។ ដើម្បីបំលែងផលិតផលធ្ងន់ទៅជាផលិតផលស្រាល គេត្រូវអនុវត្តវិធី ក្រាគិញ ។

### 3.1 និយមន័យ

ក្រាគិញជាប្រតិបត្តិការបំបែកម៉ូលេគុលធ្ងន់ឱ្យទៅជាម៉ូលេគុលស្រាលជាង ។

*ឧទាហរណ៍* : ក្រាគិញប៉ង់តាន

$$C_5H_{12} \rightarrow C_4H_8 + CH_4$$

$$2C_5H_{12} \rightarrow 2C_4H_8 + C_2H_6 + H_2$$

## 3.2 អនុវត្តន៍

ការធ្វើក្រាគិញផលិតផលធូន់នៅសីតុណ្ហភាព $500°C$ ក្រោមសម្ពាធនិងចំពោះមុខកាតាលីករ (សមាសធាតុបង្កើនល្បឿនប្រតិកម្ម) គេទទួលបានផលិតផលសំខាន់ៗគឺ

- ប្រេងសាំង
- មេតាន អេតាន ប្រូប៉ាន ប៊ុយតាន ជាឧស្ម័នឆេះ ។
- អេតែន ប្រូប៉ែន ប៊ុយតែន ប៊ុយតាឌៀន ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្ម : ប្លាស្ទិច សរសៃសំយោគ កៅស៊ូ អង្គធាតុជម្រះ ថ្នាំពេទ្យ . . . ។




*រូបទី6 : ផលិតផលសម្រេចដែលទទួលបានពីក្រាគិញណាប់តា*

# ញែកល្បាយអេតាណុល និងទឹកតាមវិធីបំណិត

## 1. វត្ថុបំណង

ដំឡើងនិងបំណាកស្រាយបំណិតល្បាយអេតាណុលនិងទឹក ។

## 2. សម្ភារពិសោធន៍

កែវបាឡុងមានខ្នែង ជើងទម្រ ចំពុះប៊ុនសិន ទែម៉ូម៉ែត កែវអ៊ែឡិន(កែវបាឡុង) បំពង់សីតករ បន្ទះអាម៉្យង់ ពែងអាកោ ។

## 3. ដំណើរការពិសោធ

- ដំឡើងឧបករណ៍ដូចបង្ហាញនៅក្នុងរូបទី 7 ។ ចាក់ស្រា 50mL ចូលក្នុងកែវបាឡុងមានខ្នែង ដាក់កណ្ដក់ទែម៉ូម៉ែតឱ្យចំមាត់ខ្នែងបាឡុង
- ដុតកម្ដៅថ្នមៗរហូតដល់ពុះ ។ ឈប់ដុតកម្ដៅពេលសីតុណ្ហភាពចាប់ផ្ដើមកើនឡើងម្ដងទៀត
- ត្រងផលបំណិតនៅក្នុងកែវអ៊ែឡិន ។




*រូបទី 7 : ពិសោធន៍ញែកល្បាយអេតាណុលនិងទឹក*

## 4. លទ្ធផល

- ស្រាចាប់ផ្ដើមពុះនៅសីតុណ្ហភាព . . . . °C ។
- យកផលបំណិត និងស្រាក្នុងកែវបាឡុង 2ឬ 3ដំណក់ដាក់ក្នុងកូនពែងអាកោពីរផ្សេងគ្នា ។ បន្ទាប់មកហិតក្លិន និងដុត ។ តើវាឆាប់ឆេះដែរ ឬទេ ? ចូរបំពេញតារាងខាងក្រោមនេះ ។

| | ក្លិន | ឆេះ | មិនឆេះ |
|---|---|---|---|
| ផលបំណិត | | | |
| ស្រាក្នុងកែវបាឡុង | | | |

For MPTC-Ebooks Only

## ៥. សំណួរពិភាក្សា

ក. តើអេតាណុលពុះនៅសីតុណ្ហភាពប៉ុន្មាន ?

ខ. តើធាតុបង្កសំខាន់នៃផលបំណិតគឺអ្វី ?

គ. តើសំណល់រាវនៅក្នុងកែវបាឡុងគឺអ្វី ?

**សំគាល់ :** - អេតាណុលពុះនៅសីតុណ្ហភាព 78.5°C ។

- គេអាចញែកធាតុបង្កនៃល្បាយអង្គធាតុរាវចេញពីគ្នាបាន លុះត្រាតែសីតុណ្ហភាពរំពុះនៃអង្គធាតុទាំងនោះខុសគ្នាធំជាង 10°C ។

**មេរៀនសង្ខេប**

- អ៊ីដ្រូកាបួជាសមាសធាតុសរីរាង្គផ្សំដោយអាតូម C និង H ។
- ប្រេងកាត និងឧស្ម័នធម្មជាតិជាឥន្ធនៈផូស៊ីល ។ វាជាល្បាយអ៊ីដ្រូកាបួដែលមិនអាចកើតឡើងវិញបានទេ ។
- បំណិតប្រភាគនៃប្រេងកាតទទួលបាន ឧស្ម័នឆេះ សាំង ណាប់តា កាស៊ាល់ ព្យូល (ប្រេងធ្ងន់) ប្រេងរំអិល និងប៊ីទូម ។
- ក្រាគិញជាលំនាំបំបែកម៉ូលេគុលធ្ងន់ទៅជាម៉ូលេគុលស្រាលជាង ។

## ? សំណួរនិងលំហាត់

1. ចូររាប់ឈ្មោះឥន្ធនៈផូស៊ីលទាំងបី ។
2. តើអ៊ីដ្រូកាបួផ្សំដោយធាតុគីមីអ្វីខ្លះ ?
3. តើប្រេងកាតជាអង្គធាតុសុទ្ធឬជាល្បាយ ?
4. តើបំណិតប្រភាគប្រេងកាតគេបានប្រភាគសំខាន់ៗអ្វីខ្លះ ?
5. ចូរឱ្យនិយមន័យក្រាគិញ ។
6. តើណាប់តាជាវត្ថុធាតុដើមសម្រាប់ធ្វើអ្វីខ្លះ ?

For MPTC-Ebooks Only

7. ចូរគូសសញ្ញា ✔ ក្នុងប្រអប់ខាងមុខចម្លើយណាមួយដែលត្រឹមត្រូវ ។

ក. ប្រេងកាតជាឥន្ធនៈផូស៊ីល ពីព្រោះវាបានកកើតរាប់លានឆ្នាំកន្លងមកហើយពី :

☐ 1. រុក្ខជាតិ ☐ 2. សត្វស្លាប

☐ 3. ដាយណូស័រ ☐ 4. មីក្រូសារពាង្គកាយ ។

ខ. ប្រេងកាតនៅជា :

☐ 1. សមាសធាតុសរីរាង្គសុទ្ធ ☐ 2. ល្បាយអ៊ីដ្រូកាបួរាវ

☐ 3. ប្រេងកាតសំរាប់ដុតបំភ្លឺ ☐ 4. ល្បាយសាំញ៉ាំនៃអ៊ីដ្រូកាបួ

គ. ក្នុងចំណោមសារធាតុខាងក្រោមនេះ តើណាមួយអាចកើតឡើងវិញបាន ?

☐ 1. ជីវឧស្ម័ន ☐ 2. ធ្យូងថ្ម

☐ 3. ឧស្ម័នធម្មជាតិ ☐ 4. ប្រេងកាត ។

For MPTC-Ebooks Only

មេរៀនទី

# 2 អ៊ីដ្រូកាបួឆ្អែត : អាល់កាន

**ចប់មេរៀននេះ សិស្សអាច**

- ❐ ពណ៌នាបានពីទម្រង់ខ្សែកាបូនក្នុងម៉ូលេគុលអាល់កាន ។
- ❐ សរសេររូបមន្តនិងហៅឈ្មោះ អាល់កាន ។
- ❐ សរសេរអ៊ីសូមែខ្សែកាបូន ។
- ❐ ពណ៌នាបានលក្ខណៈរូប ទង្វើ និងបម្រើបម្រាស់អាល់កាន ។
- ❐ សរសេរសមីការតុល្យការប្រតិកម្មចំហេះសព្វនិងជំនួស ។

អ៊ីដ្រូកាបួទាំងឡាយត្រូវបានបែងចែកជាក្រុមសំខាន់ៗទៅតាមប្រភេទសម្ព័ន្ធនៅចន្លោះអាតូមកាបូន ។ អ៊ីដ្រូកាបួឆ្អែតដូចជាអាល់កាន គឺបណ្ដាអ៊ីដ្រូកាបួដែលអាតូមកាបូននីមួយៗក្នុងម៉ូលេគុលវាភ្ជាប់ទៅអាតូម 4 ផ្សេងទៀត (អាតូម C ឬ H ) ។ ដូចនេះអាតូមកាបូនក្នុងម៉ូលេគុលអាល់កានភ្ជាប់គ្នាដោយសម្ព័ន្ធមួយជាន់ ។ អាល់កានមានរូបមន្តទូទៅ $C_nH_{2n+2}$ ( $n$ ជាចំនួនគត់វិជ្ជមាន) ។



*រូបទី1 : អាល់កានត្រូវបានប្រើជាប្រភពថាមពលសម្រាប់ដុតកម្ដៅ ។*

***ឧទាហរណ៍ :*** បើ $n = 1$ $CH_4$ មេតាន , $n = 2$ $C_2H_6$ អេតាន , $n = 3$ $C_3H_8$ ប្រូប៉ាន ។

For MPTC Ebooks Only

## 1. នាមវលី

### 1.1 នាមវលី ឬ ឈ្មោះអាល់កាន

#### ក. ឈ្មោះអាល់កានខ្សែទោល

- អាល់កាន 4 តួដំបូងមានឈ្មោះថា មេតាន អេតាន ប្រូប៉ាន និងប៊ុយតាន ។
- ចាប់ពីតួទី 5 ទៅគេត្រូវប្រើបុព្វបទក្រិចដែលបញ្ជាក់ពីចំនួនអាតូមកាបូននិងបច្ច័មបទ “**អាន**” ។

តារាងទី 1 : នាមវលីអាល់កាន

| ចំនួនអាតូមកាបូន n | រូបមន្ត | បុព្វបទ | ឈ្មោះ |
|---|---|---|---|
| 1 | $CH_4$ | គ្មាន | មេតាន |
| 2 | $C_2H_6$ | គ្មាន | អេតាន |
| 3 | $C_3H_8$ | គ្មាន | ប្រូប៉ាន |
| 4 | $C_4H_{10}$ | គ្មាន | ប៊ុយតាន |
| 5 | $C_5H_{12}$ | ប៉ង់ | ប៉ង់តាន |
| 6 | $C_6H_{14}$ | អិច | អិចសាន |
| 7 | $C_7H_{16}$ | អិប | អិបតាន |
| 8 | $C_8H_{18}$ | អុក | អុកតាន |
| 9 | $C_9H_{20}$ | ណូ | ណូណាន |
| 10 | $C_{10}H_{22}$ | ដេ | ដេកាន |

## ខ. នាមវលីបណ្តុំអាល់គីល

បើគេដកអាតូមអ៊ីដ្រូសែនមួយចេញពីម៉ូលេគុលអាល់កាន គេបាន **បណ្តុំអាល់គីល** ។ ឈ្មោះបណ្តុំអាល់គីលបានពីឈ្មោះអាល់កាន ដោយគ្រាន់តែជំនួស បច្ឆិមបទ**អាន** ដោយបច្ឆិមបទ**អ៊ីល**វិញ ។

*ឧទាហរណ៍ :* **អាល់កាន** ($C_nH_{2n+2}$) **បណ្តុំអាល់គីល** ($C_nH_{2n+1}$)

| អាល់កាន | | បណ្តុំអាល់គីល | |
|---|---|---|---|
| $CH_4$ | : មេតាន | $CH_3-$ | : មេទីល |
| $CH_3-CH_3$ | : អេតាន | $CH_3-CH_2-$ | : អេទីល |
| $CH_3-CH_2-CH_3$ | : ប្រូប៉ាន | $CH_3-CH_2-CH_2-$ | : ប្រូពីល |

## គ. នាមវលីអាល់កានខ្សែបែកខ្នែង

ដើម្បីហៅឈ្មោះអាល់កានខ្សែបែកខ្នែង គេត្រូវអនុវត្តតាមវិធានដូចតទៅ

- កំណត់ខ្សែកាបូនមេ គឺខ្សែកាបូនវែងជាងគេ ។ ឈ្មោះខ្សែកាបូនមេនេះយកតាមឈ្មោះអាល់កាន ។
- កំណត់អត្តសញ្ញាណបណ្តុំអាល់គីលដែលជាខ្នែង ។
- បង់លេខរៀងអាតូមកាបូនក្នុងខ្សែមេ ដើម្បីកំណត់សន្ទស្សន៍អាល់គីល ។ ការបង់លេខត្រូវធ្វើ

For MPTC-Ebooks Only

យ៉ាងណាឱ្យអាតូមកាបូនដែលមានខ្នែងមានលេខរៀងតូចជាងគេ ។

• បើមានបណ្តុំអាល់គីលដូចគ្នា 2 , 3 , 4 ... គេត្រូវប្រើបុព្វបទ **ឌី ទ្រី តេត្រា** . . . ។

ការហៅឈ្មោះអាល់កានត្រូវហៅតាមលំដាប់ដូចតទៅ

| ទីតាំងសន្ទស្សន៍ទាំងឡាយនៃបណ្តុំអាល់គីល + ឈ្មោះបណ្តុំអាល់គីល + ឈ្មោះខ្សែមេ |
|---|

*ឧទាហរណ៍ :*



2-មេទីលប្រូប៉ាន ឬមេទីលប្រូប៉ាន



2,2 -ឌីមេទីលប៊ុយតាន

## 1.2 ទម្រង់ម៉ូលេគុលអាល់កានងាយ

### ក. មេតាន

មេតានមានរូបមន្តម៉ូលេគុល $CH_4$ ។ អាតូមកាបូនមួយចងសម្ព័ន្ធកូវ៉ាឡង់ជាមួយអាតូមអ៊ីដ្រូសែនបួន ។ ម៉ូលេគុលមេតានមានទម្រង់ធរណីមាត្រជាចតុមុខនិយ័តដែលអាតូមកាបូនស្ថិតនៅចំផ្ចិតចតុមុខនិងអាតូមអ៊ីដ្រូសែនទាំង4 ស្ថិតនៅកំពូលទាំងបួននៃចតុមុខនិយ័ត (រូបទី2 ខ) ។



*រូបទី2 ក. គំនូសតាងឡឺវីសម៉ូលេគុលមេតាន ខ. ទម្រង់ចតុមុខម៉ូលេគុលមេតាន គ. គំរូឃ្លាតម៉ូលេគុលមេតាន*

### ខ. អេតាន

បើគេជំនួសអាតូមអ៊ីដ្រូសែនមួយនៃម៉ូលេគុលមេតាន ដោយបណ្តុំមេទីល ($-CH_3$) គេបានម៉ូលេគុលអេតាន ($CH_3-CH_3$) ដែលមានរូបមន្តម៉ូលេគុល $C_2H_6$ (រូបទី3) ។



*រូបទី3 ក. គំនូសតាងឡឺវីសអេតាន ខ. គំរូឃ្លាតម៉ូលេគុលអេតាន*

For MPTC Ebooks Only

## គ. ប្រូប៉ាន

បើគេជំនួសអាតូមអ៊ីដ្រូសែនមួយដោយបណ្តុំមេទីលមួយទៅក្នុងម៉ូលេគុលអេតាន គេបានម៉ូលេគុលប្រូប៉ាន ($CH_3-CH_2-CH_3$) ដែលមានរូបមន្តម៉ូលេគុល $C_3H_8$ (រូបទី 4) ។



*រូបទី4 ក. គំនូសតាងឡឺវីសប្រូប៉ាន*



*ខ. គំរូឃ្លាតម៉ូលេគុលប្រូប៉ាន*

បើគេជំនួសអាតូមអ៊ីដ្រូសែនដោយបណ្តុំមេទីល ($-CH_3$) បន្តទៀត គេនឹងបានស៊េរីនៃសមាសធាតុមួយហៅថា អាល់កានដែលមានរូបមន្តទូទៅ $C_nH_{2n+2}$ ($n \geq 1$) ។

## ឃ. រូបមន្តស៊ើរលាតនិងរូបមន្តលាត

គេនិយមតាងម៉ូលេគុលអាល់កានដោយរូបមន្តលាត និងស៊ើរលាតដូចបង្ហាញក្នុងតារាងទី 2 ។

តារាងទី **2** : រូបមន្តស៊ើរលាត និងរូបមន្តលាតរបស់អាល់កានមួយចំនួន

| *n* | រូបមន្តម៉ូលេគុល | រូបមន្តស៊ើរលាត | រូបមន្តលាត |
|---|---|---|---|
| 1 | $CH_4$ | $CH_4$ |  |
| 2 | $C_2H_6$ | $CH_3-CH_3$ |  |
| 3 | $C_3H_8$ | $CH_3-CH_2-CH_3$ |  |

## ង. អ៊ីសូមែខ្សែកាបូន

គេអាចជំនួសអាតូមអ៊ីដ្រូសែនដោយបណ្តុំមេទីលបានពីរយ៉ាងចាប់ពីប្រូប៉ានទៅ

- បើគេជំនួសអាតូមអ៊ីដ្រូសែននៅចុងខ្សែកាបូនគេបានអាល់កានខ្សែទោល

$CH_3-CH_2-CH_2-CH_3$ ឬ  : n-ប៊ុយតាន

- បើគេជំនួសអាតូមអ៊ីដ្រូសែននៅកណ្តាលខ្សែកាបូនគេបានអាល់កានខ្សែបែកខ្នែង

For MPTC-Ebooks Only



ឬ



: មេទីលប្រូប៉ាន

*n* -ប៊ុយតានឬប៊ុយតាន និងមេទីលប្រូប៉ានជាអ៊ីសូមែខ្សែកាបូន ។

**និយមន័យ** : សមាសធាតុពីរជាអ៊ីសូមែខ្សែកាបូន កាលណាវាមានរូបមន្តម៉ូលេគុលដូចគ្នា តែមានរូបមន្តលាតខុសគ្នា ជាហេតុនាំឱ្យវាមានលក្ខណៈរូបខុសគ្នា ។ (មើលតារាងទី 3) ។

តារាងទី 3 : លក្ខណៈខុសគ្នានៃអ៊ីសូមែខ្សែកាបូនទាំងពីរ

| ឈ្មោះអាល់កាន | ប៊ុយតាន | មេទីលប្រូប៉ាន |
|---|---|---|
| សីតុណ្ហភាពរលាយ | –139°C | –160.9°C |
| សីតុណ្ហភាពរំពុះ | –0.4°C | –10.2°C |

ចំនួនអ៊ីសូមែកើនឡើងរហ័សតាមកំណើនចំនួនអាតូមកាបូនក្នុងម៉ូលេគុល ។

$C_4H_{10}$ → អ៊ីសូមែ 2　　$C_6H_{14}$ → អ៊ីសូមែ 5

$C_5H_{12}$ → អ៊ីសូមែ 3　　$C_{10}H_{22}$ → អ៊ីសូមែ 75

## 2. លក្ខណៈរូប

អាល់កានរាវមិនរលាយក្នុងទឹកនិងស្រាលជាងទឹក តែវាអាចរលាយក្នុងធាតុរំលាយសរីរាង្គ ។ សីតុណ្ហភាពរំពុះនៃអាល់កានកាន់តែកើនឡើង កាលណាចំនួនអាតូមកាបូននៃម៉ូលេគុលកើនឡើង ។ អាល់កានបួនតួដំបូងជាឧស្ម័ន ចាប់ពីតួទីប្រាំដល់តួទីដប់ប្រាំជាអង្គធាតុរាវ និងចាប់ពីតួទីដប់ប្រាំមួយទៅជាអង្គធាតុរឹង (មើលតារាងទី 4) ។

តារាងទី 4 : ចំណុចរំពុះនិងភាពរូបនៃអាល់កាន

| អាល់កាន | ចំណុចរំពុះ °C | ភាពរូប |
|---|---|---|
| $CH_4$ | –162 | ឧស្ម័ន |
| $C_2H_6$ | –89 | ឧស្ម័ន |
| $C_3H_8$ | –42 | ឧស្ម័ន |
| $C_4H_{10}$ | –1 | ឧស្ម័ន |
| $C_5H_{12}$ | 36 | រាវ |
| . . . . . . . . . | . . . . . . . . . | រាវ |
| $C_{16}H_{34}$ | . . . . . . . . . | រឹង |

For MPTC-Ebooks Only

# 3. លក្ខណៈគីមី

## 3.1 ប្រតិកម្មចំហេះ

ចំហេះសព្វអាល់កានឱ្យផលជាទឹក កាបូនឌីអុកស៊ីត និងកម្តៅ(រូបទី5 ក) ។

$$CH_4 + 2O_2 \rightarrow CO_2 + 2H_2O$$

$$C_3H_8 + 5O_2 \rightarrow 3CO_2 + 4H_2O$$

បើបរិមាណអុកស៊ីសែនមិនគ្រប់គ្រាន់ ចំហេះអាល់កានឱ្យផលជា C , CO , $CO_2$ , និង$H_2O$ ។ ចំហេះបែបនេះគេហៅថា ចំហេះមិនសព្វ(រូបទី5ខ) ។




(ក) ពិសោធន៍ចំហេះសព្វមេតាននាំឱ្យបាន $H_2O$ និង $CO_2$

(ខ) ចំហេះមិនសព្វនៃសាំងឱ្យផ្សែងខ្មៅ

***រូបទី5 : ចំហេះសព្វនិងចំហេះមិនសព្វនៃអាល់កាន***

## 3.2 ប្រតិកម្មជំនួស

ប្រតិកម្មជំនួសមានចំពោះតែអ៊ីដ្រូកាបួឆ្អែត ដូចជាអាល់កាន ។ ក្រោមពន្លឺសាយនៃថ្ងៃមេតានមានប្រតិកម្មជាមួយក្លរ ដោយអាតូមអ៊ីដ្រូសែននៃមេតានត្រូវបានជំនួសដោយអាតូមក្លរ ។ ប្រតិកម្មនេះប្រព្រឹត្តរហូតដល់អស់អាតូមអ៊ីដ្រូសែនក្នុងម៉ូលេគុលមេតាន ។

$$\underset{\text{មេតាន}}{CH_4} + \underset{\text{ក្លរ}}{Cl_2} \xrightarrow{h\nu : \text{ពន្លឺសាយ}} \underset{\text{ម៉ូណូក្លរ៉ូមេតាន}}{CH_3Cl} + \underset{\text{អ៊ីដ្រូសែនក្លរួ}}{HCl}$$

$$CH_3Cl + Cl_2 \xrightarrow{\text{ពន្លឺសាយ}} \underset{\text{ឌីក្លរ៉ូមេតាន}}{CH_2Cl_2} + HCl$$

$$CH_3Cl_2 + Cl_2 \xrightarrow{\text{ពន្លឺសាយ}} \underset{\text{ទ្រីក្លរ៉ូមេតាន}}{CHCl_3} + HCl$$

$$CHCl_3 + Cl_2 \xrightarrow{\text{ពន្លឺសាយ}} \underset{\text{តេត្រាក្លរ៉ូមេតាន}}{CCl_4} + HCl$$

ទ្រីក្លរ៉ូមេតាន ឬក្លរ៉ូផម គេប្រើជាថ្នាំសណ្តំ ។ តេត្រាក្លរ៉ូមេតានជាអង្គធាតុរំលាយយ៉ាងល្អសម្រាប់រំលាយអង្គធាតុខ្លាញ់ ។

For MPTC-Ebooks Only

## 4. ធនធាននិងបម្រើប្រាស់

អាល់កានមាននៅក្នុងធម្មជាតិ ប្រភពសំខាន់នៃអាល់កានគឺប្រេងកាតនិងឧស្ម័នធម្មជាតិ ។ ក្នុងឧស្សាហកម្មចម្រាញ់ប្រេងកាត គេញែកអ៊ីដ្រូកាបួតាមក្រុម (ឬប្រភាគ)ដែលមានសីតុណ្ហភាពរំពុះប្រហាក់ប្រហែលគ្នា ។ អ៊ីដ្រូកាបួទាំងនេះមួយភាគធំជាអាល់កាន ។

គេប្រើអាល់កានជាប្រភពថាមពល ដូចជាចំហេះក្នុងម៉ាស៊ីននិងចង្ក្រានហ្គាស ។ អាល់កានក៏ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មគីមីដើម្បីសំយោគធ្វើគ្រឿងប្រើប្រាស់បានច្រើនយ៉ាងដូចជា : សរសៃសំយោគ ប្លាស្ទិច ថ្នាំពេទ្យ . . . ។

### មេរៀនសង្ខេប

- អាល់កានមានរូបមន្តទូទៅ : $C_nH_{2n+2}$ ។ ម៉ូលេគុលអាល់កានមានសម្ព័ន្ធមួយជាន់ : $C-C$ និង $C-H$ ។
- អាតូមកាបូនក្នុងម៉ូលេគុលអាល់កានមានទម្រង់ចតុមុខ ។
- អ៊ីសូមែខ្សែកាបូនជាសមាសធាតុដែលមានរូបមន្តម៉ូលេគុលដូចគ្នា តែរូបមន្តលាតខុសគ្នា ។
- ចំហេះសព្វនៃអាល់កានឱ្យផលជាទឹក កាបូនឌីអុកស៊ីត និងកម្ដៅ ។
- អាល់កានរងប្រតិកម្មជំនួស ពីព្រោះវាជាអ៊ីដ្រូកាបួឆ្អែត ។

### សំណួរនិងលំហាត់

1. ចូរសរសេររូបមន្តម៉ូលេគុលអាល់កានបួនតួដំបូង ។
2. ចូរសរសេររូបមន្តលាតរបស់អាល់កានដែលមានរូបមន្តម៉ូលេគុល $C_3H_8$ ។
3. ហៅឈ្មោះអាល់កានដែលមានរូបមន្តស៊ើរលាត : $CH_3-CH_2-CH_2-CH_3$ និង

$$\begin{array}{c}CH_3-\underset{\displaystyle CH_3}{\underset{|}{CH}}-CH_3\end{array}$$

។ តើអង្គធាតុទាំង 2 នេះជាអ៊ីសូមែនឹងគ្នាដែរឬទេ ?

4. ចូរសរសេររូបមន្តស៊ើរលាតអាល់កានដែលមានឈ្មោះដូចតទៅ :

ក. 2,2 - ឌីមេទីលប៉ង់តាន ខ. 3 - អេទីលប៉ង់តាន

For MPTC-Ebooks Only

5. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយណាមួយដែលត្រឹមត្រូវ ។

ក្រោមពន្លឺសាយនៃថ្ងៃ ក្លរមានអំពើជាមួយមេតានឱ្យផលជា

☐ ក. ក្លរ៉ូមេតាន និងអ៊ីដ្រូសែន

☐ ខ. ក្លរ៉ូមេតាន និងអ៊ីដ្រូសែនក្លរួ

☐ គ. ឌីក្លរ៉ូមេតាន និងអ៊ីដ្រូសែន

☐ គ. ឌីក្លរ៉ូមេតាន និងទ្រីក្លរ៉ូមេតាន ។

6. ចូរបំពេញសមីការតុល្យការចំហេះសព្វមួយម៉ូលអាល់កានដូចតទៅ

ក. $C_3H_8 + O_2 \rightarrow \ldots\ldots + \ldots\ldots H_2O$

ខ. $\ldots\ldots + \ldots\ldots O_2 \rightarrow 4CO_2 + \ldots\ldots$

គ. $\ldots\ldots + \ldots\ldots O_2 \rightarrow \ldots\ldots + 7H_2O$

ឃ. $\ldots + 2O_2 \rightarrow CO_2 + \ldots H_2O$

For MPTC-Ebooks Only

មេរៀនទី

# 3 អ៊ីដ្រូកាបួមិនទាន់ឆ្អែត

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពណ៌នាពីទម្រង់ម៉ូលេគុលអាល់សែននិងអាល់ស៊ីន ។
- ❒ ហៅឈ្មោះអាល់សែននិងអាល់ស៊ីន ។
- ❒ ពណ៌នាបានពីលក្ខណៈរូប លក្ខណៈគីមីនៃអាល់សែន និងអាល់ស៊ីន ។
- ❒ រៀបរាប់ពីទង្វើនិងបម្រើបម្រាស់អ៊ីដ្រូកាបួមិនទាន់ឆ្អែត ។

## 1. អាល់សែន

### 1.1 សេចក្តីផ្តើម





*រូបទី1 អាល់សែនមួយប្រភេទ(លីម៉ូណែន)មាននៅក្នុងសំបកផ្លែក្រូច ។ វាផ្តល់ក្លិនដល់ផ្លែក្រូច ។*

អ៊ីដ្រូកាបួមិនទាន់ឆ្អែតមានសម្ព័ន្ធពីរជាន់ឬបីជាន់ក្នុងម៉ូលេគុលចំនួនមួយឬលើសពីនេះ ។ អាតូមកាបូនអាចបង្កើតសម្ព័ន្ធពីរជាន់ឬបីជាន់យ៉ាងងាយជាមួយអាតូមកាបូនដទៃទៀត ។ អ៊ីដ្រូកាបួដែលមានសម្ព័ន្ធពីរជាន់យ៉ាងតិចចំនួនមួយនៅចន្លោះអាតូមកាបូនហៅថា **អាល់សែន** ។ អាល់សែនដែលមានសម្ព័ន្ធពីរជាន់មួយក្នុងម៉ូលេគុលមានអាតូមអ៊ីដ្រូសែនចំនួនពីរតិចជាងអាល់កានដែលត្រូវនឹងវា ។

*ឧទាហរណ៍ :*



$C_3H_8$ : ប្រូប៉ាន



$C_3H_6$ : ប្រូប៉ែន

អាល់សែនជាអ៊ីដ្រូកាបួខ្សែចំហដែលមានសម្ព័ន្ធពីរជាន់មួយក្នុងម៉ូលេគុល ។ រូបមន្តទូទៅគឺ $C_nH_{2n}$ , $(n \geq 2)$ ។

For MPTC-Ebooks Only

*ឧទាហរណ៍ :*

n = 2 : $C_2H_4$ អេទីឡែន ឬអេតែន

n = 3 : $C_3H_6$ ប្រូប៉ែន

n = 4 : $C_4H_8$ ប៊ុយតែន

……………………………………

## 1.2 នាមវលី

ឈ្មោះអាល់សែនត្រូវមានបុព្វបទទៅតាមចំនួនអាតូមកាបូនខ្សែមេដែលមានសម្ព័ន្ធ2ជាន់ និង បច្ឆិមបទ **អែន** ។

ការបង់លេខលើអាតូមកាបូនខ្សែមេ ត្រូវលៃឱ្យអាតូមកាបូនដែលមានសម្ព័ន្ធ2ជាន់ មានសន្ទស្សន៍តូចបំផុត ។ សន្ទស្សន៍ត្រូវដាក់ខាងឆ្វេងបច្ឆិមបទអែន ។

ការហៅឈ្មោះត្រូវគោរពតាមលំដាប់ដូចខាងក្រោម :

| |
|---|
| ទីតាំងបណ្តុំជំនួស **+** ឈ្មោះបណ្តុំជំនួស **+** បុព្វបទ **+** ទីតាំងសម្ព័ន្ធ2ជាន់ **+** បច្ឆិមបទអែន |

*ឧទាហរណ៍:*

$$\overset{1}{CH_3}-\overset{2}{CH}=\overset{3}{CH}-\overset{4}{CH_2}-\overset{5}{CH_3}$$

ប៉ង់ - 2 - អែន (មិនមែនប៉ង់ - 3 - អែនទេ)

$$\overset{1}{CH_2}=\overset{2}{CH}-\underset{CH_3}{\overset{3}{CH}}-\overset{4}{CH_3}$$

3- មេទីល ប៊ុយ - 1 - អែន

## 1.3 ទម្រង់ម៉ូលេគុលអាល់សែនងាយ

### ក. អេទីឡែនឬអេតែន

អេតែនមានរូបមន្តម៉ូលេគុល $C_2H_4$ ។ អាតូមទាំងប្រាំមួយឋិតនៅក្នុងប្លង់តែមួយ ។ ដើម្បីធានាតេត្រាវ៉ាឡង់នៃអាតូមកាបូនទាំងពីរវាត្រូវចងសម្ព័ន្ធនឹងគ្នាដោយសម្ព័ន្ធពីរជាន់ C = C (រូបទី2) ។

$$CH_2=CH_2$$

(ក)



(ខ)



(គ)

*រូបទី2 ក និងខ រូបមន្តស្ទើរលាត និងរូបមន្តលាតនៃអេតែន*

*គ. គំរូឃ្លាតនៃម៉ូលេគុលអេតែន*

For MPTC-Ebooks Only

## ខ. ប្រូប៉ែន

បើយើងជំនួសអាតូមអ៊ីដ្រូសែននៃអេតែនដោយបណ្តុំមេទីល ($-CH_3$) មួយយើងបានប្រូប៉ែន ដែលមានរូបមន្តម៉ូលេគុល $C_3H_6$ ។ ប្រូប៉ែនមានទម្រង់ម៉ូលេគុលដូចបង្ហាញក្នុងរូបទី3 ។

$$CH_3-CH=CH_2$$





*រូបទី3 ក. រូបមន្តស្ទើរលាតប្រូប៉ែន ខ. រូបមន្តលាតប្រូប៉ែន គ. គំរូឃ្លាតម៉ូលេគុលប្រូប៉ែន*

បើយើងចេះតែជំនួសអាតូមអ៊ីដ្រូសែនដោយបណ្តុំមេទីលបន្តទៅទៀត យើងនឹងបានស៊េរីអ៊ីដ្រូកាបួមួយប្រភេទហៅថា អាល់សែន ដែលមានរូបមន្តទូទៅ $C_nH_{2n}$ $(n \geq 2)$ ។

## 1.4 អ៊ីសូមែទីតាំងនិងអ៊ីសូមែខ្សែកាបូន

បើយើងជំនួសអាតូមអ៊ីដ្រូសែនក្នុងម៉ូលេគុលប្រូប៉ែន $CH_3-CH=CH_2$ ដោយបណ្តុំមេទីលមួយ យើងបានសមាសធាតុបីយ៉ាងគឺ

ក. $CH_2=CH-CH_2-CH_3$ : ប៊ុយ -1- អែន

ខ. $CH_3-CH=CH-CH_3$ : ប៊ុយ -2- អែន

គ. $CH_2=C(CH_3)-CH_3$ : មេទីលប្រូប៉ែន

**សមាសធាតុទាំងបីនេះជាអ៊ីសូមែនឹងគ្នា**

- (ក) និង (ខ) មានខ្សែកាបូនដូចគ្នា តែមានទីតាំងសម្ព័ន្ធ2ជាន់ខុសគ្នា វាជាអ៊ីសូមែទីតាំង ។
- (គ) មានខ្សែកាបូនមិនដូច (ក) និង (ខ) ។ វាជាអ៊ីសូមែខ្សែកាបូន ។

## 1.5 លក្ខណៈរូប

អាល់សែនបីតួដំបូង អេតែន ប្រូប៉ែន និងប៊ុយតែនជាឧស្ម័នគ្មានពណ៌ ។ ចាប់ពីប៉ង់តែនទៅជាអង្គធាតុរាវ ។ អាល់សែនមិនរលាយក្នុងទឹក តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ។ តារាងទី1 បង្ហាញពីចំណុចរំពុះនៃអាល់សែន ។

For MPTC-Ebooks Only

តារាងទី 1 : ចំណុចរំពុះអាល់សែនមួយចំនួន

| ឈ្មោះ | រូបមន្តស្ទើរលាត | ចំណុចរំពុះ (°C) |
|---|---|---|
| អេតែន | $CH_2 = CH_2$ | –104 |
| ប្រូប៉ែន | $CH_3 - CH = CH_2$ | –47 |
| ប៊ុយ -1- អែន | $CH_3 - CH_2 - CH = CH_2$ | –6.5 |
| ប៉ង់ -1- អែន | $CH_3 - CH_2 - CH_2 - CH = CH_2$ | 30 |

## 1.6 លក្ខណៈគីមីអាល់សែន

### ក. ប្រតិកម្មចំហេះ

ដូចអាល់កាន និងសមាសធាតុសរីរាង្គផ្សេងទៀតដែរ ចំហេះសព្វនៃអាល់សែនឱ្យផលជាកាបូនឌីអុកស៊ីតនិងទឹក ។ គេមិននិយមយកអាល់សែនធ្វើជាធាតុឆេះទេ ពីព្រោះវាជាវត្ថុធាតុដើមយ៉ាងសំខាន់សម្រាប់ឧស្សាហកម្មគីមី ។ ***ឧទាហរណ៍ :***

$$C_nH_{2n} + \frac{3n}{2}O_2 \longrightarrow nCO_2 + nH_2O$$

$$C_2H_4 + 3O_2 \longrightarrow 2CO_2 + 2H_2O$$

### ខ. ប្រតិកម្មបូក

អាល់សែនមានលក្ខណៈសកម្មជាងអ៊ីដ្រូកាបួឆ្អែត ដោយសារវាមានវត្តមានសម្ព័ន្ធពីរជាន់ក្នុងម៉ូលេគុល ។ ប្រតិកម្មបូកលើម៉ូលេគុលអាល់សែនងាយជាងប្រតិកម្មជំនួស ។

- **អ៊ីដ្រូសែនកម្ម**

អ៊ីដ្រូសែនកម្មជាប្រតិកម្មបូកអ៊ីដ្រូសែន ។ ចំពោះមុខកាតាលីករ( Ni ឬ Pt )និងសីតុណ្ហភាព 180°C អេតែនមានប្រតិកម្មបូកជាមួយអ៊ីដ្រូសែនបង្កើតបានជាអាល់កានដែលត្រូវគ្នានឹងវាគឺ អេតាន ។

$$\underset{\text{អេតែន}}{CH_2 = CH_2} + \underset{\text{អ៊ីដ្រូសែន}}{H_2} \xrightarrow{\text{Ni ឬ Pt}} \underset{\text{អេតាន}}{CH_3 - CH_3}$$

- **អាឡូសែនកម្ម**

អាឡូសែនកម្មជាប្រតិកម្មបូកជាមួយអាឡូសែន ។ ឧទាហរណ៍ :

$CH_2 = CH_2 + Cl_2 \longrightarrow CH_2Cl - CH_2Cl$ (1,2- ឌីក្លរ៉ូអេតាន)

$CH_2 = CH_2 + Br_2 \longrightarrow CH_2Br - CH_2Br$ (1,2- ឌីប្រូម៉ូអេតាន)

គេប្រើទឹកប្រូមសម្រាប់ធ្វើតេសរកវត្ថុមានអ៊ីដ្រូកាបួមិនទាន់ឆ្អែត (រូបទី 4) ។




*រូបទី4 : ទឹកប្រូមមានពណ៌ក្រហមទឹកក្រូច ប្រែជាគ្មានពណ៌នៅពេលឧស្ម័នអេតែនឆ្លងកាត់*

- **អ៊ីដ្រាតកម្ម**

អ៊ីដ្រាតកម្មជាប្រតិកម្មបូកទឹក ។ ទឹកមានអំពើលើអាល់សែនឱ្យផលជាអាល់កុល ។ ***ឧទាហរណ៍ :***

$$\underset{\text{អេតែន}}{CH_2 = CH_2} + \underset{\text{ទឹក}}{H - OH} \xrightarrow{H^+} \underset{\text{អេតាណុល}}{CH_3 - CH_2OH}$$

$CH_3 - CH = CH_2 + H\text{–}OH \longrightarrow CH_3 - CH_2 - CH_2OH$ (ប្រូប៉ាន -1- អុល)

ឬ $CH_3 - CHOH - CH_3$ (ប្រូប៉ាន -2- អុល)

- **ប៉ូលីមែកម្ម**

ប៉ូលីមែកម្មជាប្រតិកម្មបូកម៉ូលេគុលមិនទាន់ឆ្អែត (**ម៉ូណូមែ**) រវាងគ្នា និងគ្នា ឱ្យជាសមាសធាតុដែលមានម៉ូលេគុលធំ (**ប៉ូលីមែ**) ។ ***ឧទាហរណ៍***

- ប៉ូលីមែកម្មអេតែន :

$$\underset{\text{អេតែន}}{nCH_2 = CH_2} \longrightarrow \underset{\text{ប៉ូលីអេតែន : PE}}{\left( CH_2 - CH_2 \right)_n}$$

- ប៉ូលីមែកម្មវីនីលក្លរួ :

$$\underset{\text{វីនីលក្លរួ}}{nCH_2 = CHCl} \longrightarrow \underset{\text{ប៉ូលីវីនីលក្លរួ P.V.C}}{\left( CH_2 - CHCl \right)_n}$$

## 1.7 ទង្វើនិងបម្រើបម្រាស់អាល់សែន

### ក. ទង្វើអាល់សែន

ម៉ូលេគុលអាល់សែនបានមកពីការធ្វើក្រាគិញនៃអាល់កាន ដែលយើងបានសិក្សានៅក្នុងមេរៀនប្រេងកាត និងឥន្ធនៈ ។ រូបទី 5 បង្ហាញអំពីលំនាំក្រាគិញនៃអាល់កានចំពោះមុខកាតាលីករ $Al_2O_3$ ក្នុងឧស្សាហកម្មចម្រាញ់ប្រេងកាត ។

For MPTC-Ebooks Only




*រូបទី5 : លំនាំនៃការផលិតអាល់សែនតាមវិធីក្រាគិញអាល់កាន*

## ខ. បម្រើបម្រាស់អាល់សែន

ដូចបានរៀបរាប់នៅក្នុងផ្នែកខាងដើម អេតែនជាវត្ថុធាតុដើមសម្រាប់ធ្វើវត្ថុធាតុគីមីជាច្រើន ។ រូបទី 6 បង្ហាញអំពីផលិតផលសម្រេច ដែលបានមកពីអង្គធាតុស្រឡាយអេតែន ។




*រូបទី6 : ផលិតផលបានអំពីអង្គធាតុស្រឡាយអេតែន*

# 2. អាល់ស៊ីន

## 2.1 សេចក្តីផ្តើម

អ៊ីដ្រូកាបួមិនទាន់ឆ្អែតស៊េរីអាល់ស៊ីនមានសម្ព័ន្ធបីជាន់យ៉ាងតិចចំនួនមួយនៅចន្លោះអាតូមកាបូន ។ អាល់ស៊ីនងាយជាងគេគឺអេទីន$C_2H_2$ ។ អាល់ស៊ីនមានរូបមន្តទូទៅ: $C_nH_{2n-2}$ ; $(n \geq 2)$ ។

*ឧទាហរណ៍ :* $n = 2$ : $C_2H_2$ អាសេទីឡែន ឬ អេទីន

$n = 3$ : $C_3H_4$ ប្រូពីន

$n = 4$ : $C_4H_6$ ប៊ុយទីន

n = 5 : …………………

## 2.2 នាមវលីអាល់ស៊ីន

អាល់ស៊ីនជាស៊េរីអ៊ីដ្រូកាបួដែលមានសម្ព័ន្ធបីជាន់ក្នុងម៉ូលេគុល ។ ឈ្មោះអាល់ស៊ីនបានមកពីឈ្មោះអាល់សែន តែមានបច្ឆិមបទ **អ៊ីន** ។

*ឧទាហរណ៍ :* $CH \equiv C-CH_2-CH_3$
ប៊ុយ - 1 - អ៊ីន

### ក. ទម្រង់ម៉ូលេគុលអាល់ស៊ីនងាយ

- **អេទីនឬអាសេទីឡែន**

អេទីនមានរូបមន្តម៉ូលេគុល $C_2H_2$ ។ អាតូមទាំងបួនរត់ត្រង់ជួរគ្នា។ ដើម្បីធានាតេត្រាវ៉ាឡង់នៃអាតូមកាបូនទាំងពីរ វាត្រូវចងសម្ព័ន្ធនឹងគ្នាជាសម្ព័ន្ធបីជាន់ $C \equiv C$ (រូបទី 7) ។

$$H - C \equiv C - H$$



*រូបទី7 : ក. រូបមន្តលាតអេទីន* *ខ. គំរូឃ្លាតម៉ូលេគុលអេទីន*

- **ប្រូពីន**

ប្រូពីនមានទម្រង់ម៉ូលេគុលដូចរូបទី 8 ។



*រូបទី8 : គំរូឃ្លាតម៉ូលេគុលប្រូពីន*

### ខ. អ៊ីសូមែ

អាល់ស៊ីនមានអ៊ីសូមែទីតាំង និងអ៊ីសូមែខ្សែកាបូនដូចអាល់សែនដែរ ។

*ឧទាហរណ៍ :* អ៊ីសូមែប៊ុយទីន $C_4H_6$ ។

$CH \equiv C-CH_2-CH_3$ ប៊ុយ -1- អ៊ីន

$CH_3-C \equiv C-CH_3$ ប៊ុយ -2- អ៊ីន

For MPTC-Ebooks Only

## 2.3 លក្ខណៈរូប

អាសេទីឡែនជាឧស្ម័នគ្មានពណ៌ស្រាលជាងខ្យល់និងរលាយក្នុងទឹកបានតិចតួច ។ចំពោះអាល់ស៊ីនដទៃទៀតមានសីតុណ្ហភាពរំពុះកើនឡើងតាមចំនួនអាតូមកាបូនកើនឡើងក្នុងម៉ូលេគុល(តារាងទី 2) ។

តារាងទី **2** : ចំណុចរំពុះអាល់ស៊ីនមួយចំនួន

| ឈ្មោះ | រូបមន្តស្ទើរលាត | ចំណុចរំពុះ (°C) |
|---|---|---|
| អេទីន | $HC \equiv CH$ | –84 |
| ប្រូពីន | $CH_3 - C \equiv CH$ | –23 |
| ប៊ុយ -1- អ៊ីន | $CH_3 - CH_2 - C \equiv CH$ | 8 |
| ប៉ង់ -1- អ៊ីន | $CH_3 - CH_2 - CH_2 - C \equiv CH$ | 39 |

## 2.4 លក្ខណៈគីមីអាល់ស៊ីន

អាល់ស៊ីនមានលក្ខណៈសកម្មជាងអាល់កានដោយសារវត្តមានសម្ព័ន្ធបីជាន់ក្នុងម៉ូលេគុល ។

### ក. ប្រតិកម្មចំហេះ

អេទីនឬអាសេទីឡែនជាធាតុឆេះយ៉ាងខ្លាំងក្លា ។ ចំហេះរបស់វាផ្តល់សីតុណ្ហភាពរហូតដល់ 3000°C ។ គេប្រើវាក្នុងចំពុះផ្សារសម្រាប់ផ្សារនិងកាត់ដែកថែប (រូបទី 9) ។

$$C_2H_2 + \frac{5}{2}O_2 \longrightarrow 2CO_2 + H_2O$$



*រូបទី9 : ចំពុះផ្សារប្រើធាតុឆេះអាសេទីឡែន*

### ខ. ប្រតិកម្មបូកអ៊ីដ្រូសែន ឬអ៊ីដ្រូសែនកម្ម

នៅចំពោះមុខកាតាលីករ Ni ឬ Pt និងនៅសីតុណ្ហភាព 180°C អេទីនធ្វើប្រតិកម្មបូកជាមួយអ៊ីដ្រូសែន បង្កើតបានជាអាល់កានដែលត្រូវគ្នានឹងវា គឺអេតាន ។

$$\underset{\text{អេទីន}}{CH \equiv CH} + \underset{\text{អ៊ីដ្រូសែន}}{2H_2} \longrightarrow \underset{\text{អេតាន}}{CH_3 - CH_3}$$

### គ. អាឡូសែនកម្ម

អេទីនអាចមានប្រតិកម្មបូកជាមួយប្រូមបានមួយឬពីរម៉ូលេគុល ។

$$CH \equiv CH + Br_2 \longrightarrow BrHC = CHBr$$ ( 1,2-ឌីប្រូម៉ូអេតែន)

$$CH \equiv CH + 2Br_2 \longrightarrow Br_2HC - CHBr_2$$ ( 1,1,2,2 - តេត្រាប្រូម៉ូអេតាន)

### ឃ. អ៊ីដ្រាតកម្ម

អេទីនមានប្រតិកម្មជាមួយទឹកឱ្យផលជាអេតាណាល់ ។

$$CH \equiv CH + H_2O \longrightarrow CH_3 - C\begin{matrix} \diagup O \\ \diagdown H \end{matrix}$$ (អេតាណាល់)

អេតាណាល់ជាផលិតផលយ៉ាងសំខាន់សម្រាប់ធ្វើអេតាណុល និងអាស៊ីតអេតាណូអ៊ិច ។

### ង. ប្រតិកម្មបូកអ៊ីដ្រូសែនក្លរួ

ប្រតិកម្មរវាងអេទីននិងអ៊ីដ្រូសែនក្លរួ ប្រព្រឹត្តទៅពីរដំណាក់ដូចខាងក្រោម

ដំណាក់ទី 1 : $CH \equiv CH + H - Cl \longrightarrow CH_2 = CHCl$

(វីនីលក្លរួ)

ដំណាក់ទី 2 : $CH_2 = CHCl + H - Cl \longrightarrow CH_3 - CHCl_2$

(1,1 - ឌីក្លរ៉ូអេតាន)

នៅដំណាក់ទី 2 នេះអាតូមក្លរទាំងពីរភ្ជាប់ជាមួយអាតូមកាបូនតែមួយ ។

## 2.5 ទង្វើនិងបម្រើបម្រាស់

### ក. ទង្វើអាសេទីឡែន

អាសេទីឡែនក៏ដូចជាអាល់ស៊ីនដទៃទៀតដែរ គ្មាននៅក្នុងធម្មជាតិទេ ។ គេអាចធ្វើអាសេទីឡែនដោយអំពើនៃទឹកលើកាល់ស្យូមកាប៊ួ (ថ្មស្អុយ) ។

$$CaC_2 + 2H_2O \longrightarrow C_2H_2\uparrow + Ca(OH)_2$$

### ខ. បម្រើបម្រាស់

នៅក្នុងផ្នែកទី 2-4 បង្ហាញឱ្យឃើញថា អេទីនចូលរួមប្រតិកម្មបូកច្រើនបែប ។ កាលពីមុនគេប្រើអេទីនជាវត្ថុធាតុដើមយ៉ាងសំខាន់សម្រាប់សំយោគសរសៃអំបោះ និងកៅស៊ូ ។ ប៉ុន្តែបច្ចុប្បន្ននេះគេប្រើអេតែនជំនួសអេទីនវិញ ។ គេប្រើអាសេទីឡែនជាធាតុឆេះក្នុងចំពុះផ្សារអុកស៊ីអាសេទីឡែនសម្រាប់កាត់ឬផ្សារលោហៈ ។

For MPTC-Ebooks Only

## មេរៀនសង្ខេប

- **អាល់សែន**

- មានរូបមន្តទូទៅ $C_nH_{2n}$ $(n \geq 2)$
- គេបានវាពីក្រាគិញនៃអាល់កាន
- ចំហេះសព្វអាល់សែនឱ្យផលជា $CO_2$ និង $H_2O$
- អាល់សែនធ្វើប្រតិកម្មបូកជាមួយ $H_2$ $H_2O$ $Br_2$ $Cl_2$
- អាល់សែនអាចចូលរួមប្រតិកម្មប៉ូលីមែកម្ម ។

- **អាល់ស៊ីន :**

- អាល់ស៊ីនមានរូបមន្តទូទៅ $C_nH_{2n-2}$ $(n \geq 2)$
- ចំហេះសព្វនៃអេទីនផ្តល់សីតុណ្ហភាពរហូតដល់ 3000°C
- អាល់ស៊ីនធ្វើប្រតិកម្មបូកជាមួយ : $H_2$ , $Br_2$ , $H_2O$ , $HCl$ ។

## សំណួរនិងលំហាត់

1. សរសេររូបមន្តលាតនៃម៉ូលេគុលអេតែននិងអេទីន ។
2. ឱ្យរូបមន្តទូទៅនៃអាល់សែននិងអាល់ស៊ីន ។
3. សរសេរសមីការតុល្យការប្រតិកម្មដែលនាំឱ្យគេសំរេចបានម៉ូលេគុល :

   $CH_2 = CHCl$ និង $CH_3-CHCl-CHCl-CH_3$ ។
4. សរសេរសមីការតាងប្រតិកម្មអ៊ីដ្រាតកម្មលើប្រូប៉ែននិងអេទីន ។
5. ចូរគូសសញ្ញា ✔ ក្នុងប្រអប់ខាងមុខចម្លើយណាមួយដែលត្រឹមត្រូវ ។

   ក. ក្នុងចំណោមម៉ូលេគុលខាងក្រោមនេះ តើណាមួយជាម៉ូលេគុលអាល់សែន ?

   ☐ 1.$C_4H_6$ ☐ 2.$C_4H_{10}$ ☐ 3.$C_4H_8$ ☐ 4.$C_6H_{10}$

   ខ. អេតែនធ្វើប្រតិកម្មជាមួយចំហាយទឹកឱ្យផលជាអេតាណុល ។ ប្រតិកម្មនេះជាប្រតិកម្ម

   ☐ 1.បន្សាប ☐ 2.ជំនួស ☐ 3.បូក ☐ 4.ចំហេះ

For MPTC-Ebooks Only

គ. តើធាតុបន្ទាល់ណាមួយដែលគេប្រើសម្រាប់ញែកសំគាល់រវាងអ៊ីដ្រូកាបួឆ្អែតនិងអ៊ីដ្រូកាបួមិនទាន់ឆ្អែត ?

- ☐ 1.ទឹកប្រូម
- ☐ 2.ទឹកកំបោរថ្លា
- ☐ 3.សូលុយស្យុងប្រាក់នីត្រាត
- ☐ 4.សូលុយស្យុងផេណុលផ្តាលេអ៊ីន

ឃ. ក្នុងចំណោមរូបមន្តលាតខាងក្រោមនេះ តើណាមួយដែលសរសេរ**មិនបានត្រឹមត្រូវ** ?

☐ 1. 

☐ 2. 

☐ 3. 

☐ 4. $H-C\equiv C-H$

6. អ៊ីដ្រូកាបួ A B C និង D មានទម្រង់ម៉ូលេគុលដូចតទៅ

$H-C\equiv C-H$   

**A** **B** **C** **D**

តើម៉ូលេគុលណាខ្លះ ?

ក. ជាអ៊ីដ្រូកាបួឆ្អែត ?

ខ. បង្អើរពណ៌ទឹកប្រូម ?

គ. ហៅប្រូប៉ែន ?

ឃ. មានប្រតិកម្មបូក ?

7. ក. សរសេរសមីការតុល្យការប្រតិកម្មអ៊ីដ្រូសែនកម្ម ប៊ុយ -1- អែន និងប្រូពីនចំពោះមុខកាតាលីករ Ni ឬ Pt ។

ខ. តើមានអាល់សែនផ្សេងទៀតដែលធ្វើអ៊ីដ្រូសែនកម្ម ទទួលបានអាល់កានដូចក្នុងសំណួរ (ក) ដែរឬទេ ?

For MPTC-Ebooks Only

8. ប្រតិកម្មបូកក្លរលើអាល់សែន A មួយឱ្យផលជាឌីក្លរ៉ូអាល់កាន B មួយប្រភេទដែលមានម៉ាសក្លរ 62.5 % ។

ក. តើ A មានរូបមន្តម៉ូលេគុលដូចម្ដេច ?

ខ. ចូរសរសេររូបមន្តស្ទើរលាត A និង B ព្រមទាំងឱ្យឈ្មោះវាផង ។

គេឱ្យ $M_{Cl} = 35.5g \cdot mol^{-1}$ , $M_H = 1g \cdot mol^{-1}$ និង $M_C = 12g \cdot mol^{-1}$ ។

9. អ៊ីដ្រូកាបួមិនទាន់ឆ្អែត A មួយប្រភេទដែលធ្វើប្រតិកម្មបូកជាមួយក្លរនិងទឹក តាងដោយសមីការតុល្យការប្រតិកម្ម :

$$A + Cl_2 \rightarrow B$$

$$A + H_2O \rightarrow C$$

ម៉ាសម៉ូលេគុល B គឺ $99g \cdot mol^{-1}$ ។

ក. បង្ហាញឱ្យឃើញថា A ជាអាល់សែន ។

ខ. កំណត់រូបមន្តស្ទើរលាត A , B និងC ព្រមទាំងឱ្យឈ្មោះរបស់វាផង ។

10. គេចង់ធ្វើអាសេទីឡែន 52g ពីកាល់ស្យូមកាប៊ួដែលមានភាពសុទ្ធ 90 % ។ តើគេត្រូវការប្រើកាល់ស្យូមកាប៊ួនេះប៉ុន្មានក្រាម ?

For MPTC-Ebooks Only

មេរៀនទី

# 4 អ៊ីដ្រូកាបួប្រហើរ : បង់សែន

**ចប់មេរៀននេះ សិស្សអាច**

- ❒ សរសេរនិងហៅឈ្មោះម៉ូលេគុលរបស់សមាសធាតុប្រហើរមួយចំនួន ។
- ❒ រៀបរាប់ពីលក្ខណៈរូបនិងលក្ខណៈគីមីរបស់បង់សែន ។
- ❒ ពន្យល់និងសរសេរប្រតិកម្មពីលំនាំទង្វើបង់សែន ។

## សេចក្ដីផ្ដើម

សមាសធាតុទាំងឡាយដែលមានវង់បង់សែននៅក្នុងម៉ូលេគុលហៅថា សមាសធាតុប្រហើរ ។ នៅឆ្នាំ 1825 ផារ៉ាដេបានញែកសមាសធាតុប្រហើរចេញពីជ័រធ្យូងថ្ម ។ គេឱ្យឈ្មោះថា សមាសធាតុប្រហើរ ពីព្រោះវាមានក្លិនខ្លាំងនិងជាទូទៅវាមានក្លិនគួរឱ្យជាប់ចិត្ត ។



*រូបទី1 : អាគារដ៏ធំនេះត្រូវបានគេកម្ទេចចោល ដោយប្រើរំសេវផ្ទុះ TNT (គ្រឿងផ្ទុះដែលជាសមាសធាតុប្រហើរ) ។*

**បង់សែន**ជាសមាសធាតុប្រហើរមួយដែលមាន រូបមន្តម៉ូលេគុល $C_6H_6$ ។ វាជាអ៊ីដ្រូកាបួមិនទាន់ឆ្អែត ខ្លាំង ។ និមិត្តសញ្ញាម៉ូលេគុលបង់សែនតាងដោយឆកោណនិយ័តមួយ ដែលអាតូមកាបូនទាំងប្រាំមួយនៅត្រង់កំពូលឆកោណ ហើយអាតូមកាបូននីមួយៗ ភ្ជាប់ជាមួយអាតូមអ៊ីដ្រូសែនមួយ ។ អាតូមកាបូនភ្ជាប់គ្នាតាមរយៈសម្ព័ន្ធមួយជាន់និងពីរជាន់នៅឆ្លាស់គ្នា (រូបទី 2) ។




*រូបទី2 : និមិត្តសញ្ញាបង់សែនបែបចាស់*




*រូបទី3 : និមិត្តសញ្ញាបង់សែនបែបថ្មី*

For MPTC-Ebooks Only

> **សំគាល់**
>
> សម្ព័ន្ធ C = C មានប្រវែងខ្លីជាងសម្ព័ន្ធ (C – C) តែសម្ព័ន្ធ C = C មានភាពរឹងមាំជាងសម្ព័ន្ធ (C – C) ។

តាមការសិក្សាបែបទំនើបបង្ហាញថា សម្ព័ន្ធកាបូនកាបូនទាំងប្រាំមួយក្នុងម៉ូលេគុលបង់សែនមានប្រវែង និងមានភាពរឹងមាំដូចៗគ្នា ។ ដូចនេះអេឡិចត្រុងរបស់កាបូនពុំបានចងសម្ព័ន្ធពីរជាន់ទេ តែវាផ្លាស់ទីនៅលើវង់កាបូនទៅវិញ ។ សម្ព័ន្ធកាបូន-កាបូនទាំងប្រាំមួយក្នុងម៉ូលេគុលបង់សែន មានភាពរឹងមាំជាងសម្ព័ន្ធមួយជាន់ (C – C) នៅក្នុងម៉ូលេគុលអេតានតែខ្សោយជាងសម្ព័ន្ធពីរជាន់ (C = C) ក្នុងអេទីឡែន ។ យោងតាមការសិក្សានេះគេតាងនិមិត្តសញ្ញាម៉ូលេគុលបង់សែនដូចក្នុងរូបទី 3 ។ នៅក្នុងសៀវភៅនេះយើងប្រើនិមិត្តសញ្ញាម៉ូលេគុលបង់សែនទាំងពីរបែប ។

## 1. នាមវលី

- ម៉ូលេគុលបង់សែនដែលបានដកអាតូមអ៊ីដ្រូសែនមួយចេញហៅថា បណ្តុំ **ផេនីល** ។

$C_6H_5—$ ឬ 

- គេចាត់ទុកម៉ូលេគុលបង់សែនដែលមានបណ្តុំជំនួសតែមួយថាជា**ស្រឡាយបង់សែន** ។

**ឈ្មោះស្រឡាយបង់សែន = ឈ្មោះបណ្តុំជំនួស + បង់សែន ។**

*ឧទាហរណ៍*



*ប្រូម៉ូបង់សែន*



*នីត្រូបង់សែន*



*ក្លរ៉ូបង់សែន*



*អេទីលបង់សែន*



*អ៊ីសូប្រូពីលបង់សែន*

**ស្រឡាយបង់សែន** មួយចំនួនត្រូវបានគេហៅតាមឈ្មោះដែលគេធ្លាប់ប្រើ ។

*ឧទាហរណ៍*



*តូលុយអែន*
(មេទីលបង់សែន)



*ផេណុល*
(អ៊ីដ្រុកស៊ីបង់សែន)



*អានីលីន*
(អាមីណូបង់សែន)



*ស្ទីរ៉ែន*
(វីនីលបង់សែន)

For MPTC-Ebooks Only

• កាលណាម៉ូលេគុលបង់សែនមានបណ្តុំជំនួសពីរ នោះទម្រង់អ៊ីសូមែមានបីប្រភេទ ។ គេកំណត់ទីតាំងបណ្តុំជំនួសនីមួយៗដោយ**លេខ** និង**បុព្វបទ**ដែលសមស្រប ។ គេប្រើបុព្វបទអ័រតូ ($o-$ ) មេតា ($m-$ ) និងប៉ារ៉ា ($p-$ ) ។




1,2 - ***ឌីក្លរ៉ូបង់សែន***
ឬ អ័រតូឌីក្លរ៉ូបង់សែន
ឬ $o$-ឌីក្លរ៉ូបង់សែន




1,3 - ***ឌីក្លរ៉ូបង់សែន***
ឬ មេតាឌីក្លរ៉ូបង់សែន
ឬ $m$-ឌីក្លរ៉ូបង់សែន




1,4- ***ឌីក្លរ៉ូបង់សែន***
ឬ ប៉ារ៉ាឌីក្លរ៉ូបង់សែន
ឬ $p$- ឌីក្លរ៉ូបង់សែន

សមាសធាតុទាំងបីនេះជាអ៊ីសូមែនឹងគ្នា

កាលណាបណ្តុំជំនួសទាំងពីរខុសគ្នា គេក៏ប្រើបុព្វបទ អ័រតូ មេតា និងប៉ារ៉ាដែរ ។ គេហៅបណ្តុំជំនួសតាមលំដាប់អក្ខរក្រមអក្សរឡាតាំង ។ បណ្តុំជំនួសដែលហៅមុនគេ ត្រូវភ្ជាប់នឹងកាបូនដែលមានលេខតូចជាងគេ ។ ***ឧទាហរណ៍***




***$m$ - ប្រូម៉ូក្លរ៉ូបង់សែន***
1-ប្រូម៉ូ - 3- ក្លរ៉ូបង់សែន




***$m$ - អ៊ីយ៉ូដូនីត្រូបង់សែន***
1- អ៊ីយ៉ូដូ -3- នីត្រូបង់សែន




***$p$- នីត្រូតូលុយអែន***
4- នីត្រូតូលុយអែន




m - ក្លរ៉ូផេណុល
**3 - *ក្លរ៉ូផេណុល***




o- អេទីលអានីលីន
**2 - *អេទីលអានីលីន***




p- ក្លរ៉ូស្ទីរ៉ែន
**4 - *ក្លរ៉ូស្ទីរ៉ែន***

កាលណាមានបណ្តុំជំនួសច្រើនលើសពីពីរគេប្រើតែលេខប៉ុណ្ណោះសម្រាប់បញ្ជាក់ទីតាំងនៃបណ្តុំជំនួស ។ ***ឧទាហរណ៍***




**1,3,5 - *ទ្រីក្លរ៉ូបង់សែន***




**3,5 - *ឌីក្លរ៉ូតូលុយអែន***




**2,4,6 - *ទ្រីនីត្រូតូលុយអែន*(T.N.T.)**

For MPTC-Ebooks Only

## 2. លក្ខណៈរូបបង់សែន

បង់សែន ជាអង្គធាតុរាវ ថ្លា គ្មានពណ៌ មានក្លិនក្រអូប ។ វាងាយហួតចូលទៅក្នុងខ្យល់ ងាយឆាបឆេះនិងរលាយតិចតួចក្នុងទឹក ។ បង់សែនមានម៉ាសម៉ូលស្មើនឹង$78.11 g.mol^{-1}$ កម្រិតកក $5.5°C$ និងកម្រិតរំពុះ $80.1°C$ ។

## 3. លក្ខណៈគីមី

### 3.1 ប្រតិកម្មចំហេះ

បង់សែន តូលុយអែន ឆេះក្នុងខ្យល់ឱ្យផ្សែងខ្មៅខ្លាំង (ដោយវត្ថុមានកាបូនម៉ត់ខៃ) ។

ចំហេះសព្វបង់សែនឱ្យផលជា $CO_2$ និង $H_2O$ ។

$$C_6H_6 + \frac{15}{2}O_2 \longrightarrow 6CO_2 + 3H_2O$$

ចំហេះមិនសព្វនៃបង់សែន ត្រូវបានគេអនុវត្តនៅក្នុងឧស្សាហកម្មដើម្បីផលិតម្សៅកាបូនពណ៌ខ្មៅ ដែលគេប្រើសម្រាប់ធ្វើកៅស៊ូកង់ឡាន ថ្នាំលាប ស៊ីរ៉ា . . . ។

### 3.2 ប្រតិកម្មបូក

#### ក. ការបូកក្លរលើបង់សែន

ប្រតិកម្មបូករវាងក្លរនិងបង់សែនអាចប្រព្រឹត្តទៅបាននៅក្រោមពន្លឺថ្ងៃឬពន្លឺនៃចំហេះម៉ាញេស្យូម ។

$$\underset{\text{បង់សែន}}{C_6H_6} + \underset{\text{ក្លរ}}{3Cl_2} \xrightarrow{\text{ពន្លឺសាយ}} \underset{\text{អិចសាក្លរ៉ូស៊ីក្លូអិចសាន}}{C_6H_6Cl_6}$$

#### ខ. អ៊ីដ្រូសែនកម្ម(ការបូកអ៊ីដ្រូសែន)

នៅសីតុណ្ហភាព $200°C$ ទៅ $300°C$ ចំពោះមុខកាលីករ Ni ឬ Pt បង់សែនធ្វើប្រតិកម្មបូកជាមួយ $H_2$ ឱ្យផលជាស៊ីក្លូអិចសានដែលជាវត្ថុធាតុដើមសម្រាប់ធ្វើនីឡុង ។

$$C_6H_6 + 3H_2 \xrightarrow{Ni, t^\nearrow} \underset{\text{ស៊ីក្លូអិចសាន}}{C_6H_{12}}$$

ប្រតិកម្មបូកទៅលើអ៊ីដ្រូកាបួប្រហើរ ពិបាកជាងប្រតិកម្មបូកទៅលើអាល់សែននិងអាល់ស៊ីន ។

## 3.3 ប្រតិកម្មជំនួស

ថ្វីបើវង់បង់សែនមានសម្ព័ន្ធកាបូន-កាបូនពីរជាន់ តែបង់សែនអាចឱ្យប្រតិកម្មជំនួសដូចអាល់កានដែរ ។ ប្រតិកម្មជំនួសនេះមិនអាចកើតមានចំពោះអាល់សែននិងអាល់ស៊ីនទេ ។

### ក. ប្រតិកម្មជំនួសដោយអាឡូសែន (ឬអាឡូសែនកម្ម)

ចំពោះមុខកាតាលីករ បង់សែនធ្វើប្រតិកម្មជំនួសជាមួយ ប្រូម ឬក្លរ ។




*ក្លរ៉ូបង់សែន*

$$C_6H_6 + Br_2 \xrightarrow{FeBr_3} C_6H_5-Br + HBr$$

*ប្រូម៉ូបង់សែន*

ប្រតិកម្មជំនួសដោយអាឡូសែន ប្រព្រឹត្តទៅរហូតដល់អស់អាតូមអ៊ីដ្រូសែន ។

ប្រតិកម្មជំនួសលើកទី 2 គេទទួលបានល្បាយអ៊ីសូមែបីប្រភេទ :




1,2- ឌីក្លរ៉ូបង់សែន ឬ អ័រតូឌីក្លរ៉ូបង់សែន

1,3- ឌីក្លរ៉ូបង់សែន ឬ មេតាឌីក្លរ៉ូបង់សែន

1,4- ឌីក្លរ៉ូបង់សែន ឬ ប៉ារ៉ាឌីក្លរ៉ូបង់សែន

### ខ. ប្រតិកម្មជំនួសដោយបណ្តុំ $-NO_2$ (ឬនីទ្រកម្ម)

**នីទ្រកម្មបង់សែន** : ក្នុងភាពត្រជាក់អាស៊ីតនីទ្រិចមានអំពើលើបង់សែន ចំពោះមុខអាស៊ីតស៊ុលផួរិចខាប់ឱ្យផលជាម៉ូណូនីត្រូបង់សែន ។




*ម៉ូណូនីត្រូបង់សែន*

For MPTC-Ebooks Only

នៅសីតុណ្ហភាពប្រហែល 80°C គេបាន :



1,3 - ឌីនីត្រូបង់សែន



1,3,5- ទ្រីនីត្រូបង់សែន

**នីទ្រកម្មតូលុយអែន** : តូលុយអែនឬមេទីលបង់សែនមានប្រតិកម្មជំនួសជាមួយអាស៊ីតនីទ្រិចចំពោះមុខអាស៊ីតស៊ុលផួរិចខាប់ គេបានទ្រីនីត្រូតូលុយអែន (T.N.T.) ។



1- មេទីល - 2,4,6 - ទ្រីនីត្រូបង់សែន ឬ ទ្រីនីត្រូតូលុយអែន

## 3.4 ប៉ូលីមែកម្មស្ទីរ៉ែន

ប៉ូលីមែកម្មស្ទីរ៉ែនឱ្យផលជា ប៉ូលីស្ទីរ៉ែន (P.S) ។



ប៉ូលីស្ទីរ៉ែន ( P.S)



រូបទី4 : វត្ថុប្រើប្រាស់ធ្វើអំពីប៉ូលីស្ទីរ៉ែន

# 4. អ៊ីដ្រូកាបួប្រហើរពហុវង់

អ៊ីដ្រូកាបួប្រហើរពហុវង់ជា អ៊ីដ្រូកាបួដែលមានវង់បង់សែននៅជាប់ៗគ្នា ។

***ឧទាហរណ៍***



ណាប់តាឡែន អង់ត្រាសែន ផេណង់ត្រែន

អង់ត្រាសែននិងផេណង់ត្រែនជាអ៊ីសូមែនឹងគ្នា ។

for MPTC-Ebooks Only

# 5. ឧទ្ធើនិងបម្រើប្រាស់

ធ្យូងថ្ម ជាប្រភពយ៉ាងសំខាន់ដែលផ្តល់បង់សែននិងអ៊ីដ្រូកាបួប្រហើរដទៃទៀត (តូលុយអែន ណាប់តាឡែន ផេណង់ត្រូលីន . .) ។ ថ្វីបើបង់សែននិងធាតុស្រឡាយរបស់វាអាចទាញចេញពីជ័រធ្យូងថ្មតែបរិមាណយ៉ាងច្រើននៃបង់សែន ត្រូវបានផលិតចេញពីប្រេងកាត ។ ***ឧទាហរណ៍ :*** គេផលិតបង់សែនពីអិចសាន

$CH_3-CH_2-CH_2-CH_2-CH_2-CH_3 \xrightarrow{\text{កាតាលីករ(កម្ដៅ)}}$  $+\,4H_2$

អិចសាន

បង់សែន ជាវត្ថុធាតុដើមសម្រាប់សំយោគសមាសធាតុសរីរាង្គដទៃទៀតដូចជានីត្រូបង់សែន ក្លរ៉ូបង់សែន ល័ខ និងថ្នាំពេទ្យ ។ គេក៏ប្រើវាជាវត្ថុធាតុដើមសម្រាប់សំយោគរូបធាតុប្លាស្ទិច (PS) និងជាអង្គធាតុរំលាយ ។

**មេរៀនសង្ខេប**

- បង់សែនមានរូបមន្តម៉ូលេគុល $C_6H_6$ ។
- ម៉ូលេគុលវាតាងដោយនិមិត្តសញ្ញា :  ។
- បង់សែនជាអង្គធាតុរាវនៅសីតុណ្ហភាពបន្ទប់ ។ វាងាយហួតនៅក្នុងខ្យល់និងងាយឆាបឆេះ ។
- ប្រតិកម្មបូករបស់អ៊ីដ្រូសែនឬក្លរ($H_2$ , $Cl_2$)ទៅលើម៉ូលេគុលបង់សែនពិបាកសម្រេចណាស់ ។
- ប្រតិកម្មជំនួសទៅលើម៉ូលេគុលបង់សែន ប្រព្រឹត្តទៅដោយងាយស្រួលនៅចំពោះមុខកាតាលីករ ។ ផលិតផលនៃប្រតិកម្មនេះមានសារៈសំខាន់ក្នុងការអនុវត្តផ្សេងៗ ។

## សំណួរនិងលំហាត់

1. សរសេររូបមន្តលាតនៃម៉ូលេគុលបង់សែននិងតូលុយអែន ។
2. សរសេរសមីការតុល្យការប្រតិកម្មចំហេះសព្វបង់សែនក្នុងអុកស៊ីសែន ។
3. ឱ្យរូបមន្តម៉ូលេគុលនិងឈ្មោះផលិតផលដែលទទួលបានពីប្រតិកម្មបូកនៃអ៊ីដ្រូសែនលើម៉ូលេគុលបង់សែន ។
4. ឱ្យរូបមន្តលាតនៃណាប់តាឡែននិងអង់ត្រាសែន ។

For MPTC-Ebooks Only

5. សរសេររូបមន្តលាតនៃសមាសធាតុខាងក្រោម

ក. មេតានីត្រូតូលុយអែន ខ. មេតាឌីនីត្រូបង់សែន

គ. 2,6- ឌីប្រូម៉ូ-4- ក្លរ៉ូតូលុយអែន ឃ. T.N.T. ង. PS

6. បំពេញសមីការតុល្យការប្រតិកម្មខាងក្រោមនិងសរសេររូបមន្តលាតនៃអង្គធាតុកកើត

ក. $C_6H_6 + 6Cl_2 \xrightarrow{FeCl_3}$ …………… + …………

ខ. $C_6H_5 - CH_3 + 3HNO_3 \xrightarrow{H_2SO_4}$ …………… + ……….

For MPTC-Ebooks Only

## សំណួរនិងលំហាត់ជំពូក 4

1. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់ ។

ក. តើប្រភាគណាមួយដែលគេប្រើសម្រាប់លាយជាមួយថ្ម និងខ្សាច់ហើយយកទៅក្រាលថ្នល់

☐. ព្យូល ☐ កាស៊ាល់ ☐ ណាប់តា ☐ ប៊ីទូម

ខ. សមាសធាតុបង្កសំខាន់នៃឧស្ម័នធម្មជាតិគឺ

☐ អេតាន ☐មេតាន ☐ប្រូប៉ាន ☐ ប៊ុយតាន

គ. បំណិតប្រភាគនៃប្រេងកាតជា

☐ប្រតិកម្មគីមី ☐ ប្រតិបត្តិការចម្រាញ់ប្រេងកាត

☐បច្ចេកទេសទាញយកប្រេងកាត ☐ក្រាគិញផលិតផលប្រេងកាត

ឃ. បើអ្នកធ្វើក្រាគិញម៉ូលេគុលដេកាន $C_{10}H_{22}$ តើអ្នកអាចទទួលបានសមាសធាតុណាមួយ

☐ $C_{10}H_{22}$ ☐ $C_5H_{12}$ ☐ $C_{12}H_{24}$ ☐ $CO_2$ ។

2. សាំងស៊ុបពែជាសាំងដែលមានគុណភាពខ្ពស់ ក្នុងនោះមា នអ៊ីសូអុកតាន 98 % ។ អ៊ីសូអុកតាន ឬ 2, 2, 4 – ទ្រីមេទីលប៉ង់តានជាអ៊ីសូម៉ែនៃអុកតាន ។ សរសេររូបមន្តស្ទើរលាតនៃអ៊ីសូអុកតាន ។

3. អាល់កានខ្សែបើកមួយមានម៉ាសម៉ូលម៉ូលេគុល $M = 58\text{g.mol}^{-1}$ ។

ក. កំណត់រូបមន្តអាល់កាននេះ ។

ខ. សរសេររូបមន្តស្ទើរលាតនិងឱ្យឈ្មោះនៃបណ្ដាអ៊ីសូម៉ែដែលអាចមាន ។

4. ក. សរសេរសមីការចំហេះសព្វនៃអាសេទីឡែននិងអេទីឡែន ។

ខ. គេយកអាសេទីឡែន 1L និងអេទីឡែន 1L លាយចូលគ្នា ។ រកមាឌអុកស៊ីសែនចាំបាច់សម្រាប់ចំហេះសព្វល្បាយឧស្ម័ននេះ ។ គណនាម៉ាសកាបូនឌីអុកស៊ីតកកើត ។ គេឱ្យមាឌម៉ូលឧស្ម័ន $V_M = 22.4\text{L.mol}^{-1}$ ។

5. អ៊ីដ្រូសែនកម្មអាសេទីឡែនដែលមានមាឌ $V$ ចំពោះមុខកាតាលីករនីកែល Ni ត្រូវការអ៊ីដ្រូសែន 10g ។ រកមាឌអាសេទីឡែន $V$ ដែលបានប្រើ ។ មាឌម៉ូលឧស្ម័ននៅក្នុងលក្ខខណ្ឌពិសោធន៍គឺ $V_M = 22.4\text{L.mol}^{-1}$ ។

For MPTC-Ebooks Only

6. ក. សរសេរសមីការតុល្យការប្រតិកម្មអ៊ីដ្រាតកម្មអាសេទីឡែន ។

ខ. រកម៉ាសអង្គធាតុដែលទទួលបានពីប្រតិកម្មអ៊ីដ្រាតកម្មអាសេទីឡែន 100L ។

គេឱ្យមាឌម៉ូលឧស្ម័ន $V_M = 22.4L.mol^{-1}$ ។

7. អ៊ីដ្រូកាបួ A មួយមានប្រតិកម្មបូកជាមួយប្រូម ។ គេដឹងថា បើគេប្រើអ៊ីដ្រូកាបួមួយម៉ូល គេត្រូវការប្រូមមួយម៉ូលដែរ ។ បើគេធ្វើអ៊ីដ្រូសែនកម្ម A ចំនួន 3.5g គេត្រូវការអ៊ីដ្រូសែន 1.12L ។ កំណត់រូបមន្តម៉ូលេគុលនៃអ៊ីដ្រូកាបួ A ។

8. គេយកល្បាយអេតែននិងអេតាន $70cm^3$ ឱ្យមានប្រតិកម្មជាមួយអ៊ីដ្រូសែន $40cm^3$ ចំពោះមុខកាតាលីករ Ni ។ ក្រោយប្រតិកម្មគេទទួលបានល្បាយឧស្ម័ន $80cm^3$ ។ គណនាមាឌអេតែននិងអេតាននៅក្នុងល្បាយដើម ។

9. ក្រាគិញអិបតានអាចទទួលបានប៊ុយ -1- អែន និងអាល់កានមួយប្រភេទ ។

ក. ចូរកំណត់ឈ្មោះអាល់កាន ។

ខ. សរសេរសមីការតុល្យការប្រតិកម្មក្រាគិញដោយប្រើរូបមន្តស្ទើរលាត ។

10. ក. តាមការវិភាគបង្ហាញថា ចំហេះសព្វនៃអ៊ីដ្រូកាបួ A ចំនួន 0.46g គេទទួលបានកាបូនឌីអុកស៊ីត 1.54g និងទឹក 0.36g ។ កំណត់រូបមន្តងាយនៃអ៊ីដ្រូកាបួ A ។

ខ. អ៊ីដ្រូកាបួ A នេះមានអំពើជាមួយអ៊ីដ្រូសែនចំពោះមុខកាតាលីករ Pt គេទទួលបានអ៊ីដ្រូកាបួឆ្អែតមួយដែលមានរូបមន្តម៉ូលេគុល $C_7H_{14}$ ។ តើអ៊ីដ្រូកាបួ A មានរូបមន្តលាតដូចម្តេច ?

11. ក. សមាសធាតុ B មានរូបមន្តម៉ូលេគុល $C_8H_8$ ដែលម៉ូលេគុលវាមានវង់បង់សែនមួយ ។ ឱ្យឈ្មោះនិងរូបមន្តលាតនៃសមាសធាតុ B ។

ខ. សមាសធាតុ B អាចធ្វើប្រតិកម្មប៉ូលីមែកម្មឱ្យផលជាប៉ូលីមែ C ។ ចូរសរសេរសមីការតុល្យការប្រតិកម្មប៉ូលីមែកម្មនេះនិងឱ្យឈ្មោះប៉ូលីមែ C ។

For MPTC Books Only

# គីមីអនុវត្តន៍ ជីគីមី

**ចប់មេរៀននេះ សិស្សអាច**

- ❒ បង្ហាញពីសមាសភាពរបស់ជី ។
- ❒ ពណ៌នាពីតួនាទីរបស់សមាសភាគផ្សំនីមួយៗរបស់ជី ។
- ❒ អនុវត្តចំណេះដឹងនៃបម្រើបម្រាស់ជីគីមីក្នុងជីវភាពប្រចាំថ្ងៃ ។



*រូបទី 1 : ចម្ការបន្លែ*

កសិករធ្លាប់តែពឹងផ្អែកទៅលើសារធាតុធម្មជាតិដើម្បីបង្កើនជីវជាតិដី ដែលបាត់បង់ដោយសាររុក្ខជាតិស្រូបយក ។ លាមកសត្វ និងការពុកផុយរបស់រុក្ខជាតិ គឺជាសារធាតុធម្មជាតិដែលកសិករតែងប្រើជាយូរមកហើយ ។ បច្ចុប្បន្ននេះ ដោយអត្រាកំណើនប្រជាជនកើនយ៉ាងលឿន ដូចនេះគេត្រូវការស្បៀងអាហារយ៉ាងច្រើន ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅ ។ ដូច្នេះដើម្បីបំពេញតម្រូវការចាំបាច់នេះ កសិករត្រូវការប្រភពសារធាតុចិញ្ចឹមដីផ្សេងទៀត ដើម្បីបង្កើនទិន្នផលដំណាំ ។

ជីគីមីជាសមាសធាតុដែលផ្ទុកនូវសារធាតុចិញ្ចឹម ដើម្បីជួយបង្កើនការលូតលាស់របស់រុក្ខជាតិ ។ គេបន្ថែមជីទៅក្នុងដីដើម្បីបង្កើនផលដំណាំ ។

## 1. សមាសភាពជី

ធាតុបង្កជីសំខាន់ៗគឺ អាសូត (N) ផូស្វរ (P) និងប៉ូតាស្យូម (K) ។

### 1.1 ជីសរីរាង្គ

ជីសរីរាង្គបំលែងទៅជាសារធាតុខនិជ ក្រោមអំពើនៃបាក់តេរីដើម្បីឱ្យរុក្ខជាតិស្រូបយកវាបាន ។ ជីសរីរាង្គអាចទង្វើបានតាមធម្មជាតិនិងតាមឧស្សាហកម្ម ។ ជីសរីរាង្គមានប្រភពពីកម្ទេចកំទីពុកផុយនៃរុក្ខជាតិ កាកសំណល់សត្វដូចជា លាមកសត្វ ឆ្អឹង ស្បែកជាដើម ។ ជីប្រភេទនេះសម្បូរទៅដោយធាតុអាសូត ផូស្វរ និងប៉ូតាស្យូមដែលរុក្ខជាតិត្រូវការចាំបាច់សម្រាប់ការលូតលាស់ ។

***ឧទាហរណ៍ :*** ជីអ៊ុយរ៉េ ជាជីសរីរាង្គ ដែលមាននៅក្នុងទឹកនោម ។ ក្នុងឧស្សាហកម្មអាចទង្វើវាពីអាម៉ូញ៉ាក់ ($NH_3$) និងកាបូនឌីអុកស៊ីត ($CO_2$) ។ ជីអ៊ុយរ៉េមានរូបមន្ត $CO(NH_2)_2$ ។

For MPTC-Ebook only

## 1.2 ជីអសរីរាង្គ

### ក. ជីទោល

ជីទោលគឺជាជីដែលមានធាតុបង្កជីតែមួយប្រភេទគឺ N P ឬ K ។

- **ជីអាសូត** : ជីអាសូតអាចផ្តល់ធាតុអាសូតទៅឱ្យរុក្ខជាតិក្រោមសណ្ឋានពីរយ៉ាង
  - ជាអ៊ីយ៉ុងនីត្រាត ($NO_3^-$) ដូចជាសូដ្យូមនីត្រាត ($NaNO_3$) កាល់ស្យូមនីត្រាត $Ca(NO_3)_2$ និងម៉ាញេស្យូមនីត្រាត $Mg(NO_3)_2$ ។
  - ជាអ៊ីយ៉ុងអាម៉ូញ៉ូម ($NH_4^+$) ដូចជាអាម៉ូញ៉ូមស៊ុលផាត $(NH_4)_2SO_4$ និងអ៊ុយរ៉េ $CO(NH_2)_2$ ។ ជីអាសូតដែលសំខាន់ជាងគេគឺ អាម៉ូញ៉ូមនីត្រាត ($NH_4NO_3$) ។
- **ជីផូស្វាត** : ជីផូស្វាតផ្តល់ធាតុផូស្វរ ក្រោមសណ្ឋានជាអ៊ីយ៉ុង
  - ជីផូស្វាតធម្មជាតិ : មានធាតុបង្កសំខាន់គឺ កាល់ស្យូមផូស្វាត $Ca_3(PO_4)_2$ ដែលជាអំបិលមិនរលាយក្នុងទឹក ។
  - ជីស៊ុយពែផូស្វាត ជាផលិតផលដែលបានមកពីអំពើនៃអាស៊ីតស៊ុលផួរិច ($H_2SO_4$) ឬអាស៊ីតផូស្វរិច ($H_3PO_4$) ទៅលើផូស្វាតធម្មជាតិ ។

នៅប្រទេសកម្ពុជាយើង រ៉ែផូស្វាតមាននៅក្នុងខេត្តកំពត ។ រុក្ខជាតិអាចស្រូបផូស្វាតធម្មជាតិបានយ៉ាងលំបាក ពីព្រោះវាជាអំបិលរលាយតិច ដូចនេះគេត្រូវយកវាទៅកែច្នៃសិន ។

ដូចនេះដើម្បីបានជីផូស្វាតរលាយច្រើន គេត្រូវបំលែងអ៊ីយ៉ុង $PO_4^{3-}$ នៃកាល់ស្យូមផូស្វាតធម្មជាតិទៅជាអ៊ីយ៉ុង $H_2PO_4^-$ ដោយបន្ថែមអ៊ីយ៉ុង $H^+$ នៃអាស៊ីត $H_2SO_4$ ឬ $H_3PO_4$ ។

- **ជីប៉ូតាស្យូម** : ជីប៉ូតាស ផ្តល់ធាតុប៉ូតាស្យូម ក្រោមសណ្ឋានជាអ៊ីយ៉ុង $K^+$ ។ គេច្រើនប្រើវាក្រោមសណ្ឋានជាអំបិលប៉ូតាស្យូមក្លរួ ($KCl$) ។

### ខ. ជីសមាស

ជីសមាសជាជីដែលអាចផ្តល់នូវធាតុបង្កជី យ៉ាងហោចណាស់ពីរយ៉ាងនៃ N P ឬ K ។

ជីសមាសសំខាន់ៗដែលផលិតនៅក្នុងឧស្សាហកម្មមាន

- **ជីទ្វេធាតុ** ជាជីដែលមានធាតុបង្កជី 2 មុខ : NP NK ឬ PK ។

**ឧទាហរណ៍ :** NP ដូចជា អាម៉ូញ៉ូមឌីអ៊ីដ្រូសែណូផូស្វាត $(NH_4)H_2PO_4$

NK ដូចជា ប៉ូតាស្យូមនីត្រាត $KNO_3$

PK ដូចជា ប៉ូតាស្យូមឌីអ៊ីដ្រូសែណូផូស្វាត $KH_2PO_4$

- **ជីត្រីធាតុ** : ជាជីដែលមានធាតុបង្កបីមុខគឺ NPK ។

For MPTC-Ebooks Only

### គ. ទង្វើជីអាសូត

ជីអាសូតភាគច្រើនទង្វើចេញពីអាម៉ូញ៉ាក់ ($NH_3$) និងអាស៊ីតនីទ្រិច ($HNO_3$) ។ ជីអាសូតសំខាន់ៗរួមមានអាម៉ូញ៉ូមនីត្រាត អ៊ុយរ៉េ និងអាម៉ូញ៉ូមស៊ុលផាត ។ គំនូសតាងខាងក្រោមនេះ បង្ហាញពីលំនាំនៃការផលិតជីអាសូតនៅក្នុងឧស្សាហកម្ម ។



*រូបទី2 ការផលិតជីអាសូត*

## 2. តួនាទីរបស់សមាសធាតុនីមួយៗរបស់ជី

រុក្ខជាតិត្រូវការធាតុគីមីជាច្រើនប្រភេទដើម្បីទ្រទ្រង់ដល់ការលូតលាស់ ផ្លែផ្កា និងការបន្តពូជ ។ ធាតុសំខាន់ៗទាំងនោះមានធាតុ N P និង K ។ តើធាតុសំខាន់នីមួយៗនេះផ្តល់សារប្រយោជន៍អ្វីខ្លះដល់រុក្ខជាតិ ?

### ធាតុអាសូត (N)

រុក្ខជាតិត្រូវការអាសូតដើម្បីផលិតប្រូតេអ៊ីនសម្រាប់ការលូតលាស់ ។ អាសូតជួយដល់ការលូតលាស់របស់ស្លឹកនិងធ្វើឱ្យស្លឹកមានពណ៌ខៀវ ។ កង្វះជាតិអាសូតធ្វើឱ្យស្លឹកមានពណ៌លឿងនិងបង្អាក់ដល់ការលូតលាស់របស់រុក្ខជាតិ ។ ប៉ុន្តែបើធាតុអាសូតមានច្រើនពេកនឹងធ្វើឱ្យរុក្ខជាតិមិនងាយចេញផ្កានិងមានស្លឹកច្រើន ។


*រូបទី3 ដើមស្ពៃខៀវ*

For MPTC Ebooks Only



រូបទី4 ឫសរុក្ខជាតិ

**ធាតុផូស្វ័រ** (P)

រុក្ខជាតិត្រូវការផូស្វ័រដើម្បីការលូតលាស់ឫស និងរួមចំណែកក្នុងចលនការនៃការបន្តពូជ ។ វាជួយឱ្យគ្រាប់មានការលូតលាស់បានល្អបង្កើនទិន្នផលគ្រាប់និងឆាប់ចេញផ្លែផ្កា ។ ម្យ៉ាងទៀតធាតុផូស្វ័រជួយរុក្ខជាតិធន់នឹងជំងឺទៀតផង ។



រូបទី5 មើមឆៃថាវ

**ធាតុប៉ូតាស្យូម** (K)

ប៉ូតាស្យូមមានសារៈសំខាន់ណាស់ ពីព្រោះវាមានតួនាទីជួយស្រូបទឹកនិងធ្វើឱ្យរុក្ខជាតិលូតលាស់ ។ ប៉ូតាស្យូមក៏ជួយក្នុងលំនាំធ្វើរស្មីសំយោគនិងកំណត្តូយស៊ីតបម្រុងទុកក្នុងរុក្ខជាតិ (ដំឡូង ឆៃថាវ) និងធ្វើឱ្យរុក្ខជាតិធន់នឹងភាពស្ងួត ។

ក្រៅពីធាតុសំខាន់ៗខាងលើក៏មានធាតុបន្ទាប់បន្សំផ្សេងទៀតដែលរុក្ខជាតិត្រូវការផងដែរ ដូចជាស្ពាន់ធ័រក្នុងសណ្ឋានជាអ៊ីយ៉ុង ($SO_4^{2-}$) ជួយបង្កើនការលូតលាស់នៃរុក្ខជាតិ កាល់ស្យូមក្នុងសណ្ឋានជាអ៊ីយ៉ុង($Ca^{2+}$) ជួយមីក្រូសារពាង្គកាយឱ្យមានសកម្មភាព ជាពិសេសជួយក្នុងលំនាំស្រូបយកអាសូត ម៉ាញេស្យូមក្នុងសណ្ឋានជា ($Mg^{2+}$) ជួយក្នុងការបង្កើតក្លរ៉ូភីល ។ មានធាតុខ្លះទៀតក៏រុក្ខជាតិបានស្រូបយកផងដែរ ក្នុងបរិមាណតិចតួចនិងក្នុងសណ្ឋានជាអ៊ីយ៉ុងដូចជា : $Fe^{2+}$ $Mn^{2+}$ $Zn^{2+}$ $Cu^{2+}$ … ។

## 3. គុណសម្បត្តិនិងគុណវិបត្តិរបស់ជី

រុក្ខជាតិមិនស្រូបយកជីដែលកសិករប្រើដើម្បីបង្កើនទិន្នផលដំណាំបានទាំងអស់ទេ ។ ជីមួយចំណែកបានរលាយក្នុងទឹកភ្លៀងហើយហូរចូលទៅក្នុងបឹង ស្ទឹង ទន្លេ។ លំនាំនេះបានបំពុលទឹកនិងបណ្ដាលឱ្យត្រីងាប់ថែមទៀតផង ។ ដូចនេះ ដើម្បីគ្រប់គ្រងការបំពុលដល់បរិស្ថានទឹក ទន្លេ ស្ទឹង បឹងបួរ យើងគប្បីប្រើប្រាស់ជីកុំឱ្យលើសពីបរិមាណកំណត់ ។

### 3.1 គុណសម្បត្តិ

ប្រជាជននៅលើពិភពលោកបានកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងមួយសតវត្សចុងក្រោយនេះ ។ តើគេផ្គត់ផ្គង់ស្បៀងដល់ប្រជាជនទាំងអស់នោះយ៉ាងដូចម្ដេច ? ដីសម្រាប់ការដាំដុះពុំមានការកាប់រានបានច្រើនថែមទៀតទេ ដូចនេះដើម្បីផ្គត់ផ្គង់ស្បៀងឱ្យបានគ្រប់គ្រាន់នោះ កត្តាសំខាន់បំផុតគឺត្រូវប្រើប្រាស់ជីជាចាំបាច់ ។

For MPTC-Ebooks Only

បច្ចុប្បន្ននេះពិភពលោកបានផលិតស្បៀងលើសពីតម្រូវការ ប៉ុន្តែនៅតែមានមនុស្សជាច្រើនដែលមិនទាន់មានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ទទួលទាននៅឡើយ ។

ប្រទេសក្រីក្រមួយចំនួនផលិតស្បៀងមិនបានគ្រប់គ្រាន់ទេ ពីព្រោះកសិករមិនអាចទិញជីបានឬមិនមានគ្រាប់ពូជល្អឬគ្មានគ្រឿងម៉ាស៊ីនសម្រាប់ប្រើប្រាស់ហើយភ្លៀងធ្លាក់ក៏មិនគ្រប់គ្រាន់ទៀត ។ ប៉ុន្តែមានប្រទេសខ្លះទៀតផលិតស្បៀងលើសពីតម្រូវការ ។ ដូចនេះការផលិតស្បៀងនៅលើពិភពលោកមានលក្ខណៈមិនស្មើគ្នាទេ ។

រហូតដល់ឆ្នាំ2025 មនុស្សនៅលើពិភពលោកប្រហែលជាកើនឡើងដល់ 8,3 ពាន់លាននាក់ ដូច្នេះប្រសិនបើយើងមិនប្រើជីទេនោះ ការផលិតស្បៀងនឹងមិនបានគ្រប់គ្រាន់តាមតម្រូវការឡើយ ។

## 3.2 គុណវិបត្តិ

នៅពេលគេបាចជីទៅក្នុងស្រែ វាមិនត្រឹមតែស្រូបយកដោយឫសរុក្ខជាតិតែប៉ុណ្ណោះទេ ។ ចូរពិនិត្យមើលរូបភាពខាងក្រោមនេះ




***រូបទី 6 : ការបំពុលបរិស្ថានទឹក***

ជីអាចជួយឱ្យរុក្ខជាតិលូតលាស់បានយ៉ាងល្អ ។ សារាយជារុក្ខជាតិតូចៗដែលរស់នៅលើទឹក វាអណ្តែតនៅលើផ្ទៃទឹក ដូចជាកម្រាលព្រំដែលរំខានដល់ការធ្វើរស្មីសំយោគរបស់រុក្ខជាតិនៅក្រោមទឹកដោយរារាំងពន្លឺព្រះអាទិត្យ ។ នៅពេលរុក្ខជាតិនៅក្នុងទឹកងាប់ វានឹងរលួយដោយសារការបំបែករបស់បាក់តេរី ហើយប្រតិកម្មបំបែកនេះស្រូបយកអុកស៊ីសែនដែលរលាយក្នុងទឹក ។ កាលណាទឹកខ្វះអុកស៊ីសែនពពួកសត្វក្នុងទឹក (ត្រី កង្កែប . . .) ក៏ត្រូវបាត់បង់ដែរ ។

For MPTC-Ebooks Only

កំហាប់នីត្រាតខ្ពស់នៅក្នុងទឹកសម្រាប់បរិភោគក៏ទាក់ទងនឹងជំងឺមហារីកដែរ ប៉ុន្តែទំនាក់ទំនងនេះមិនទាន់មានអ្នកវិទ្យាសាស្ត្រណាអាចបង្ហាញបាននៅឡើយទេ ។

## 3.3 ដំណោះស្រាយបញ្ហាបំពុលបរិស្ថាន

ដើម្បីដោះស្រាយបញ្ហាបំពុលបរិស្ថាន កសិករត្រូវបន្ថយការប្រើប្រាស់ជីដោយប្រើជីតិចតួច ហើយកុំប្រើវានៅលើដីសើម ឬនៅក្នុងអាកាសធាតុសើម ។ ចំពោះទឹកបរិភោគ យើងអាចបំបាត់អ៊ីយ៉ុងនីត្រាតនៅកន្លែងផលិតទឹក ។ តែមានរុក្ខជាតិមួយចំនួនបានប្រើប្រាស់បាក់តេរី ដើម្បីស្រូបយកអ៊ីយ៉ុងនីត្រាតចេញពីទឹកដែរ ។

មនុស្សមួយចំនួនជឿជាក់ថា ការដាំដុះតាមបែបធម្មជាតិ គឺជាវិធីមួយល្អបំផុតដែលក្នុងនោះកសិករប្រើតែជីធម្មជាតិនិងធ្វើការផ្លាស់ប្តូរប្រភេទដំណាំដែលគាត់ដាំដុះឬទុកដីឱ្យនៅទំនេរ ដើម្បីឱ្យដីមានជីជាតិដោយធម្មជាតិឡើងវិញ ។

### មេរៀនសង្ខេប

- ប្រភពនៃជីសរីរាង្គមាន កាកសំណល់សត្វ រុក្ខជាតិ លាមកសត្វ អំពុកផុយសរីរាង្គផ្សេងៗ ។
- ធាតុសំខាន់នៅក្នុងជីគីមីគឺ អាសូត ផូស្វរ និងប៉ូតាស្យូម ។
- ជីទោលគឺជាជីដែលមានធាតុបង្កជីតែមួយប្រភេទ : N P ឬ K ។
- ជីសមាសអាចផ្តល់នូវធាតុបង្កជី យ៉ាងហោចណាស់ពីរយ៉ាងនៃ N P ឬ K ។
- រុក្ខជាតិត្រូវការអាសូតសម្រាប់ផលិតប្រូតេអ៊ីនដើម្បីលូតលាស់ដើម និងស្លឹក ផូស្វរដើម្បីការលូតលាស់ឫស ការបន្តពូជផ្លែផ្កា និងជួយធន់នឹងជំងឺ ប៉ូតាស្យូមសម្រាប់លំនាំរស្មីសំយោគស្រូបទឹក និងកំណត់ខ្លុយស៊ីត ។
- ការប្រើប្រាស់ជីជួយបង្កើនទិន្នផលដំណាំ ប៉ុន្តែការប្រើប្រាស់ដោយមិនបានត្រួតពិនិត្យត្រឹមត្រូវនាំឱ្យមានការបំពុលដល់បរិស្ថាន ជាពិសេសទឹកទន្លេ ស្ទឹង បឹងបួ និងគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ។
- ជីអសរីរាង្គ សំដៅទៅលើជីគីមីដែលមានធាតុផ្សំ N P និង K ។ ជីអសរីរាង្គមានពីរប្រភេទគឺជីទោល និងជីសមាស ។

For MPTC-Ebooks Only

## សំណួរនិងលំហាត់

1. តើសារធាតុណាមួយជាជីអាសូត ?

   ក. $HNO_3$ ខ. $N_2$ គ. $NO_2$ ឃ. $NH_4NO_3$

2. អាម៉ូញ៉ូមនីត្រាតមានរូបមន្តម៉ូលេគុល $NH_4NO_3$ ។

   ក. ចូរគណនាភាគរយអាសូតនៅក្នុងអាម៉ូញ៉ូមនីត្រាត ។

   ខ. អាម៉ូញ៉ូមនីត្រាតជាអំបិល ។ ចូរប្រាប់ឈ្មោះអាស៊ីត និងបាសដែលមានប្រតិកម្មបង្កើតវា ។

3. អ៊ុយរ៉េមានរូបមន្តម៉ូលេគុល $CO(NH_2)_2$ ។ វាមានប្រតិកម្មយឺតៗជាមួយទឹកបង្កើតជា អាម៉ូញ៉ាក់ និងកាបូនឌីអុកស៊ីត ។ ចូរសរសេរសមីការតាងប្រតិកម្មនេះ ។

4. ហេតុអ្វីបានជាកសិករមិនបញ្ចូលអ៊ីដ្រូសែន និងអុកស៊ីសែនទៅក្នុងជីគីមី ?

5. តើរវាងជីសរីរាង្គ និងជីអសរីរាង្គ (ជីទោល - ជីសមាស) មួយណាដែលរុក្ខជាតិងាយស្រូបយកជាង ? ព្រោះអ្វី ?

6. ទឹកនៅក្នុងស្ទឹងមួយត្រូវបានគេរកឃើញថាមានបរិមាណជីអាសូតដ៏ច្រើន និងសារធាតុដែលអាចបំបែកដោយបាក់តេរីបាន ។ ទឹកនៅក្នុងស្ទឹងពោរពេញដោយរុក្ខជាតិទឹក ហើយគេអង្កេតឃើញបរិមាណអុកស៊ីសែននៅក្នុងទឹកបានថយចុះ ។

   ក. តើអ្នកគិតថា ជីអាសូតអាចចូលក្នុងទឹកស្ទឹងបានដោយវិធីណា ?

   ខ. ចូរប្រាប់ឈ្មោះសមាសធាតុគីមីដែលគេប្រើជាជីអាសូត ។

   គ. ចូរពន្យល់ថា ហេតុអ្វីបានជាបរិមាណអុកស៊ីសែននៅក្នុងទឹកស្ទឹងថយចុះ ?

For MPTC-Ebooks Only

# បទានុក្រម

| | |
|---|---|
| កម្ទេចកំណ | រូបធាតុរឹង (ដុំថ្ម ក្រួស ខ្សាច់ . . . ) ដែលដឹកជញ្ជូននិងចាក់បង្កដោយខ្យល់ ចរន្តទឹក ឬទឹកនៅបាតស្ទឹង បឹងទន្លេ សមុទ្រ ជាដើម ។ |
| កម្លាំងអន្តរម៉ូលេគុល | កម្លាំងខ្សោយដែលកើតឡើងរវាងម៉ូលេគុលទាំងឡាយ ។ |
| កម្លាំងអេឡិចត្រូស្តាទិច | កម្លាំងបង្កឡើងដោយបន្ទុកអគ្គិសនីនៅនឹង ដូចជាបន្ទុកអគ្គិសនីលើវត្ថុមួយ ។ |
| កាចុង | ជាអ៊ីយ៉ុងដែលមានបន្ទុកវិជ្ជមាន ។ |
| កាតាលីករ | សារធាតុដែលជួយបង្កើនល្បឿនឬពន្យឺតល្បឿនប្រតិកម្មគីមីមួយ ហើយក្រោយប្រតិកម្ម បរិមាណ និងសមាសភាពរបស់វានៅដដែល ។ |
| ក្រាភិច | ទម្រង់នៃកាបូនដែលមានការត្រៀមអាតូមជាស្រទាប់ៗ ។ វាជា សារធាតុពណ៌ខ្មៅទន់ គេប្រើជាបណ្តូរខ្មៅដៃនិងក្នុងឧបករណ៍អគ្គិសនី ។ |
| ក្រុម | ជួរឈរឬបន្ទាត់ឈរក្នុងតារាងខួប ។ |
| ក្រុមឡង់តានីត | ធាតុកម្រលើផែនដីពីលេខលំដាប់ 57-71 ដែលមានលក្ខណៈគីមីប្រហែលគ្នាទៅនឹងធាតុឡង់តាន ។ |
| ក្រុមអាក់ទីនីត | ធាតុវិទ្យុសកម្ម ចាប់ពីលេខលំដាប់ 89-103 ។ |
| ខួប | ជួរដេកនៃតារាងខួប ។ |
| ជីសរីរាង្គ | ជីដែលផ្សំដោយអង្គធាតុសរីរាង្គមាន : ជីអ៊ុយរ៉េ $CO(NH_2)_2$ ជីធម្មជាតិដូចជា ទឹកនោម អាចម៍សត្វ ឆ្អឹង ភក់ កំប៉ុស ជីស្រស់ ដើម ស្លឹករុក្ខជាតិ ស្រស់ . . . ) ។ |
| ជីអសរីរាង្គឬជីខនិជ | ជីដែលផ្សំដោយអង្គធាតុខនិជ ។ ខនិជសំខាន់ៗមាន សមាសធាតុអាសូត (N) ផូស្វរ (P) និងប៉ូតាស្យូម (K) ។ |

For MPTC-Ebooks Only

| | |
|---|---|
| ជ័រធ្យូងថ្ម | បំណិតធ្យូងថ្មឱ្យក្លាយជាធ្យូងកូក ។ |
| ដង់ស៊ីតេ | ម៉ាសក្នុងមួយខ្នាតមាឌ ជាទូទៅគិតជាក្រាមក្នុងមួយសង់ទីម៉ែតគូបឬក្រាមក្នុងមួយមីលីលីត ។ |
| ទម្រង់ម៉ូលេគុលធំៗ | ទម្រង់ដែលក្នុងនោះ អាតូមទាំងអស់ចងភ្ជាប់គ្នាដោយសម្ព័ន្ធកូវ៉ាឡង់ដែលផ្តល់ភាពរឹងនឹងចំណុចរលាយខ្ពស់នៃរូបធាតុ ។ ឧទាហរណ៍ : កាបូន (ពេជ្រ... ) ។ |
| ទម្រង់អេឡិចត្រូនិច | ជាការតម្រៀបអេឡិចត្រុងតាមស្រទាប់នៅក្នុងអាតូមមួយ ។ ឧទាហរណ៍ : ធាតុស្ពាន់ធ័រ (S) មានលេខអាតូម 16 ទម្រង់ អេឡិចត្រូនិចរបស់ស្ពាន់ធ័រគឺ $(K)^2$ $(L)^8$ $(M)^6$ ។ |
| ធាតុអំផូទែ | ធាតុដែលមានលក្ខណៈជាលោហៈផង និងជាអលោហៈផង ។ |
| នីត្រូកម្ម | គឺជាការបញ្ចូលបណ្តុំ ($-NO_2$) ទៅក្នុងសមាសធាតុសរីរាង្គមួយ ។ |
| បណ្តាញក្រាម | ការតម្រៀបស្មើនៃម៉ូលេគុល អាតូម ឬអ៊ីយ៉ុងនៅក្នុងក្រាមអង្គធាតុរឹង ។ បណ្តាញក្រាមមានផ្ទុកដោយភាគល្អិតដ៏ច្រើនដែលតម្រៀបតាមរបៀបដោយឡែកៗគ្នា ។ |
| ប្រតិកម្មនុយក្លេអ៊ែ | ប្រតិកម្មទាក់ទងទៅនឹងបម្រែបម្រួលក្នុងណ្វៃយ៉ូអាតូម ។ |
| បំណិតប្រភាគ | គឺញែកធាតុបង្កនៃល្បាយវត្ថុរាវ ដែលរលាយចូលគ្នា ។ វត្ថុរាវទាំងនោះមានសីតុណ្ហភាពរំពុះខុសគ្នា ។ |
| ប្រព្រឹត្តកម្ម | លំនាំកំណែប្រែសារធាតុមួយទៅជាសារធាតុផ្សេងទៀតដែលជាតម្រូវការ ។ |
| ប៉ូលីមែ | សារធាតុដែលបង្កឡើងពីម៉ូលេគុលធំៗកើតឡើងពីការផ្គុំគ្នានៃម៉ូលេគុលតូចៗ (ម៉ូណូមែ)ដូចគ្នាច្រើន ។ |

For MPTC-Ebooks Only

| | |
|---|---|
| ផូសីល | ជាននៃសត្វ និងរុក្ខជាតិ ឬសំណល់នៃផ្នែកមួយនៃសរីរាង្គ ឬភាវៈរស់ទាំងមូល ដែលរក្សាទុកនៅក្នុងសិលាតាំងពីរាប់លានឆ្នាំមកហើយ ។ |
| ភាពរូប | រឹង រាវ និងឧស្ម័ន ។ ឧទាហរណ៍ : រឹង រាវ និង ឧស្ម័ន គឺជាភាពរូបទាំង 3 នៃរូបធាតុ ។ |
| ម៉ាក្រូម៉ូលេគុល | ជាម៉ូលេគុលធំៗ ។ គេប្រើសម្រាប់ពណ៌នាពីម៉ូលេគុល ។ |
| ម៉ូល | ជាចំនួនសន្មតមួយ ដែលមួយម៉ូលតាងចំនួន $6.02\times10^{23}$ និងមាននិមិត្តសញ្ញា mol ។ |
| ម៉ូលេគុល | ក្រុមអាតូមដែលចងសម្ព័ន្ធជាមួយគ្នាក្នុងសមាមាត្រកំណត់មួយ ដើម្បីបង្កជាសមាធាតុ ។ ឧទាហរណ៍ : អាតូមអ៊ីដ្រូសែនពីរ និងអាតូមអុកស៊ីសែនមួយ បង្កើតបានជាម៉ូលេគុលទឹក $H_2O$ . . . ។ |
| រូបធាតុ | ភាវៈដែលមានម៉ាសនិងមាឌក្នុងលំហ ។ |
| លោហៈ | ពួកអង្គធាតុទោលដែលមានផ្លេកលោហៈ ចម្លងកំដៅ និងអគ្គិសនីបានល្អ និងជាទូទៅអាចផែឬហូតជាលួសបាន ។ |
| លោហៈឆ្លង | ធាតុដែលមិនទាន់បំពេញគ្រប់ស្រទាប់ d ។ |
| លោហៈអាល់កាលីណូទែរ៉ី | ធាតុក្នុងក្រុមទី IIA (Be Mg Ca Sr Ba និង Ra) ។ |
| លោហៈអាល់កាឡាំង | ធាតុក្នុងក្រុមទី IA (Li Na K Rb Cs និង Fr) ។ |
| លំនាំហេប៊ើ | លំនាំឧស្សាហកម្មសម្រាប់ផលិតអាម៉ូញ៉ាក់ ដោយប្រតិកម្មអ៊ីដ្រូសែនជាមួយអាសូតលើសដោយយកកាតាលីករដែកនៅ 450°C និងសម្ពាធ 250atm ។ឧទាហរណ៍ : $N_2 + 3H_2O \to NH_3$ ។ |

For MPTC-Ebooks Only

| | |
|---|---|
| វង់បង់សែនឬណ្វៃយ៉ូបង់សែន | គឺជាស៊ិច (Cycle) នៃអាតូម C មានរាងជាឆកោណនិយ័ត ដែលអាតូម C ទាំង 6 ជាកំពូលរបស់ឆកោណនិងមានសម្ព័ន្ធពីរជាន់ឆ្លាស់ជាមួយសម្ព័ន្ធមួយជាន់ ។ |
| វត្ថុធាតុដើម | សារធាតុដែលប្រើប្រាស់ក្នុងផលិតកម្មគីមីឬឧស្សាហកម្មអាហារ ។ វត្ថុធាតុដើមដែលប្រើក្នុងឧស្សាហកម្មគីមីមាន : អ៊ីដ្រូកាបួ ខ្យល់ រ៉ែ លោហៈ ទឹក ។ |
| វ៉ាឡង់ | ចំនួនបង្ហាញពីលទ្ធភាពបន្សំនៃធាតុមួយចំពោះធាតុមួយផ្សេងទៀត ។ |
| វីសមរូប | លក្ខណៈនៃអង្គធាតុរ៉ែទោលឬសមាសដែលមានទម្រង់ និងលក្ខណៈរូបផ្សេងៗគ្នា ។ |
| សិលាឃ្លាំង | សិលាស្ពោតមានសណ្ឋាន ដូចជាអេប៉ុង ។ |
| សម្ព័ន្ធកូវ៉ាឡង់ | សម្ព័ន្ធដែលកើតឡើងដោយការដាក់ហ៊ុនអេឡិចត្រុងជាទ្វេតា ។ |
| សម្ព័ន្ធកូវ៉ាឡង់ប៉ូលែ | សម្ព័ន្ធដែលកើតឡើងដោយការដាក់ហ៊ុន $e^-$ រួមនៃអាតូមដែលចងសម្ព័ន្ធ ។ ប៉ុន្តែទ្វេតា $e^-$ នេះខិតទៅជិតអាតូមដែលមានកម្រិតអេឡិចត្រូអវិជ្ជមានខ្លាំងជាង ។ឧទាហរណ៍ : $H \rightarrow Cl$ . . . ។ |
| សម្ព័ន្ធកូវ៉ាឡង់មិនប៉ូលែ | សម្ព័ន្ធដែលកើតឡើងដោយការដាក់ហ៊ុន $e^-$ រួមនៃអាតូមចងសម្ព័ន្ធ តែទ្វេតា $e^-$ រួមនេះមិនខិតទៅជិតអាតូមណាមួយឡើយ ។ឧទាហរណ៍ : $H-H$ , $O = O$ . . . ។ |
| សម្ព័ន្ធគីមី | កម្លាំងទំនាញរវាងអាតូមដែលបង្កឡើងដោយការបែងចែកឬការបញ្ជូនអេឡិចត្រុង ។ |
| សម្មតិកម្ម | ទ្រឹស្តីឬច្បាប់ដែលមិនអាចពិតជាសកល ។ |
| សមាសធាតុ | អង្គធាតុដែលកើតឡើងដោយបន្សំរវាងធាតុពីរឬច្រើន ។ |

For MPTC-Ebooks Only

| | |
|---|---|
| សម្ព័ន្ធលោហៈ | ប្រភេទសម្ព័ន្ធគីមីដែលអាតូមជាច្រើនដាក់រួមអេឡិចត្រុងដោយផ្តល់អេឡិចត្រុងនីមួយៗជាមួយក្រុម អេឡិចត្រុងដែលចល័តជុំវិញអាតូម ។ |
| សម្ព័ន្ធអ៊ីយ៉ុង | សម្ព័ន្ធដែលកើតពីកម្លាំងទំនាញរវាងអ៊ីយ៉ុងពីរដែលមានបន្ទុកផ្ទុយគ្នា ។ |
| សម្ព័ន្ធអ៊ីដ្រូសែន | កម្លាំងអន្តរម៉ូលេគុលខ្សោយដែលក្នុងនោះអាតូមអ៊ីដ្រូសែនចងសម្ព័ន្ធកូវ៉ាឡង់ទៅនឹងអាតូមដែលមានកម្រិតអេឡិចត្រូអវិជ្ជមានខ្លាំង( F , N , O ) ហើយចងសម្ព័ន្ធខ្សោយផងដែរទៅនឹងទ្វេតាអេឡិចត្រុងមិនដាក់រួមនៃអាតូមដែលមានកម្រិតអេឡិចត្រូអវិជ្ជមានអាតូមនៅក្បែរនោះ ។ |
| សមាសធាតុប្រហើរ | ជាសមាសធាតុសរីរាង្គដែលមានវង់បង់សែនក្នុងម៉ូលេគុល ។ |
| សារធាតុ | ប្រភេទនៃរូបធាតុដែលមានសមាសភាពគីមីកំណត់មួយ ។ |
| អង្គធាតុចង្អុលពណ៌ | ជាសារធាតុដែលអាចមានពណ៌ខុសៗគ្នាក្នុងមជ្ឈដ្ឋានអាស៊ីតនិងបាស ។ |
| អលោហៈ | ធាតុដែលមិនមែនជាលោហៈ មិនចម្លងកម្តៅឬចរន្តអគ្គិសនី ។ វាមានអេឡិចត្រូអវិជ្ជមាន និងបង្កើតជាអ៊ីយ៉ុងអវិជ្ជមាន ឬសម្ព័ន្ធ កូវ៉ាឡង់ក្នុងសមាសធាតុនិងបង្កើតអុកស៊ីតណឺតឬអុកស៊ីតអាស៊ីត ។ |
| អាញ៉ុង | ជាអ៊ីយ៉ុងដែលមានបន្ទុកអវិជ្ជមាន ។ |
| អាឡូសែន | ធាតុដែលឋិតនៅក្នុងក្រុមទី VIIA ឬក្រុមទី 17 នៃតារាងខួប(F Cl Br I និង At ) ។ |
| អ៊ីដ្រូកាបួ | សមាសធាតុផ្សំដោយកាបូននិងអ៊ីដ្រូសែន ។ |
| អ៊ីយ៉ុងកុំផ្លិច | ក្រុមអាតូមឬរ៉ាឌីកាល់មានបន្ទុកអគ្គិសនីសាំញ៉ាំ ។ |
| អុកស៊ីត | ផលិតផលនៃប្រតិកម្មរវាងអុកស៊ីសែនជាមួយធាតុមួយទៀត ។ |

| | |
|---|---|
| អុកស៊ីតកម្ម | លំនាំបាត់បង់អេឡិចត្រុងដោយផ្នែកឬទាំងស្រុងឬក៏ការចំណេញអុកស៊ីសែន ។ វាក៏ជាលទ្ធផលនៃការកើនឡើងនូវចំនួនអុកស៊ីតកម្មនៃអាតូម ។ ឧទាហរណ៍ ៖ ពេលដែកឡើងច្រែះវាប្តូរចំនួនអុកស៊ីតកម្មរបស់វា 0 ទៅ +3 ។ |
| អ៊ីសូតូប | ជាប្រភេទអាតូមនៃធាតុតែមួយ ដែលមានចំនួនប្រូតុងដូចគ្នា តែមានចំនួនណឺត្រុងខុសគ្នា ។ឧទាហរណ៍ ៖ ធាតុអ៊ីដ្រូសែន មានអ៊ីសូតូបបីគឺ ៖ ${}^{1}_{1}H$ ${}^{2}_{1}H$ ${}^{3}_{1}H$ ។ |
| អេឡិចត្រុងវ៉ាឡង់ | ជាអេឡិចត្រុងស្រទាប់ក្រៅនៃអាតូមដែលទាក់ទងក្នុងការចងសម្ព័ន្ធគីមី ។ |
| ឥន្ធនៈ | ជាធាតុឆេះដូចជាឧស្ម័នធម្មជាតិ ប្រេងកាត ធ្យូងថ្ម អុស នុយក្លេអ៊ែ . . . ។ |
| ឥន្ធនៈផូស៊ីល | សមាសធាតុកាបូន ឬអ៊ីដ្រូកាបួធម្មជាតិដែលកកើតឡើងពីការបំបែកធាតុនៃរូបធាតុសរីរាង្គនៅក្នុងសំបកផែនដីក្នុងធរណីកាលដោយពុំមានការចូលរួមពីខ្យល់ ។ ឥន្ធនៈផូស៊ីលសំខាន់ៗមានៈឧស្ម័នធម្មជាតិ ប្រេងកាត ធ្យូងថ្ម ។ |
| ឧស្ម័នកម្រ | ធាតុក្នុងក្រុមទី VIII (ឬក្រុម *O* ឬក្រុមទី 18) នៃតារាងខួបធាតុ(He Ne Ar Kr Xe និង Rn) ។ |

For MPTC-Ebooks Only